# ស្ថានភាពស្ត្រីនៅកម្ពុជា

**រៀបរៀងដោយ  : Natalie Hacks**

**ខែកក្កដា  ឆ្នាំ២០០៤**

**ព័ត៌មានបន្ថែម  សូមទំនាក់ទំនង:**

**វេជ្ជ. ពុង ឈីវកេក**

**ប្រធានអង្គការលីកាដូ**

អាសយដ្ឋានលេខ១៦  ផ្លូវ៩៩  ភ្នំពេញ  កម្ពុជា

ប្រអប់សំបុត្រលេខ  :  ៤៩៩  ប្រៃសណីយ៍ភ្នំពេញ

ទូរស័ព្ទលេខ  :(៨៥៥)  ២៣  ៣៣០  ៩៦៥  /  ៣៦៤  ៩០១

ទូរសារលេខ  :(៨៥៥)  ២៣  ៣៣០  ៩៦៥  /  ២១៧  ៦២៦

អ៊ីម៉ែល:licadho@camnet.com.kh

គេហទំព័រ: www.licadho.org/

# មាតិកា


ទំព័រ

**សទ្ទានុក្រម** ........ **៦**

**I.បុព្វកថា** ........ **៨**

ប្រវត្តិអតីតកាល ........ ៨

ការអនុវត្តន៍អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំង នឹងនារីភេទ និងការការពារសិទ្ធិស្ត្រី ........ ១០

ប្រភពឯកសារ និងការវិភាគទិន្នន័យ ........ ១៣

**II- សមភាពចំពោះមុខច្បាប់** ........ **១៥**

បញ្ហាច្បាប់ដែលស្ត្រីកំពុងប្រឈមមុខ ........ ១៥

អនុសាសន៍ ........ ១៦

**III- អាពាហ៍ពិពាហ៍ និងគ្រួសារ** ........ **១៧**

ប្តីមួយ ប្រពន្ធមួយ ........ ១៧

អាពាហ៍ពិពាហ៍ផ្សំផ្គុំដោយមាតាបិតា ........ ១៨

អំពើហិង្សាក្នុងគ្រួសារ និងអំពើរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ ........ ១៨

អនុសាសន៍ ........ ២១

**IV- អំពើហិង្សាលើស្ត្រី និងកុមារ** ........ **២៣**

រំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ ........ ២៣

ជនរងគ្រោះ ........ ២៣

តារាងទី១ ករណីរំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ ដែលអង្គការលីកាដូបានស៊ើបអង្កេតក្នុងឆ្នាំ ២០០២-២០០៣ ........ ២៤

តារាងទី២ អាយុជនរងគ្រោះ (អនិតិជន) ........ ២៤

ការរាយការណ៍អំពីករណីរំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ ........ ២៤

ការរំលោភសេពសន្ថវៈជាពួក ........ ២៥

តារាងទី ៣ ការស៊ើបអង្កេតករណីរំលោភជាក្រុមក្នុងឆ្នាំ ២០០២-២០០៣ ........ ២៥

ជនល្មើស (ចារីជន) ........ ២៥

ឧបសគ្គនានានៅក្នុងប្រព័ន្ធច្បាប់ ........ ២៦

ដំណោះស្រាយក្រៅច្បាប់ ........ ២៧

ការទទួលខុសត្រូវចំពោះចំនួនករណីកើនឡើងដែលបានរាយការណ៍ ........ ២៨

ការស្តារនីតិសម្បទារសំរាប់ជនរងគ្រោះ ........ ២៩

អំពើហិង្សាផ្នែកយេនឌ័រ ........ ៣០

ការវាយប្រហារដោយទឹកអាស៊ីត ........ ៣០

ការងារដោយបង្ខំលើស្ត្រី និងកុមារ ........ ៣២

ការសុំកូនចិញ្ចឹម ........ ៣៣

អនុសាសន៍.......... ៣៥
**V- ស្ត្រី និងកុមារដែលត្រូវបានគេជួញដូរ និងបានធ្លាក់ទៅក្នុងមុខរបរផ្លូវភេទ.......... ៣៧**
ហេតុអ្វីបានជាស្ត្រីកម្ពុជាធ្លាក់ទៅក្នុង និងនៅតែបន្តប្រកបអាជីវកម្មផ្លូវភេទនេះ.......... ៣៨
និទ្ទណ្ឌភាពផ្នែកច្បាប់ចំពោះជនល្មើសប្រព្រឹត្តអំពើជួញដូរមនុស្ស និងមេបន.......... ៣៩
ស្ត្រីវៀតណាមបំរើផ្លូវភេទនៅកម្ពុជា.......... ៤០
កម្មវិធីការស្តារនីតិសម្បទារ និងសមាហរណកម្មដល់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ.......... ៤១
សុខភាពចំពោះស្ត្រីបំរើផ្លូវភេទ.......... ៤២
ការជួញដូរស្ត្រី និងកុមារដែលពុំមែនក្នុងគោលបំណងជួញដូរផ្លូវភេទ.......... ៤២
អនុសាសន៍.......... ៤៤
**VI- ស្ត្រីក្នុងពន្ធនាគារ.......... ៤៦**
ស្ថានភាពរស់នៅ.......... ៤៦
ការរំលោភលើអ្នកទោស និងពិរុទ្ធជន.......... ៤៨
កុមារធំដឹងក្តីនៅក្នុងពន្ធនាគារ.......... ៤៩
អនុសាសន៍.......... ៥០
**VII- ស្ត្រីនៅតាមជនបទ.......... ៥១**
ការវិលវល់នៃវឌ្ឍនភាពក្រីក្រ និងឧបសគ្គ ដែលប្រឈមមុខនឹងការអភិវឌ្ឍន៍សំរាប់ស្ត្រីជនបទ .. ៥១
ស្ត្រីមេគ្រួសារ.......... ៥៣
ស្ត្រីក្នុងការកែទំរង់ជនបទ និងកិច្ចអភិវឌ្ឍន៍សហគមន៍.......... ៥៣
ស្ត្រីក្នុងវិស័យកសិកម្ម.......... ៥៤
អនុសាសន៍.......... ៥៤
**VIII- ស្ត្រី និងសុខភាព.......... ៥៥**
លទ្ធភាពក្នុងការទទួលបានសេវាសុខភាពមានគុណភាព.......... ៥៥
ការគាំពារមាតា.......... ៥៦
ការពន្យាកំណើត.......... ៥៧
អនុសាសន៍.......... ៥៨
**IX- ស្ត្រីបំរើការងារ.......... ៥៩**
បៀវត្សស្មើគ្នា.......... ៥៩
សន្តិសុខការងារ និងការគាំពារមាតាដែលបំរើការងារ.......... ៦០
ស្ត្រីក្នុងឧស្សាហកម្មកាត់ដេរ.......... ៦០
ស្ត្រីក្នុងវិស័យកសិកម្ម.......... ៦២
ពលករទេសន្តប្រវេសន៍ (ពលករចំណាកស្រុក).......... ៦២
អនុសាសន៍.......... ៦៣
**X- ស្ត្រីក្នុងវិស័យអប់រំ.......... ៦៥**
ការអប់រំបឋមសិក្សា.......... ៦៥

ការអប់រំនៅមធ្យមសិក្សា និងកំរិតឧត្តមសិក្សា ........ ៦៦
ការហ្វឹកហ្វឺនជំនាញ និងវិជ្ជាជីវៈ ........ ៦៧
អនុសាសន៍ ........ ៦៧
**XI- ស្ត្រីក្នុងកិច្ចការនយោបាយ ជីវភាពសាធារណៈ និងកិច្ចការបរទេស ........ ៦៨**
ការបោះឆ្នោត និងតំណាងនៅក្នុងរដ្ឋាភិបាល ........ ៦៩
សេរីភាពក្នុងការចូលរួមប្រជុំ ........ ៦៩
ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ ២០០២ ........ ៧០
ការបោះឆ្នោតជាតិ ឆ្នាំ២០០៣ ........ ៧០
ស្ត្រីក្នុងប្រព័ន្ធតុលាការ ........ ៧១
ស្ត្រីក្នុងវិស័យកិច្ចការអន្តរជាតិ ........ ៧២
**អនុសាសន៍** ........ ៧២
**XII. សេចក្តីសន្និដ្ឋាន ........ ៧៣**
ការផ្តល់អំណាចដល់ស្ត្រីកម្ពុជាពេលអនាគត ........ ៧៣
សេរីភាព និងទំនុកទុកចិត្តលើខ្លួនឯង ........ ៧៣
ស្ថាប័នរដ្ឋនានា និងរដ្ឋាភិបាល : ផ្លូវឆ្ពោះទៅរកការផ្តល់អំណាចស្ត្រី ........ ៧៣

**ឯកសារយោង ........ ៧៥**

# សទ្ទានុក្រម

| | |
|---|---|
| AAFLI | វិទ្យាស្ថានការងារសេរីអាស៊ី អាមេរិក |
| ARIAT | គំនិតផ្តួចផ្តើមនៃតំបន់អាស៊ីប្រឆាំងនឹងអំពើជួញដូរមនុស្ស |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CPP | គណបក្សប្រជាជនកម្ពុជា |
| CSD | មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| CITA | សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ |
| CNCW | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| CWCC | មជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ |
| CWDA | ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា |
| ECPAT | បញ្ឈប់ពេស្យាចារកុមារក្នុងវិស័យទេសចរណ៍អាស៊ី |
| DRK | សាធារណៈរដ្ឋប្រជាធិបតេយ្យកម្ពុជា |
| FHH | ស្ត្រីមេគ្រួសារ |
| GAD | យេនឌ័រ និងការអភិវឌ្ឍន៍កម្ពុជា |
| HR | សិទ្ធិមនុស្ស |
| IHRT | អនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| KOC | ព្រះរាជាណាចក្រកម្ពុជា |
| LAC | ជំនួយផ្នែកច្បាប់កម្ពុជា |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស |
| MoH | ក្រសួងសុខាភិបាល |
| MoJ | ក្រសួងយុត្តិធម៌ |
| MOSALVY | ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទារ |
| MSF | គ្រូពេទ្យគ្មានព្រំដែន |
| NA | សភាជាតិ |

| | |
|---|---|
| NICFIC | គណៈកម្មាធិការអព្យាក្រិត្យ និងឥតលំអៀង ដើម្បីការបោះឆ្នោតសេរី និងយុត្តិធម៌នៅកម្ពុជា |
| NPRS | យុទ្ធសាស្ត្រជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ |
| PADV | កម្មវិធីប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ |
| PAT | កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម |
| PER | ទស្សនាវដ្ដីការចំណាយសាធារណៈ |
| PGE | ដៃគូរ ដើម្បីសមភាពយេនឌ័រ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| TBA | ឆ្មបបែបបុរាណ (ឆ្មបជនបទ) |
| SCM | ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម |
| UNICEF | មូលនិធិកុមារ នៃអង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍ នៃអង្គការសហប្រជាជាតិ |
| UNTAC | អាជ្ញាធរបណ្ដោះអាសន្ន នៃអង្គការសហប្រជាជាតិនៅកម្ពុជា |

# I. បុព្វកថា

## ប្រវត្តិអតីតកាល

ប្រទេសកម្ពុជាត្រូវបានសន្មត់ថា ក្រោយពីឆ្លងកាត់សហសម័យមានជំលោះច្របូកច្របល់ជាប្រវត្តិសាស្ត្រ ដែលធ្វើឱ្យសង្គមជាតិរីកវរ ។ កម្ពុជាមានព្រំប្រទល់ដែនជាប់គ្នានៃចន្លោះប្រទេសថៃ និងប្រទេសវៀតណាម តែងបានទទួលនូវអស្ថេរភាព និងទទួលរងនូវការឈ្លានពានទឹកដីពីសំណាក់មហិច្ឆតាបរទេសទៀតផង ។ ការកាន់កាប់ក្នុងរយៈពេលមួយយ៉ាងវែង គឺក្រោមរដ្ឋបាលអាណានិគមបារាំង ដែលគ្រប់គ្រងអស់រយៈពេលជិតមួយសតវត្សរហូតដល់សម័យបារាំងបោះបង់អាណានិគមរបស់ខ្លួននៅគណ្ឌចិនក្នុងទសវត្សឆ្នាំ ១៩៥០[១] ។ នៅពេលនោះប្រទេសកម្ពុជាក៏បានទទួលអធិបតេយ្យភាពមកវិញ ក្រោមរបបរាជាធិបតេយ្យសង្គមរាស្ត្រនិយម ដឹកនាំដោយព្រះមហាក្សត្រ នរោត្តម សីហនុ ។ ការស្តារប្រទេសក្នុងរយៈពេលខ្លីនោះក៏ត្រូវបានអន្តរាយទៅវិញ ដោយសារតែកម្ពុជាជាប្រទេសស្ថិតនៅចន្លោះមនោគមវិជ្ជាប្រទាញប្រទង់នៃការបែងចែកប្រទេសវៀតណាម រវាងសម្ព័ន្ធកុម្មុយនិស្តវៀតណាមខាងជើងជាមួយសហរដ្ឋអាមេរិក ។ កម្ពុជាក៏បានក្លាយទៅជាសមរភូមិសម្ងាត់សំរាប់កំលាំងតស៊ូទាំងនោះ ហើយជាលទ្ធផលនាំអោយមានការបែកបាក់ផ្ទៃក្នុងយ៉ាងធ្ងន់ធ្ងរ ជាហេតុបណ្តាលអោយមានរដ្ឋប្រហារយោធា ដែលដឹកនាំដោយឧត្តមសេនីយ៍ *លន់ ណុល* នៅឆ្នាំ១៩៧០ ។ នេះជាចំណុចចាប់ផ្តើមនៃសង្គ្រាមរ៉ាំរ៉ៃ និងសង្គ្រាមស៊ីវិលអស់រយៈពេល៣០ឆ្នាំ រួមទាំងរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ ដែលដឹកនាំដោយ ប៉ុល ពត ពីឆ្នាំ១៩៧៥-១៩៧៩ ផងដែរ ។ ក្រោយមកក៏ត្រូវបានកាន់កាប់ដោយវៀតណាម ។ បន្ទាប់មកក៏មានការចរចាមួយ ដែលជ្រោមជ្រែងដោយអង្គការសហប្រជាជាតិ ហើយចំណាយអស់ពេលយ៉ាងយូរ នៅទីបំផុតក៏បានឈានដល់កិច្ចព្រមព្រៀងនឹងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស នាថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ ព្រមទាំងមានការបោះឆ្នោតនៅខែឧសភា ឆ្នាំ១៩៩៣ នៅពេលក្រោយបន្ទាប់មក ។

នៅក្នុងសម័យបោះឆ្នោតពហុបក្ស ឆ្នាំ១៩៩៣ គណបក្សហ៊្វុនស៊ិនប៉ិច ដែលដឹកនាំដោយសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ បានឈ្នះសំលេងឆ្នោត ៤៥%នៃសំលេងឆ្នោត ប៉ុន្តែក៏ត្រូវបង្ខំអោយចូលរួមក្នុងរដ្ឋាភិបាលចំរុះដ៏លំបាកមួយជាមួយនឹងគណបក្សប្រជាជនកម្ពុជា ដែលដឹកនាំដោយសម្តេច *ហ៊ុន សែន* ។ ប៉ុន្តែដំណើរការស្តារស្ថានភាពនយោបាយឡើងវិញក៏បានចាប់ផ្តើមដោយការបង្កើតបានរដ្ឋសភាជាតិ និងការចុះព្រះហស្តលេខាលើរដ្ឋធម្មនុញ្ញថ្មីដោយព្រះករុណា ព្រះបាទ *នរោត្តម សីហនុ* ។ ទង្វើនេះបានផ្តល់នូវសញ្ញា

---

[១] គួរកត់សំគាល់ថា វៀតណាមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរំដោះប្រទេសកម្ពុជាអោយរួចផុតពីរបបខ្មែរក្រហម ។ ក្រោយមកក៏មានជនជាតិវៀតណាមយ៉ាងច្រើនចូលមកតាំងទីលំនៅក្នុងទឹកដីកម្ពុជាក្នុងសម័យ ដែលវៀតណាមកាន់កាប់នោះ ប៉ុន្តែជនជាតិវៀតណាមភាគច្រើនពុំមានឯកសារបញ្ជាក់សញ្ជាតិស្របច្បាប់ទេ ។

នៃការបញ្ចប់នូវសម័យដែលគ្មានស្តេចសោយរាជ្យរយៈពេល២៣ឆ្នាំ និងការបង្កើតអោយមានរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញជាថ្មីម្តងទៀត ។ ដោយសារតែរចនាសម្ព័ន្ធបែបប្រជាធិបតេយ្យនៅក្មេងខ្ចីនៅឡើយ កម្ពុជាក៏នៅតែបន្តរងគ្រោះពីការអុកឡុកឥតឈប់ឈររបស់ពួកទ័ពព្រៃខ្មែរក្រហម ដែលបន្តជំលោះរហូតមកដល់ឆ្នាំ១៩៩៩[2] ។ នៅឆ្នាំ១៩៩៧ ការចុះចូលរបស់កងទ័ពខ្មែរក្រហមបានក្លាយទៅជារបត់មួយដែលនាំអោយមានការរង្គោះរង្គើនយោបាយពហុបក្ស ។ ការរាលដាលនៃអំពើហិង្សាបានផ្ទុះឡើងពាសពេញទីក្រុងភ្នំពេញ និងនៅទូទាំងប្រទេសនាខែកក្កដា ដែលបណ្តាលអោយមានមនុស្សរងរបួស ស្លាប់ បាត់បង់ជីវិត និងការបាត់ខ្លួនជាដើម ។ នៅក្នុងបរិយាកាសចលាចល និងអនាធិតេយ្យគ្មានច្បាប់ទំលាប់ ហ៊ុន សែន ក៏បានធ្វើរដ្ឋប្រហារបណ្តេញសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ អោយរត់ទៅរស់នៅនិរទេសនឹងបរទេស ។ ជាងមួយឆ្នាំ ក្រោយមកអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានប្រកាសថា ការបោះឆ្នោតជាតិក្នុងខែកក្កដា ឆ្នាំ១៩៩៨ ត្រូវបានប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌ ហើយថ្ងៃនោះ ហ៊ុន សែន នៅតែកាន់តំណែងជានាយករដ្ឋមន្ត្រី តែម្នាក់ឯង ។ តាមការពិតនៅមុន និងក្រោយពេលបោះឆ្នោតគេបានកត់សំគាល់ឃើញមានការបំភិតបំភ័យ និងអំពើហិង្សាដែលបន្តរហូតដល់ពាក់កណ្តាលខែកញ្ញា ។

ចាប់តាំងពីសម័យបោះឆ្នោតលើកទី១ នៅឆ្នាំ១៩៩៣ កម្ពុជាបានតស៊ូរហូតមកដល់ទីបំផុតមួយជាមួយនឹងអតិតកាលរបស់ខ្លួន ព្រមទាំងបានស្ថាបនានូវមូលដ្ឋានដ៏រឹងមាំមួយ ដើម្បីប្រជាធិបតេយ្យ និងការការពារសិទ្ធិមនុស្សដល់ពលរដ្ឋរបស់ខ្លួន ។ មកដល់របត់នៃសហសវត្សថ្មីគេបានធ្វើអោយមានការរីកចំរើនថែមទៀតហើយរាជរដ្ឋាភិបាលកម្ពុជា ក៏បានផ្តួចផ្តើមនូវដំណើរការវិមជ្ឈការ ដែលបានធ្វើអោយមានការបោះឆ្នោតឃុំ-សង្កាត់នៅឆ្នាំ២០០២ ។ គណបក្សប្រជាជនកម្ពុជារបស់សម្តេច ហ៊ុន សែន បានទទួលជោគជ័យយ៉ាងធំធេង ដោយទទួលបានបេក្ខជនជិត ១.៦០០នាក់ ក្នុងចំណោមឃុំសរុបទាំង ១.៦២១ នៅទូទាំងប្រទេស ។ ទោះបីជាមិនទាន់បានឈានដល់ស្តង់ដាអន្តរជាតិក៏ដោយ ក៏គណបក្សប្រជាជនកម្ពុជាបានយល់ឃើញថានេះ គឺជាជោគជ័យនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដែលចាត់ទុកជាការវិនិច្ឆ័យតាមគំរូយ៉ាងទាបបំផុត ដែលបានកំណត់ដោយការបោះឆ្នោតកាលពីមុនៗ ។ ជាយថាហេតុជោគជ័យទាំងនោះពុំមែនជាជោគជ័យ សំរាប់សមភាពយេនឌ័រទេ ពីព្រោះគណបក្សធំៗបានបដិសេធមិនព្រមទទួលយកប្រព័ន្ធកូតាដែលស្នើសុំអោយមានបេក្ខភាពស្ត្រីភេទ ៣០% ។

ការបោះឆ្នោតឆ្នាំ២០០៣ ថ្មីៗកន្លងទៅនេះ ក៏បានទទួលសំលេងគាំទ្រយ៉ាងច្រើនដោយសារតែនយោបាយពោរពេញទៅដោយអំពើហិង្សា ។ គណបក្សប្រជាជនក៏បានឈ្នះសំលេងភាគច្រើនម្តងទៀតប៉ុន្តែពុំបានដល់ពីរភាគបីដែលអាចគ្រប់គ្រងរដ្ឋតែម្នាក់ឯងដូចបានកំណត់ក្នុងច្បាប់ទេ ។ ក្រោយមកក៏តំរូវ

---

២ ក្រោយពីការបោះឆ្នោតដែលរៀបចំដោយអ៊ុនតាក់ឆ្នាំ ១៩៩៣ គេបានប៉ាន់ប្រមាណថាមានកងទ័ពខ្មែរក្រហមប្រមាណ ១០០.០០០ នាក់ទៀតនៅតែបន្តធ្វើសកម្មភាពទូទាំងប្រទេសកម្ពុជា ( ជាពិសេសនៅតំបន់ពាយ័ព្យ ) ។ ដកស្រង់ពីកាសែតឌីឃែមបូឌាដេលី ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០០៣ ។

អោយមានការបង្កើតរដ្ឋាភិបាលចំរុះមួយ ប៉ុន្តែការជាប់គាំងផ្នែកនយោបាយបានពន្យាពេលរហូតដល់ ១១ខែ ដោយគណបក្សទាំងនោះបានដណ្តើមកាន់កាប់ក្រសួងធំៗ ព្រមទាំងពិភាក្សាលើគោលការណ៍គ្រឹះមួយចំនួន។ ក្នុងកំឡុងពេលនេះ ប្រទេសកម្ពុជាពុំមានដំណើរការនិតិបញ្ញត្តិទេ ហើយការអនុម័តនិតិក្រម ដូចជា ពង្រាងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងច្បាប់ស្តីពីអំពើជួញដូរមនុស្សត្រូវបានអាក់ខាន ។

ប្រាំឆ្នាំក្រោយពីការចុះចាញ់ចុងក្រោយរបស់កងកំលាំងខ្មែរក្រហមនៅកម្ពុជា ការខ្វែងគំនិតគ្នារវាងជាហត្ថលេខីនានានៅតែកើតឡើងជុំវិញការបង្កើតតុលាការ ។ ដើម្បីអោយកម្ពុជាបានចូលរួមក្នុងដំណើរការផ្សះផ្សាស្តារ និងកសាងសន្តិភាពសេចក្តីសំរេចមួយចំនួនត្រូវតែសំរេចអោយបានដើម្បីរៀបចំតុលាការនេះ ។

មរតកនៃចលាចលអំពើហិង្សាដ៏យូរអង្វែងបានបង្ករជាបញ្ហា នឹងនាំមកនូវឧបសគ្គដ៏ធំដល់កម្ពុជាសព្វថ្ងៃ ។ ការរៀបចំសង្គមស៊ីវិលនៅគ្រាដំបូង មានការប្រឈមមុខទៅនឹងបញ្ហាអសន្តិសុខ និងការខ្វះខាតយ៉ាងលំបាកជាទីបំផុត[3] ។ វប្បធម៌និទ្ទណ្ឌភាព ដែលបានរីកធំធាត់ឡើងក្នុងសម័យចលាចលក៏នៅតែបន្តរាំងដល់ក្បាលម៉ាស៊ីនដឹកនាំរដ្ឋ និងបានរួមចំណែកធ្វើអោយអំពើពុករលួយកាន់តែមានភាពធ្ងន់ធ្ងរឡើងៗក្នុងផ្នែករដ្ឋបាលគ្រប់កំរិតទាំងអស់ ។ ប្រព័ន្ធបញ្ហាទាំងនេះ បានបណ្តាលអោយមានការលំបាកយ៉ាងខ្លាំងជាពិសេសដល់ស្ត្រីក្នុងការធានាអោយពួកគេមានសមភាពនៅក្នុងសង្គម ដែលតាមប្រពៃណីស្ត្រីគឺជាអ្នកជំនួយការដល់បុរស ។ លើសពីបញ្ហាទំនាស់នៅក្នុងវប្បធម៌ វាយតំលៃរួមមកលើស្ត្រី ដែលបានកប់ជាយូរមកហើយបញ្ហាដ៏តឹងរឹងដែលស្ត្រីកម្ពុជាកំពុងប្រឈមសព្វថ្ងៃ គឺការកើនឡើងនូវអំពើហិង្សាផ្នែកយេនឌ័រ ការកេងប្រវ័ញ្ច និងភាពក្រីក្រឥតឈប់ឈរ ។

## ការអនុវត្តន៍អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ និងកិច្ចការពារសិទ្ធិស្ត្រី

### មាត្រា ១

> *ដើម្បីបំរើគោលដៅនៃអនុសញ្ញានេះ ពាក្យថា "ការរើសអើងប្រឆាំងនឹងនារីភេទ" មានន័យថា ការបែងចែក ការផាត់ចេញ ឬការដាក់កំហិតណាមួយដែលធ្វើឡើងលើមូលដ្ឋានភេទ ហើយដែលបង្ករឡើង ឬដែលមានទិសដៅធ្វើអោយខូចខាត ឬធ្វើអោយទៅជាមោឃៈដល់ការទទួលស្គាល់*

[3] របាយការណ៍របស់ ADB ថ្មីៗនេះបានបង្ហាញនូវភាពក្រីក្រយ៉ាងខ្លាំងនៅកម្ពុជា ព្រមទាំងសន្និដ្ឋានថាពុំមានសំរេចបានការកាត់បន្ថយភាពក្រីក្រសោះក្នុងកំឡុងពេល ១០ ឆ្នាំ កន្លងទៅនេះ ។ ដកស្រង់ពីការសែតបញ្ញាវ័ន្តខ្មែរមាន ចំណងជើងថា" សុច្ចនៈការកាត់ភាពក្រីក្រកាន់តែដុនដាប" ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ២០០៤ ។

> *ការទទួលបាន ឬការប្រើប្រាស់ដោយនារីភេទនូវសិទ្ធិមនុស្ស និងរាល់សេរីភាពជាគ្រឹះនៅក្នុងវិស័យនយោបាយសេដ្ឋកិច្ច វប្បធម៌ ពលរដ្ឋ ឬក្នុងវិស័យផ្សេងៗទៀតលើមូលដ្ឋានស្មើភាពរវាងបុរស និងនារីទោះជាក្នុងស្ថានភាពអាពាហ៍ពិពាហ៍បែបណាក៏ដោយ[4] ។*

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ជាអនុសញ្ញាមួយនៅឆ្នាំ១៩៨១ ។ រដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅខែតុលា ឆ្នាំ១៩៩២ ហើយក៏បានទទួលស្គាល់ ដោយរដ្ឋធម្មនុញ្ញដែលមានចែងនៅក្នុងមាត្រាទី ៣១.១ ។ ចំពោះពាក្យ ***"រើសអើងប្រឆាំង នឹងនារីភេទ"*** មិនទាន់ត្រូវបានផ្តល់និយមន័យជាផ្លូវការណាមួយនៅក្នុងរដ្ឋធម្មនុញ្ញនៅឡើយទេ រដ្ឋាភិបាលបានអះអាងថាទទួលយកនិយមន័យ ដែលបានគូសបញ្ជាក់នៅក្នុងអនុសញ្ញា ។ វិធានការទៅថ្ងៃមុខ ដើម្បីលុបបំបាត់យ៉ាងសកម្មរាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទត្រូវបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៤៥.១ នៃអនុសញ្ញា ។ យោងតាមរបាយការណ៍របស់រដ្ឋាភិបាលថ្មីៗបំផុតស្តីពីការអនុវត្តន៍ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) "ព្រះរាជាណាចក្រកម្ពុជាបានចាត់ទុកអនុសញ្ញា (CEDAW) ថាជាមូលដ្ឋានច្បាប់សំរាប់អនុវត្តដែលមានអាទិភាពលើច្បាប់កម្ពុជា[5] ។

ជាអកុសលការទទួលស្គាល់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃអំពើហិង្សាប្រឆាំងនឹងនារីភេទដោយស្របច្បាប់នៅមិនទាន់ត្រូវបានធានាថា ស្ត្រីកម្ពុជារួចផុតពីការរើសអើងនៅឡើយទេ ។ ទោះជាមានការខិតខំប្រឹងប្រែងរួមដោយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ព្រមទាំងក្រុមអង្គការសិទ្ធិមនុស្ស ដូចជាអង្គការសម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស (លីកាដូ) ក្នុងការអប់រំ និងលើកកំពស់ការយល់ដឹងអំពីសិទ្ធិដល់ស្ត្រីក៏ស្ត្រីជាច្រើននៅតែមិនទាន់បានយល់ជ្រួតជ្រាប ព្រមទាំងងាយរងគ្រោះជាទីបំផុត[6] ។ នេះគឺជា បញ្ហាពិសេសមួយនៅតាមជនបទដែលមានកំរិតយល់ដឹង និងការអប់រំនៅទាបនៅឡើយ ។ អាស្រ័យដោយ ការភ័យខ្លាចនៅក្នុងសង្គម ដែលខ្ទេចខ្ទាំជាច្រើនឆ្នាំដោយសារសង្គ្រាម

---

[4] នៅក្នុងភាគទីមួយៗពីនេះទៅនឹងបញ្ជាក់មាត្រាពាក់ព័ន្ធមួយចំនួននៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលត្រូវបានពិភាក្សានៅក្នុងអត្ថបទខាងមុខ ។ នៅក្នុងនេះ យើងសន្មត់ថាមានការយល់ដឹងអំពីអនុសញ្ញាខាងលើរួចដូច្នេះប្រយោគសំខាន់ៗនៃមាត្រាទាំងមូល ឬមួយផ្នែកត្រូវបានលើកយកមកបញ្ជាក់ ។ នៅក្នុងរបាយការណ៍នេះមិនបានរៀបតាមលេខលំដាប់របស់អនុសញ្ញាទេ ប៉ុន្តែវាជាការឆ្លុះបញ្ចាំងនូវការវិភាគខ្លឹមសារបញ្ហាដែលជាអាទិភាពនៃកង្វល់ដ៏ខ្លាំងបំផុត ដែលស្ត្រីកំពុងប្រឈមមុខនៅកម្ពុជាសព្វថ្ងៃ ។

[5] របាយការណ៍ដំបូងរបាយការណ៍ទី ២ និងទី៣ស្តីពីការអនុវត្តន៍អនុសញ្ញា ( CEDAW )នៅកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជាខែតុលា ឆ្នាំ២០០៣ ទំ. ២៤ )

[6] លីកាដូត្រូវបានបង្កើតឡើងនៅភ្នំពេញជាអង្គការជាតិមួយនៅឆ្នាំ ១៩៩២ ហើយបច្ចុប្បន្នមានការិយាល័យចំនួន ១៤នៅតាមបណ្តាខេត្តក្រុងនានា ។ គោលការណ៍ដ៏ទូលំទូលាយរបស់លីកាដូរួមមានការស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស និងការជួយជនរងគ្រោះដើម្បីធ្វើបណ្តឹងទៅអាជ្ញាធរពាក់ព័ន្ធនានា ។ ក្រៅពីនេះក៏មានការស្រាវជ្រាវ និងស្វែងរកការគាំទ្រមតិអំពីបញ្ហាសិទ្ធិមនុស្សនានាអប់រំសិទ្ធិមនុស្សដល់សមាជិកអាជ្ញាធរ និងសាធាណៈជនទូទៅផងដែរ ។ លីកាដូ ក៏មានកម្មវិធីសំរាប់ស្ត្រី និងកុមារដែលរងគ្រោះដោយការរំលោភលើរាងកាយ និងផ្លូវភេទជាដើម ។

និងការចលាចលស្ត្រីកម្ពុជាពុំដែល មានបណ្តាញជនសាមញ្ញក្រុមស្ត្រី និងសមាគមដែលមានអាយុកាលវែង និងរៀបចំឱ្យបានល្អ ដូចប្រទេសជិត ខាងដូចជាថៃ និងហ្វីលីពីននៅឡើយ ។ ដើម្បីជំនះលើស្ថានភាពទាំងនេះ ស្ត្រីកម្ពុជាត្រូវបានជួយជ្រោម ជ្រែង និងការពារដោយអង្គការដ៏សកម្ម ដែលប្រកបដោយគំនិតផ្តួចផ្តើមយ៉ាងច្រើន ។ អង្គការទាំងនេះអាច សហការគ្នាជាសម្ព័ន្ធភាពមួយ និងគាំទ្រគំនិតផ្តួចផ្តើមជាវិជ្ជមានដោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ព្រមទាំងបញ្ចុះបញ្ចូលរដ្ឋាភិបាលដើម្បីអោយមានសមភាពយេនឌ័រ និងកំណែទំរង់ច្បាប់ ។

ការងារដ៏ឧត្តុងឧត្តម្ភជាច្រើនក្នុងកិច្ចការពារ និងលើកស្ទួយសិទ្ធិស្ត្រីត្រូវបានអនុវត្តដោយឃែមបូវ (CAMBOW)[7] ។ ខែមបូវ គឺជាសមាគមនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ៣៣ជាសមាជិក ដែលអនុវត្តការងារលើបញ្ហាស្ត្រីជាចំបង ។ អង្គការទាំងនេះបានស្វះស្វែងក្នុងការលុបបំបាត់ចោលនូវច្បាប់ ដែលមានការរើសអើងនឹងអនុវត្តប្រឆាំងចំពោះស្ត្រី ជាពិសេសច្បាប់ដែលទាក់ទងទៅនឹងអំពើហិង្សាក្នុង គ្រួសារ និងអំពើជួញដូរមនុស្ស ។ ឃែមបូវ ធ្វើការបញ្ចុះបញ្ចូលអ្នកនយោបាយ ក្រសួង ស្ថាប័នរដ្ឋនានា គណៈកម្មាធិការសំខាន់ៗក៏ដូចជាការរៀបចំអោយមានការពិភាក្សាតុមូលសវនាការសាធារណៈ និងសន្និសីទ កាសែតជាដើម ។ ឃែមបូវធ្លាប់បានរៀបចំការដើរក្បួន និងបាតុកម្មដោយសន្តិវិធី ដើម្បីលើកកំពស់ការ យល់ដឹងអំពីអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែសកម្មភាពទាំងនេះត្រូវបានរដ្ឋាភិបាលហាមឃាត់មិនអោយរៀបចំ ទេក្នុងពេលថ្មីៗកន្លងទៅនេះ ។ ឃែមបូវកន្លងមកធ្លាប់ទទួលបានជោគជ័យគួរអោយកត់សំគាល់ក្នុងការ ស្វែងរកការគាំទ្រមតិធ្វើវិសោធនកម្មក្នុងពង្រាងច្បាប់ថ្មីស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែនៅ តែប្រឈមនឹងឧបសគ្គធំៗជាច្រើនក្នុងការធានាអោយមានវិសោធនកម្មនេះ ។ នៅមានកិច្ចការដែលត្រូវ ធ្វើបន្តទៀត គឺត្រូវធ្វើការបញ្ចុះបញ្ចូលក្រសួងយុត្តិធមិអោយធ្វើសេចក្តីព្រាងច្បាប់គោលមួយស្តីពីអំពើជួញ ដូរមនុស្ស ។ បញ្ហានេះនឹងត្រូវលើកយកមកពិភាក្សាលំអិតថែមទៀតនៅក្នុងផ្នែកខាងមុខទៀតនៃរបាយ ការណ៍នេះ ។

ឧបសគ្គមួយដែលជាឧបសគ្គធំជាងគេបំផុតក្នុងការអនុវត្តន៍អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) គឺភាពទន់ខ្សោយនៃប្រព័ន្ធច្បាប់ ដែលកម្រនឹងអាចផ្តន្ទា ទោសជនល្មើសក្នុងករណីរើសអើងផ្លូវភេទណាស់ ។ នៅក្នុងករណីព្រហ្មទណ្ឌមានប្រព័ន្ធជំនួយផ្នែកច្បាប់ ពិសេសមួយ ប៉ុន្តែស្ត្រីទាំងឡាយហាក់ដូចជា ចូលចិត្តពឹងផ្អែកទៅលើការគាំទ្ររបស់ក្រុមអង្គការមិនមែនរដ្ឋា ភិបាលជាជាង ដូចជាអង្គការលីកាដូ (LICADHO) និងអង្គការជំនួយផ្នែកច្បាប់កម្ពុជា (LAC) ជាដើម ដែលអាចជួយស្ត្រីក្នុងការនាំយកករណីទាំងឡាយទៅចំពោះមុខតុលាការបាន ។ ទោះបីជានៅក្នុងករណី

---

[7] ឃែមបូវត្រូវបានបង្កើតឡើងនៅ ឆ្នាំ២០០០ ដោយមានការផ្តួចផ្តើមគាំទ្រនិងផ្តល់មូលនិធិ ដោយអង្គការមូលនិធិអាស៊ី ។

កេងប្រវ័ញ្ច និងករណីរំលោភធ្ងន់ធ្ងរ ក៏ស្ត្រីភាគច្រើនតែងមានអារម្មណ៍ទទួលការបង្ខិតបង្ខំអោយទទួលយករបៀបដោះស្រាយតាមការសំរេចរបស់សហគមន៍តាមបែបទំនៀមទំលាប់ និងទទួលយកសំណងជំងឺចិត្តជាជាងរកដំណោះស្រាយតាមផ្លូវច្បាប់ចំពោះបទល្មើសដែលបានប្រព្រឹត្តចំពោះពួកគេ ។ ទង្វើបែបនេះ ជាការពង្រឹងនូវវប្បធម៌និទ្ទណ្ឌភាព ហើយអាចជាកត្តារួមចំណែកក្នុងការធ្វើអោយមានការកើនឡើងនូវអំពើហិង្សា និងការរើសអើងប្រឆាំងនឹងនារីភេទនៅកម្ពុជាបច្ចុប្បន្ននេះ (២០០៤) ។ មន្ត្រីរដ្ឋាភិបាលនានាមេធាវី និងនគរបាលនៅគ្រប់លំដាប់ថ្នាក់ក្នុងជួររដ្ឋបាលត្រូវរៀនសូត្របន្ថែមទៀតអំពីសារសំខាន់ក្នុងការពង្រឹងសិទ្ធិស្ត្រី និងការអនុវត្តន៍ ការពង្រឹងផ្នែកច្បាប់អោយមានប្រសិទ្ធិភាពចំពោះការផ្តន្ទាទោសជនទាំងឡាយដែលរំលោភលើសិទ្ធិជាមូលដ្ឋានទាំងនេះ ។

## ប្រភពឯកសារ និងការវិភាគទិន្នន័យ

ព័ត៌មានក្នុងរបាយការណ៍នេះត្រូវបានដកស្រង់ចេញពីប្រភពឯកសារ របាយការណ៍ អេឡិចត្រូនិកនានាដែលត្រូវបានពិនិត្យពិច័យ និងវាយតំលៃយ៉ាងប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ ដើម្បីបង្ហាញស្ថានភាពស្ត្រីកម្ពុជានាពេលបច្ចុប្បន្នអោយបានត្រឹមត្រូវ និងឥតលំអៀង ។

នៅកម្ពុជា ឆ្នាំ២០០៣ កន្លងទៅនេះ ពុំមានការធ្វើជំរឿនថ្នាក់ជាតិទេ ហើយសុច្ចនករស្ថិតិពលរដ្ឋភាគច្រើនដែលប្រើក្នុងរបាយការណ៍នេះ ត្រូវបានចងក្រងដោយធនាគារពិភពលោក អង្គការសហប្រជាជាតិ និងប្រភពរដ្ឋាភិបាលរហូតមកដល់ឆ្នាំ២០០៣ នេះ ។ មានទិន្នន័យស្ថិតិទូទៅតិចតួច ដែលត្រូវប្រមូលពីការបោះពុម្ពផ្សាយរបាយការណ៍ និងកាសែតថ្មីៗរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ព័ត៌មានដែលត្រូវបានផ្តល់ដោយអង្គការលីកាដូដល់វេទិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាស្តីពីបញ្ហាស្ត្រី ដែលនាំអោយមានវេទិការក្រុងប៉េកាំងនៅឆ្នាំ១៩៩៥ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានគ្រឹះក្នុងការកត់សំគាល់ការផ្លាស់ប្តូរជាបន្តបន្ទាប់នៅក្នុងឆ្នាំអន្តរាគមន៍[8] ។ ជាអកុសល មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមមិនទាន់បានចេញផ្សាយនូវរបាយការណ៍អភិវឌ្ឍន៍សង្គមឆ្នាំ ២០០៤ ដែលអាចបញ្ជាក់ថាជាប្រភពព័ត៌មានថ្មីៗអំពីសុច្ចនករអភិវឌ្ឍន៍នៅកម្ពុជាដែលមានតំលៃខ្ពស់ជាទីបំផុត ។ ស្ថិតិអំពីការជួញដូរមនុស្ស និងនារីរកស៊ីផ្លូវភេទត្រូវបានរៀបចំយ៉ាងប្រុងប្រយ័ត្នជាទីបំផុតដោយការស្រាវជ្រាវថ្មីៗនៅទូទាំងប្រទេសកម្ពុជា រួមមានតួលេខដែលទទួលបានកាលពីមុនជាតួលេខបំប៉ោង និងដែលមិនអាចយកជាការបាន[9] ។

[8] វេទិការអង្គការមិនមែនរដ្ឋាភិបាលស្តីពីបញ្ហាស្ត្រីនៅប៉េកាំងឆ្នាំ ១៩៩៥ : សិទ្ធិស្ត្រីជាសិទ្ធិមនុស្ស (លីកាដូ ១៩៩៥)
[9] ការវាស់ស្ទង់ចំនួនស្ត្រី និងកុមារដែលត្រូវបានគេជួញដូរនៅកម្ពុជា: ការសិក្សានៅមូលដ្ឋានដោយការសង្កេតដោយផ្ទាល់ (Thomas M. Steinfatt សកលវិទ្យាល័យម៉ៃអាមី ឆ្នាំ ២០០៣) ។

ស្ថានភាពស្ត្រីនៅកម្ពុជាអាចវិភាគបានតាមក្របខ័ណ្ឌគោលការណ៍ដ៏ធំទូលាយ ដែលបានចែងនៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ។ ប៉ុន្តែវានៅតែជាការអនុវត្តន៏តាមរបាយការណ៍តំរូវការមិនមានលក្ខណៈច្បាស់លាស់នៅឡើយទេ ។ របាយការណ៍ពីអង្គការស្ត្រី និងក្រុមសិទ្ធិមនុស្សនានា ដែលធ្វើការនៅទូទាំងប្រទេសជាច្រើននៅតែមិនស្របគ្នាជាមួយនឹងការវិភាគអំពីបញ្ហាស្ត្រី និងការអនុវត្តន៏អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទទេ ។ ជាការមិនគួរអោយភ្ញាក់ផ្អើលនោះ គឺរដ្ឋាភិបាលចូលចិត្តតែបង្ហាញពីទិដ្ឋភាពវិជ្ជមាននៃស្ថានភាពស្ត្រីនៅក្នុងប្រទេសកម្ពុជានោះ ។ និយាយជាទូទៅក្រសួងកិច្ចការនារី និងអតីតយុទ្ធជនតែងតែមានចេតនាស្មោះត្រង់អំពីបញ្ហាដែលស្ត្រីកំពុងប្រឈមមុខជាងក្រសួងរដ្ឋផ្សេងៗទៀត ពីព្រោះក្រសួងនេះបានជួបប្រទះ និងបន្តទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលចុះធ្វើការនៅតាមមូលដ្ឋានផ្ទាល់ ។ ចំណុចដែលមិនស្របគ្នាទាំងនោះ គឺទីកន្លែងណាដែលអាចធ្វើទៅបានត្រូវបានគូសបញ្ជាក់នៅក្នុងរបាយការណ៍ ដើម្បីបង្ហាញនូវការពិត និងបញ្ហាពិបាកទាំងឡាយដែលស្ត្រីកំពុងប្រឈមមុខនៅកម្ពុជា ។

## II- សមភាពចំពោះមុខច្បាប់

### មាត្រា ១៥

> *១- នៅចំពោះមុខច្បាប់ រដ្ឋភាគីត្រូវផ្តល់ជូននារីនូវភាពស្មើគ្នានឹងបុរស ។*
>
> *២- នៅក្នុងផ្នែករដ្ឋប្បវេណី រដ្ឋភាគីត្រូវផ្តល់ចំពោះនារីភេទនូវសមត្ថកិច្ចនេះ ។ ជាពិសេសរដ្ឋភាគីត្រូវផ្តល់ចំពោះនារីភេទនូវសិទ្ធិដូចគ្នាក្នុងកិច្ចការចុះកិច្ចសន្យា និងក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ហើយត្រូវចាត់ទុកពួកគេស្មើៗគ្នានៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីក្នុងការជំនុំជំរះ និងនៅតុលាការ ។*
>
> *៣- រដ្ឋភាគីទទួលស្គាល់ថារាល់កិច្ចសន្យា និងរាល់លិខិតតុបករណ៍ឯកជនដទៃទៀតគ្រប់ប្រភេទដែលមានអនុភាពខាងផ្លូវច្បាប់សំដៅដាក់កំហិតលើសមត្ថកិច្ចផ្លូវច្បាប់របស់នារី ត្រូវចាត់ទុកជាមោឃ: និងមិនអាចយកមកប្រើប្រាស់បានឡើយ ។*
>
> *៤- រដ្ឋភាគីទទួលស្គាល់ថា បុរស និងស្ត្រីមានសិទ្ធិដូចគ្នាទាក់ទងទៅនឹងបញ្ញត្តិ ដែលចែងអំពីសិទ្ធិបុគ្គលក្នុងការដើរហើរ និងសេរីភាពក្នុងការជ្រើសរើសទីកន្លែងស្នាក់អាស្រ័យ និងគេហដ្ឋានរបស់ខ្លួន ។*

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាផ្តល់នូវតថភាពដល់កថាខណ្ឌ៤នៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើងអើងប្រឆាំងនឹងនារីភេទ ដែលទាក់ទងទៅនឹងសមភាពចំពោះមុខច្បាប់ ។ នៅក្នុងការអនុវត្តន៏ជាក់ស្តែង ប្រព័ន្ធច្បាប់កម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពទន់ខ្សោយនៅឡើយ និងពោរពេញទៅដោយបញ្ហាដែលរារាំងដល់នីតិរដ្ឋដល់ពលរដ្ឋកម្ពុជាទាំងអស់គ្នា ។ របាយការណ៏របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សបានសន្និដ្ឋានថា "ប្រព័ន្ធតុលាការនៅកម្ពុជាត្រូវបានជ្រៀតជ្រែកដោយស្ថាប័ននយោបាយ ដោយអង្គនីតិប្រតិបត្តិ ជាតុលាការដែលមានសមត្ថភាពក៏រិតទាប ( អាស្រ័យដោយជំនាញខ្សោយ និងខ្វះការហ្វឹកហ្វឺន និងការអប់រំដល់ចៅក្រមទាំងឡាយ ) ព្រមទាំងមានបញ្ហាពុករលួយយ៉ាងច្រើនថែមទៀតផង" [10] ។

## បញ្ហាច្បាប់ដែលស្ត្រីកំពុងប្រឈមមុខ

បញ្ហាជាក់លាក់មួយចំនួនដែលស្ត្រីកម្ពុជាកំពុងប្រឈមមុខចំពោះការធានាផ្នែកផ្លូវច្បាប់របស់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៃរាជរដ្ឋាភិបាលកម្ពុជា គឺមានបីដំណាក់កាល ។ បញ្ហាទីមួយ ច្បាប់សំខាន់ៗ ដើម្បីគាំទ្រសិទ្ធិស្ត្រីនៅមិនទាន់បានអនុម័តអោយទៅជាចង្កោមនិតិកម្មនៅឡើយ ។ ការជាប់គាំងច្បាប់នេះទាក់ទងទៅនឹងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ កំណែលំអច្បាប់ស្តីការប្រឆាំងការជួញដូរមនុស្ស និងពង្រាងក្រមព្រហ្មទណ្ឌថ្មី ដែលចូលរួមក្នុងការ

---

[10] កំហុសធ្ងន់ធ្ងរ : ហេតុអ្វីបានជាមហាសន្និបាតអង្គការសហប្រជាជាតិគួរអោយពង្រាងកិច្ចព្រមព្រៀង អំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមានការផ្លាស់ប្តូរ ( អង្គការឃ្លាំមើលសិទ្ធិមនុស្ស ខែមេសា ឆ្នាំ២០០៣) ។

ដាក់ទណ្ឌកម្មដល់ការរើសអើងផ្នែកយេនឌ័រ ។ ការជាប់គាំងផ្នែកនយោបាយក្រោយការបោះឆ្នោតឆ្នាំ២០០៣ បានបន្តរហូតមកដល់ខែកក្កដា ឆ្នាំ២០០៤ ព្រមទាំងធ្វើអោយខកខានក្នុងការផ្តល់សច្ចាប័នដល់ច្បាប់ទាំងនេះ (និងច្បាប់មួយចំនួនច្រើនទៀត) ដោយក្នុងកំឡុងពេលនោះពុំទាន់មានរដ្ឋសភាជាតិទេ ។

បញ្ហាទី២ គឺភាពងាយរងគ្រោះរបស់ស្ត្រីនៅក្នុងកិច្ចការកិច្ចសន្យា និងតំណែងជាម្ចាស់កម្មសិទ្ធិ ។ ស្ត្រីទើបតែលែងលះប្តីថ្មីៗ និងស្ត្រីមេគ្រួសារ គឺជាក្រុមស្ត្រីដែលងាយរងគ្រោះជាទីបំផុតនៅពេលដែលមាននរណាម្នាក់ដណ្តើមយកដីធ្លីពីពួកគេ ។ ជំនួយផ្នែកច្បាប់សំរាប់ករណីរដ្ឋប្បវេណីកម្រមានជាទីបំផុត ហេតុដូច្នេះស្ត្រីត្រូវរត់ការកិច្ចការច្បាប់នេះដោយខ្លួនឯង ឬព្រមទទួលយកការសម្របសម្រួលក្រៅផ្លូវការក្នុងមូលដ្ឋានរបស់ខ្លួនដែលភាគច្រើនសុទ្ធតែត្រូវធ្វើឡើងដោយភាគីខាងបុរស ។

បញ្ហាចុងក្រោយ គឺធានាធ្វើយ៉ាងណាអោយច្បាប់ការពារស្ត្រី ដែលមានស្រាប់ត្រូវបានលើកយកមកអនុវត្ត និងអនុវត្តអោយមានប្រសិទ្ធិភាពដើម្បីការពារស្ត្រី ។ តំរូវអោយមានការគាំទ្រ និងកិច្ចប្រឹងប្រែងអោយបានច្រើនពីសំណាក់ក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជន ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀតទៅលើបញ្ហាចំបងទ្វេរគ្រោះទាំងពីរ ។ ទីមួយ គឺត្រូវអប់រំស្ត្រីអំពីសិទ្ធិរបស់ពួកគេ ។ ទីពីរ គឺត្រូវបញ្ចុះបញ្ចូលអោយមានការផ្លាស់ប្តូរចំពោះនិទ្ទណ្ឌភាពដែលមានដ៏ច្រើនលើសលុបនៅក្នុងប្រព័ន្ធអនុវត្តច្បាប់ ។

## អនុសាសន៍

- បន្តកែលំអការហ្វឹកហ្វឺន និងលើកទឹកចិត្តអោយមានការហ្វឹកហ្វឺនព្រមទាំងជ្រើសរើសស្ត្រីអោយបានច្រើនថែមទៀត ដើម្បីបំរើការងារនៅក្នុងប្រព័ន្ធតុលាការ ។
- បង្កើតក្រុមសង្កេតការណ៍ច្បាប់ឯករាជ្យ ជាវិធីក្នុងការព្យាយាមប្រឆាំងនឹងនិទ្ទណ្ឌភាព និងការប្រព្រឹត្តអំពើពុករលួយនៅក្នុងប្រព័ន្ធច្បាប់ ។
- ត្រូវខិតខំប្រឹងប្រែងថែមទៀត ដើម្បីធានាអោយមានភាពសុច្ចរិតនៅក្នុងការធ្វើប្លង់ដីសំរាប់ស្ត្រីដែលជាម្ចាស់លើកម្មសិទ្ធិ ។
- បង្កើនជំនួយផ្នែកច្បាប់ដល់ស្ត្រីជាពិសេសដល់ស្ត្រីទន់ខ្សោយដែលងាយរងគ្រោះ ដូចជា ស្ត្រីមេម៉ាយជាមេគ្រួសារជាដើម ។

## III- អាពាហ៍ពិពាហ៍ និងគ្រួសារ

### មាត្រា ១៦

*១- រដ្ឋភាគីនានាត្រូវចាត់គ្រប់វិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់រាល់ការរើសអើងប្រឆាំង នឹងនារីភេទនៅក្នុងគ្រប់វិស័យដែលទាក់ទិនទៅនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ...*

*២- ការភ្ជាប់ពាក្យ និងអាពាហ៍ពិពាហ៍បុត្រធីតានឹងមិនមានប្រសិទ្ធិភាពតាមផ្លូវច្បាប់ឡើយ ហើយរាល់ទង្វើចាំបាច់នានារួមទាំងបញ្ញត្តិច្បាប់ផងត្រូវតែប្រកាន់យកការកំណត់អំពីអាយុអប្បបរមាក្នុងការរៀបអាពាហ៍ពិពាហ៍ ព្រមទាំងការកំណត់ជាកិច្ចចាំបាច់នូវការចុះបញ្ជីអាពាហ៍ពិពាហ៍នៅក្នុងបញ្ជីជាផ្លូវការ ។*

*ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩ បានបញ្ជាក់ពីសិទ្ធិដែលមានតំកល់នៅក្នុងអនុសញ្ញាស្តីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដើម្បីការពារស្ត្រី (និងបុរស) ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ ព្រមទាំងហាមឃាត់មិនអោយមានប្តី ឬប្រពន្ធច្រើន ។ ច្បាប់នោះក៏បានធានាដល់សិទ្ធិរបស់ស្ត្រីក្នុងការលែងលះគ្នាដែរ និងការចិញ្ចឹមកូនថែមទៀត ។ នៅក្នុងការអនុវត្តន៍ជាក់ស្តែងមានការអនុវត្តន៍សិទ្ធិជាមូលដ្ឋានទាំងនេះតិចតួចជាទីបំផុត ។*

## ប្តីមួយ ប្រពន្ធមួយ

ការអនុវត្តន៍ប្រពៃណីប្តីមួយប្រពន្ធមួយ គឺបុរសមានប្រពន្ធច្រើនមិនសូវមានទៀតទេនៅកម្ពុជាបច្ចុប្បន្ននេះ ។ ប៉ុន្តែ ការមានដៃគូររួមភេទខាងក្រៅបានកើតមានជាទូទៅនៅក្នុងប្រទេស បញ្ហានេះ មួយផ្នែក គឺអាស្រ័យដោយមានស្ត្រីរកស៊ីផ្លូវភេទច្រើនពេក ។ បញ្ហាការរួមភេទជាមួយស្ត្រីបំរើផ្លូវភេទនេះត្រូវបានស្ត្រីជាភរិយាជាច្រើនយល់ឃើញថា វាជារឿងធម្មតា និងចាត់ទុកថាជាអំពើដែលកើតឡើងក្នុងរយះពេលដ៏វែង ដែលអាចនាំអោយមានគ្រោះថ្នាក់ដល់ជីវិតអាពាហ៍ពិពាហ៍ទៀតផង ។ និន្នាការនេះកំពុងចាប់ផ្តើមធ្វើអោយស្ត្រីកម្ពុជាទទួលនូវផលវិបាកផ្នែកសុខភាព ។ នៅឆ្នាំ ២០០២ អង្គការយូនីសេហ្វ បានរាយការណ៏ថាមានការកើនឡើងកំរិតឆ្លងរោគជាសមាមាត្ររវាងពីប្តីទៅប្រពន្ធ និងជាសមាមាត្ររវាងពីម្តាយទៅកូនយ៉ាងខ្ពស់ ដែលនាំអោយមានកុមារកំព្រាដោយសារជំងឺអេដស៏អាយុក្រោម ១៥ឆ្នាំ ប្រមាណ ៣០.០០០

នាក់[11] ។ មិនដូចស្ត្រីរកស៊ីផ្លូវភេទមួយចំនួនធំទេ ស្ត្រីមានគ្រួសារហាក់ដូចជាមានការយល់ដឹងអំពី HIV /AIDS នៅទាបនៅឡើយ ហើយថែមទាំងមានអារម្មណ៍ថាមិនអាចហាមឃាត់ការប្រព្រឹត្តិការរួមភេទខាងក្រៅបានទេ ។

## អាពាហ៍ពិពាហ៍ផ្សំផ្គុំដោយមាតាបិតា

ប្រជាជនកម្ពុជាជាច្រើន នៅតែប្រកាន់តាមប្រពៃណីជ្រើសរើសស្វាមីអោយកូនស្រីរបស់ខ្លួន ។ ភាពសមគ្នានៅក្នុងអាពាហ៍ពិពាហ៍បែបនេះមានការខុសប្លែកគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ ជាពិសេសកូនស្រីគ្រួសារក្រីក្រនៅតាមជនបទច្រើនតែត្រូវបង្ខំអោយរៀបអាពាហ៍ពិពាហ៍ ដែលមិនសូវសមគ្នាដូចជា ត្រូវម្តាយលើកអោយបុរសដែលមានទ្រព្យសម្បត្តិច្រើនដែលជារឿងធម្មតា (មានអាយុច្រើនជាង) នៅក្នុងភូមិឃុំ ។ ប្រពៃណីបែបនេះ ក៏ត្រូវបានអនុវត្តនៅក្នុងវណ្ណៈសង្គមថ្នាក់លើផងដែរ ដោយពួកមន្ត្រីខ្ពង់ខ្ពស់យកមកអនុវត្តក្នុងការជ្រើសរើសស្វាមី ភរិយាអោយកូនៗរបស់ពួកគេ ។ ទង្វើនេះជាការធ្វើអោយពលរដ្ឋទូទៅនៅក្នុងសង្គមទាំងមូលយល់ថា មាតាបិតាគួរតែជាអ្នកជ្រើសរើសកូនប្រសារប្រុស-ស្រីជាជាងការជ្រើសរើសតាមរយៈកូនៗរបស់ពួកគាត់ ក្នុងការកំណត់នូវជំរើសអាពាហ៍ពិពាហ៍ដោយខ្លួនឯង ។ នៅក្នុងមាត្រា ១៦ខ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ចែងថាមនុស្សគ្រប់រូប "មានសិទ្ធិដូចគ្នាក្នុងការជ្រើសរើសគូរស្រករដោយសេរី ព្រមទាំងមានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ដោយមានការយល់ព្រមយ៉ាងពេញលេញពីសំណាក់សាម៉ីខ្លួននោះ" ។ កថាខណ្ឌនេះនៅតែមានការគោរពតិចតួចបំផុតនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃនេះ ។

## អំពើហិង្សាក្នុងគ្រួសារ និងអំពើរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍

វេទិកាលីកាដូស្តីពីស្ត្រីកម្ពុជានៅប៉េកាំងឆ្នាំ ១៩៩៥ បានទាមទារថា "អំពើហិង្សាក្នុងគ្រួសារគួរតែបញ្ចូលទៅក្នុងបញ្ជីជំងឺឆ្លងដ៏សំខាន់បំផុតដែលរារាំងដល់ការអភិវឌ្ឍន៍"[12] ។ ប្រាំបួនឆ្នាំក្រោយមកអំពើហិង្សាក្នុងគ្រួសារនៅតែរាលដាលដដែល ហើយមានរបាយ-ការណ៍មួយរាយការណ៍ថាមានស្ត្រីរៀបអាពាហ៍ពិពាហ៍ចំនួន១៧%អាយុពី១៥-៤៥ឆ្នាំ បានរងអំពើហិង្សាលើរាងកាយ និងផ្លូវភេទដោយសារស្វាមីរបស់ពួក

[11] កម្ពុជា: រូបភាពធំ (យូនីសេហ្វ កម្ពុជាឆ្នាំ២០០៣ ទំ. ៣) ។ គួរកត់សំគាល់ថា UNDP ប៉ាន់ប្រមាណថា ចំនួនកុមារកំព្រាមានការកើនឡើងខ្ពស់ដល់ ៥១.០០០ នាក់ក្នុងឆ្នាំ២០០២ តាមពត៌មានទទួលបានចុងក្រោយ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០០៤ តាមរយៈ Web site (www.youandaids.org) ។

[12] វេទិការអង្គការស្តីពីស្ត្រីនៅប៉េកាំងឆ្នាំ ១៩៩៥ : សិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស (លីកាដូ ឆ្នាំ១៩៩៥) ទំ.១០ ។

គេ[13] ។ ជាការគួរអោយរំលឹកផងដែរ ដែលមានស្ត្រីជាង ២៥% ដែលបានរងគ្រោះដោយអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារមិនបានគិតថាពួកគេត្រូវបានទទួលរងការរំលោភទេ[14] ។ ចំណុចនេះបង្ហាញថាស្ត្រីមិនបានយល់ដឹងអំពីសិទ្ធិរបស់ខ្លួនទេ ព្រមទាំងសិទ្ធិជាទូទៅយ៉ាងច្រើនលើសលុបទៀតផង ។

តាមការស្រាវជ្រាវខ្លះបានបង្ហាញអោយឃើញនូវទំនាក់ទំនងរវាងការកើនឡើងនូវអំពើហិង្សាក្នុងគ្រួសារនិងការកើនឡើងនូវភាពក្រីក្រ[15] ។ គេជឿថាការលំបាកដែលបណ្តាលមកពីអស្ថេរភាពខាងផ្នែកហិរញ្ញវត្ថុបាននាំអោយមានភាពតានតឹង និងការអស់សង្ឃឹមក្នុងកំរិតខ្ពស់ ដែលជាហេតុធ្វើអោយមនុស្សចង់តែប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ។ ជាការពិតណាស់ស្ត្រីក្រីក្រ និងខ្វះការអប់រំមានចំនួនយ៉ាងច្រើនក្នុងចំណោមជនរងគ្រោះទាំងឡាយ ។ ការសិក្សាស្រាវជ្រាវមួយដែលធ្វើឡើងដោយអង្គការលីកាដូ បានបង្ហាញនូវទំនាក់ទំនងផ្ទុយរវាងកំរិតការអប់រំ និងអំពើហិង្សាដោយមានស្ត្រី១៩.៨%ក្នុងចំណោមស្ត្រីរងគ្រោះមិនដែលបានចូលរៀន និង១៨%ទៀតបានបញ្ចប់ត្រឹមកំរិតបឋមសិក្សា ហើយស្ត្រីចំនួន ១០.៩%បានរៀនចប់អនុវិទ្យាល័យ និងមានតែស្ត្រី៥.៨%ប៉ុណ្ណោះបានរៀនដល់វិទ្យាល័យ[16] ។ យោងតាមស្ត្រីរងគ្រោះបានអោយដឹងថា ៦៥.៧% នៃស្ត្រីដែលរងរបួសដោយសារអំពើហិង្សាក្នុងគ្រួសារបានបញ្ជាក់ថាគ្រឿងស្រវឹង គឺជាកត្តារួមចំណែកយ៉ាងធំក្នុងការប្រព្រឹត្តិនូវអំពើហិង្សានេះ ។

សង្គ្រាម និងការផ្លាស់ប្តូរប្រពៃណីសង្គមក៏នាំអោយមានឥទ្ធិពលទៅលើកំរិតវិលវល់នៃអំពើហិង្សាក្នុងគ្រួសារក្នុងសង្គមកម្ពុជាដែរ ។ នៅឆ្នាំ១៩៩៦ អង្គការលីកាដូបានប្រមើលមើលថាស្ត្រីដែលកើតទាន់សម័យខ្មែរក្រហមដែលសព្វថ្ងៃមានអាយុពី (៣៦-៥០ឆ្នាំ) យោងតាមរបាយការណ៍បានបង្ហាញអោយឃើញថា មនុស្សក្រុមនេះបានរងអំពើហិង្សាក្នុងគ្រួសារក្នុងកំរិតដ៏ខ្ពស់ជាងគេ[17] ។ ចំណុចនេះជាការបង្ហាញអោយយើងឃើញថា មានទំនាក់ទំនងយ៉ាងខ្លាំងរវាងហិង្សាទំនាស់នៅក្នុងសង្គម និងហិង្សានៅក្នុងគ្រួសារ ។ កត្តារួមផ្សំមួយទៀត គឺការឃ្លាតឆ្ងាយពីប្រពៃណីបន្តិចម្តងៗនៃគូរស្វាមីភរិយាក្នុងការរស់នៅជាមួយនឹងគ្រួសារខាងប្រពន្ធ ។ ការរស់នៅជាមួយនឹងគ្រួសារខាងប្រពន្ធបែបនេះ ជាទូទៅអាចជួយអោយស្ត្រី និងកូនៗមានសន្តិសុខពីអំពើហិង្សាដែលប្រព្រឹត្តដោយស្វាមី ។ ការសិក្សាបន្ថែមទៀតដោយលីកាដូ

---

13 របាយការណ៍ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅកម្ពុជា (គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាស្តីពីអនុសញ្ញា CEDAW ឆ្នាំ ២០០១) ទំ.៥៧ ។
14 សិទ្ធិមនុស្សរបស់ស្ត្រី (វេជ្ជ. ពុង ឈីវកេក ការពិភាក្សាក្នុងតំបន់រវាងសកម្មជនសិទ្ធិស្ត្រី និងអង្គការសិទ្ធិមនុស្ស នានា នៅទីក្រុងម៉ានីល ឆ្នាំ ១៩៩៦) ។
15 មជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ-ជួយស្ត្រីដើម្បីអោយពួកគាត់ចេះជួយខ្លួនឯង (មជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ-របាយការណ៍ប្រចាំឆ្នាំ ខែមករា-ធ្នូ ២០០២ ។
16 សិទ្ធិមនុស្សរបស់ស្ត្រីកម្ពុជា (វេជ្ជ. ពុង ឈីវកេក-ការពិភាក្សាថ្នាក់តំបន់រវាងសកម្មជនសិទ្ធិមនុស្ស និងអង្គការសិទ្ធិមនុស្សនានា នៅទីក្រុងម៉ានីល ឆ្នាំ ១៩៩៦ )
17 ប្រភពឯកសារដដែល ទំ. ២

បានឈានដល់ការសន្និដ្ឋានថា ស្ត្រីរស់នៅកាន់តែឆ្ងាយពីគ្រួសាររបស់នាង នោះនាងកាន់តែងាយរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ[18] ។

ជំលោះហិង្សា និងអំពើរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ នៅតែត្រូវបានចាត់ទុកថាជាបញ្ហាក្នុងគ្រួសារ ដែលនគរបាល និងមន្ត្រីនានាមានការស្ទាក់ស្ទើរក្នុងការជួយ និងសម្រុះសម្រួស ។ ស្ត្រីច្រើនតែមានអារម្មណ៏ឯកោ មិនអាចហ៊ាននិយាយ ឬមានការអៀនខ្មាស់ក្នុងការរកជំនួយខាងក្រៅដើម្បីដោះស្រាយអំពើរំលោភបំពានដែលពួកគេរងគ្រោះដោយស្នាដៃស្វាមីរបស់ពួកគេនោះ ។ នៅតុលាការថ្នាក់ខេត្ត ស្ត្រីអាចសុំលែងលះប្តីបាន ប៉ុន្តែវាជាដំណើរការមួយយ៉ាងវែងអន្លាយដោយរួមទាំងពេលវេលាត្រូវចំណាយដើម្បីផ្សះផ្សាគ្នាផង ។ នៅក្នុងកំឡុងពេលនេះ ស្ត្រីអាចត្រូវបានរងការគាបសង្កត់ដោយញាតិសន្តាន និងមនុស្សផ្សេងៗទៀតនៅក្នុងសហគមន៍ ដើម្បីអោយនាងសុខចិត្តផ្សះផ្សាជាមួយស្វាមីវិញ ។ អំពើហិង្សាក្នុងគ្រួសារពុំមែន ពាក់ព័ន្ធទៅនឹងអំពើហិង្សា ដែលប្រព្រឹត្តទៅលើតែស្ត្រីដោយស្វាមីតែប៉ុណ្ណោះទេ ។ កុមារជារឿយៗក៏បានក្លាយទៅជាជនរងគ្រោះដោយសារអំពើរំលោភបំពានរាងកាយ និងផ្លូវភេទពីសំណាក់មាតាបិតាផងដែរ ។ ពីព្រោះនៅក្នុងសង្គមអាស៊ី វាជាបញ្ហាធម្មតាទៅហើយដែលសាច់ញាតិរស់នៅជាមួយគ្នាក្នុងផ្ទះតែមួយ និងដោយមូលហេតុបញ្ហានេះជនល្មើសក្នុងការប្រព្រឹត្តិអាចជាឪពុក ឬជីតានៅក្នុងគ្រួសារនោះ ។ ដោយសារចំណុចនេះហើយ ទើបវាជាការចាំបាច់បំផុតក្នុងការបញ្ចុះបញ្ចូលរដ្ឋសភាជាតិ ដើម្បីធ្វើយ៉ាងណាអោយពង្រាងច្បាប់ថ្មីស្តីពីអំពើហិង្សាក្នុងគ្រួសារទទួលស្គាល់អ្នកប្រព្រឹត្តបែបនេះផង ពុំមែនទទួលស្គាល់តែអំពើដែលប្រព្រឹត្តដោយស្វាមីរៀបការពេញច្បាប់ប៉ុណ្ណោះទេ ។ អាពាហ៍ពិពាហ៍ភាគច្រើននៅជនបទច្រើនតែ បានរៀបចំឡើងតាមពិធីប្រពៃណី ហើយមិនសូវបានរៀបចំទៅតាមផ្លូវច្បាប់ដែលពុំមានការការពារដល់ភរិយាពិតៗក្រោមពង្រាងច្បាប់ ស្តីពីអំពើហិង្សាក្នុងគ្រួសារដែលបានស្នើឡើងថ្មីនេះ ។ ដូច្នេះឃៃមបូវ និងក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជនត្រូវរក្សាទុកសំពាធទៅលើរដ្ឋសភាអោយបាន ដើម្បីពង្រីងនូវនិយមន័យនៃពាក្យ ***"ជនរងគ្រោះ"*** ដើម្បីអោយបានដាក់បញ្ចូលការប្រព្រឹត្តិទៅលើមនុស្សក្រៅពីសហព័ន្ធថែមទៀតផងដែរ ដូចជា អ្នកបំរើ ឬសាច់ញាតិជាដើម ។ ការធ្វើវិសោធនកម្មនេះត្រូវបានក្រុមប្រឹក្សារដ្ឋមន្ត្រីទទួលយករួចហើយ ប៉ុន្តែក្រោយមកក៏ត្រូវបានរដ្ឋសភាបដិសេធ ។ ដោយសារតែបញ្ហានេះទើបបណ្តាលអោយមានភាពតានតឹងរវាងអង្គការស្ត្រីនានា និងរដ្ឋសភាជាតិ ប៉ុន្តែទោះជាយ៉ាងនេះក្តីការបញ្ចុះបញ្ចូលត្រូវតែធ្វើជាបន្តទៅទៀត ។

ក្រសួងកិច្ចការនារី និងអង្គការនានា ដូចជាមជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) ជាដើមបានអំពាវនាវដល់មណ្ឌលទាំងឡាយនៅតាមបណ្តាខេត្តទូទាំងប្រទេសកម្ពុជាអោយជួយដល់ស្ត្រី ដែលរងអំពើហិង្សាដោយសារអាពាហ៍ពិពាហ៍នេះ ។ ប៉ុន្តែ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះតំរូវអោយមានស្ត្រី

---

[18] ប្រភពឯកសារដដែល ទំ. ២

ដែលមានការហ្វឹកហ្វឺនអំពីការពិគ្រោះប្រឹក្សាបញ្ហាជាបន្ទាន់ ដើម្បីដោះស្រាយតំរូវការច្បាប់ និងចិត្តសាស្ត្ររបស់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនេះ ។ លើសពីនេះទៅទៀតក៏ត្រូវមានមណ្ឌលថែមទៀតដែរដើម្បីផ្តល់ជំនួយដល់ស្ត្រី ដែលស្វែងរកទីកន្លែងសុវត្ថិភាពដោយការរងការរំលោភ និងអំពើហិង្សានោះ ។ ហើយក៏ត្រូវស្ថាបនាការងារបណ្តាញអភិវឌ្ឍន៍ និងយេនឌ័រ ជាបឋមស្ថាបនាគ្លីនិក ដើម្បីកែប្រែបុរសណាដែលចេះតែចង់ប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ។

## អនុសាសន៍

- យុទ្ធនាការផ្សព្វផ្សាយអប់រំគួរតែធ្វើនៅទូទាំងប្រទេស ដើម្បីលើកកំពស់ការយល់ដឹងអំពីច្បាប់របស់ស្ត្រី ជាពិសេសទាក់ទិនទៅនឹងអាពាហ៍ពិពាហ៍ និងការលែងលះគ្នា ។
- ត្រូវធ្វើការបញ្ចុះបញ្ចូលរដ្ឋសភាអោយអនុម័តពង្រាងច្បាប់ទី១ ស្តីពីអំពើហិង្សាក្នុងគ្រួសារដែលយៃមបូវ និងអង្គការនានាបានស្វែងរកការគាំទ្រមតិកន្លងមក ។ ពង្រាងច្បាប់នេះត្រូវបានក្រុមប្រឹក្សារដ្ឋមន្ត្រីអនុម័តរួចហើយមុនបោះឆ្នោតឆ្នាំ២០០៣ ។ ច្បាប់ដែលរដ្ឋសភាបានធ្វើវិសោធនកម្មថ្មីៗនេះមិនគ្រប់គ្រាន់ ដើម្បីការពារជនរងគ្រោះទាំងអស់ដែលត្រូវរងគ្រោះដោយអំពើហិង្សានៅក្នុងគ្រួសារទេ ។ ច្បាប់ថ្មីៗក៏បានទុកអោយមានចន្លោះប្រហោងស្របច្បាប់សំរាប់បុរសក្នុងការគេចពីការដាក់ទណ្ឌកម្មប្រហាក់ប្រហែលគ្នាចំពោះអំពើហិង្សាដែលពួកគេបានប្រព្រឹត្តផងដែរ ។
- យុទ្ធនាការឃោសនា ជាពិសេសនៅតំបន់ជនបទត្រូវប្រឆាំងនឹងគំនិតពីបុរាណ ដែលស្ត្រីត្រូវតែរក្សាចំណងអាពាហ៍ពិពាហ៍របស់ខ្លួនអោយសមនឹងការចំណាយប្រាក់របស់បុរសមកលើនាង ។
- ត្រូវអប់រំស្ត្រីអំពីវិធានការការពារគ្រោះថ្នាក់ និងវិធានកិច្ចការពារចាំបាច់នានា ដើម្បីបញ្ឈប់ការរាលដាលជំងឺ HIV/AIDS ។
- ព័ត៌មានគួរតែប្រើក្នុងន័យស្ថាបនានឹងធ្វើអោយគ្រប់គ្នាបានយល់ ដោយសង្កត់ធ្ងន់បញ្ជាក់ទៅលើសារដែលផ្តល់ដំណឹងថារាល់ទំរង់នៃអំពើហិង្សាក្នុងគ្រួសារនឹងមិនត្រូវបានអត់ឱនជាដាច់ខាតនៅប្រទេសកម្ពុជា ។
- នគរបាល និងមន្ត្រីផ្នែកច្បាប់ត្រូវតែអនុវត្តច្បាប់ដែលមានស្រាប់ ជាកិច្ចការពារពីអំពើហិង្សា និងអំពើរំលោភបំពាន ព្រមទាំងបញ្ឈប់នូវវប្បធម៌និទ្ទណ្ឌភាព ដែលកើតឡើងដ៏ច្រើនលើសលុប ។
- គួរផ្តល់មូលនិធិបន្ថែម ដើម្បីគាំទ្រដល់គំរោងការរបស់អង្គការមិនមែនរដ្ឋាភិបាល និងក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជន ដើម្បីជួយនឹងផ្តល់ជំរកដល់ស្ត្រីខ្វះខាត ។ ព្រមទាំងគំរោងការស្តារនីតិសម្បទាក៏ត្រូវតែមាន ដើម្បីជួយដល់ស្ត្រី និងកុមារក្នុងការជំនះនូវវិបត្តិផ្លូវចិត្ត និងធ្វើអោយពួកគេបានរស់រានឡើងវិញក្នុងសហគម ។

- ជាពិសេស ទង្វើបែបនេះមានសារៈសំខាន់ណាស់ចំពោះកុមាររងគ្រោះដោយអំពើរំលោភបំពាន ដើម្បីកាត់បន្ថយនូវវដ្ដចក្រពីជនរងគ្រោះក្លាយទៅជនល្មើស ។
- ត្រូវអោយមានគ្លីនិក និងការពិគ្រោះប្រឹក្សាបញ្ហា ដើម្បីស្តារនីតិសម្បទារបុរសដែលបានប្រព្រឹត្តនូវអំពើហិង្សាក្នុងគ្រួសារ ។

# IV- អំពើហិង្សាលើស្ត្រី និងកុមារ

អំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាលើស្ត្រី និងកុមារបានកើនឡើងរីករាលដាលកាន់តែធំឡើង១ នៅទូទាំងប្រទេសកម្ពុជា ។ បញ្ហានេះត្រូវបានធ្វើការស្រាវជ្រាវ និងលើកមកពិភាក្សាក្នុងបរិបទនៃស្ថានភាពក្នុងគ្រួសារ ព្រមទាំងទាក់ទងទៅនឹងការរកស៊ីផ្លូវភេទ និងអំពើជួញដូរមនុស្ស ។ អង្គការលីកាដូកំពុងតែព្យាយាមធ្វើយ៉ាងណាអោយបញ្ហានេះត្រូវបានដាក់ទៅក្នុងរបៀបវារៈសំខាន់ ហើយត្រូវបានដោះស្រាយដូចជាបាតុភូតសង្គមមួយដែលកើតឡើងផ្ទួន១ នឹងកើនឡើងនៅខាងក្រៅបរិបទនេះ[19] ។

## រំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់

អំពើរំលោភសេពសន្ថវៈត្រូវបានទទួលស្គាល់ថាជាបទល្មើសព្រហ្មទណ្ឌតាមមាត្រា ៥ នៃច្បាប់ស្តីពីបទល្មើសព្រហ្មទណ្ឌស្ថានក៏រិតទម្ងន់ទោសឆ្នាំ២០០១ ។ នៅក្នុងច្បាប់នេះបានកំណត់ និយមន័យនៃពាក្យរំលោភសេពសន្ថវៈថា "រាល់អំពើរំលោភផ្លូវភេទដែលប្រព្រឹត្តឡើងបំពានទៅលើមនុស្សដោយពុំមានការព្រមព្រៀង "។ ករណីរំលោភ និងការប៉ុនប៉ងរំលោភអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ២០ឆ្នាំ ។ ប្រសិនបើ ករណីបែបនេះត្រូវនាំយកទៅកាត់ទោសពីបទចោទប្រកាន់លើករណីរំលោភ ច្រើនតែត្រូវបន្ធូបន្ថយបទចោទប្រកាន់ជាករណីបៀតបៀនកេរ្តិ៍ខ្មាស់ទៅវិញ ដែលត្រូវចាត់ទុកជាបទព្រហ្មទណ្ឌក៏រិតស្រាលវិញ ហើយទីបំផុតអាចត្រូវកាត់ទោសដោយព្យួរទោស ។ អំពើរំលោភសេពសន្ថវៈ គឺជាប្រភេទបទល្មើសមួយ ដែលពិបាកផ្តន្ទាទោសជាទីបំផុត ហើយដោយនីតិវិធីអាចបណ្តាលអោយជនរងគ្រោះរងការរំលោភលើកទីពីរ ហើយជនរងគ្រោះលើករណីប្រភេទនេះភាគច្រើនជាកុមារ ។

## ជនរងគ្រោះ

តារាងទី១ បង្ហាញនូវចំនួនករណីរំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ដែលអង្គការលីកាដូបានស៊ើបអង្កេតក្នុងឆ្នាំ២០០២-២០០៣ ។ តារាងទី២ បង្ហាញនូវក្រុមអាយុកុមាររងគ្រោះនៅក្នុងករណីនេះ ។ ករណីទាំងនេះ គឺជាភស្តុតាងយ៉ាងច្បាស់លាស់ ដោយករណីរំលោភជាច្រើនបានស្ថិតក្នុងសភាពលាក់កំបាំងដោយលាក់លៀមភាពអាម៉ាស់ ខ្លាចអំណាចជនល្មើស ឬត្រូវការដោះស្រាយក្រៅវិធីប្រព័ន្ធច្បាប់ ។ រាល់ករណីរំលោភសេពសន្ថវៈទាំងឡាយ ដែលបានរាយការណ៍នឹងប្តឹងមកលីកាដូ ជនរងគ្រោះមួយភាគធំ គឺជាកុមារដែល

---

[19] សូមអានឯកសារស្តីពីការរំលោភ និងការបៀតបៀនកេរ្តិ៍ខ្មាស់ (របាយការណ៍ពិសេសរៀបរៀងដោយ (Diane O'connel, LICADHO) ឆ្នាំ២០០១) របាយការណ៍អំពីការរំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ (របាយការណ៍សង្ខេបរបស់លីកាដូ -ភ្នំពេញ ខែមិនា ឆ្នាំ២០០៤ ) ។

មានវ័យក្មេងៗ ។ កុមារី អាចជាជនរងគ្រោះមានកំរិតធ្ងន់ធ្ងរក្នុងការទទួលការរងគ្រោះយ៉ាងខ្ពស់បំផុតក្នុងចំណោមកុមារស្ថិតក្នុងគ្រួសារក្រីក្រ ។

**តារាងទី១ ករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ដែលអង្គការលីកាដូបានស៊ើបអង្កេតក្នុងឆ្នាំ ២០០២-២០០៣ ។**

| កាលបរិច្ឆេទ | ករណីរាយការណ៍នឹងប្តឹង | បានបើកសវនាករណី | កំរិតផ្តន្ទាទោស |
|---|---|---|---|
| ២០០២ | ១៧៩ | ៧១ | ៦៣ |
| ២០០៣ | ១៧៧ | ៥ | ៤ |

**តារាងទី២ អាយុជនរងគ្រោះ ( អនិតិជន)**

| ឆ្នាំ | អាយុក្រោម ១៨ឆ្នាំ | អាយុក្រោម ១២ឆ្នាំ | អាយុក្រោម ៥ឆ្នាំ |
|---|---|---|---|
| ២០០២ | ៨៧.៦% | ៤០.៤% | ៦.៤% |
| ២០០៣ | ៧៧.៨% | ៤១.១% | ៨.៧% |

ប្រភព: រំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ (របាយការណ៍សង្ខេបលីកាដូ ភ្នំពេញ ខែមិនា ឆ្នាំ២០០៤) ។ ក្នុងចំណោមករណី ដែលត្រូវបានស៊ើបអង្កេតលើស្ត្រី ដែលមានអាយុចាប់ពីអាយុ០-៥០ឆ្នាំឡើង កុមារី ដែលមានអាយុចន្លោះពី ១១-១៥ឆ្នាំ មានចំនួនច្រើនជាងគេបំផុត ( ៣៨.៣%) ក្នុងចំណោមករណីទាំងអស់ ។

# សេចក្តីរាយការណ៍អំពីករណីរំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់

នៅប្រទេសកម្ពុជាក៏ដូចជានៅប្រទេសជាច្រើនទៀតដែរ ករណីរំលោភច្រើនតែជាបទឧក្រិដ្ឋមួយប្រភេទដែលមិនសូវត្រូវបានរាយការណ៍ទេ ។ ករណីរំលោភកុមារទំនងជាមានការរាយការណ៍អាស្រ័យដោយការយកចិត្តទុកដាក់របស់មាតាបិតា ។ ប៉ុន្តែករណី ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍រួចទំនងជាមិនសូវបានរាយការណ៍ទេ ។ បញ្ហានេះពាក់ព័ន្ធទៅនឹងកត្តាបន្ទុបន្ថយមួយចំនួន ដែលរារាំងមិនអោយមានការរាយការណ៍នូវករណីរំលោភផ្លូវភេទបែបនេះ ។ ស្ត្រីជាធម្មតាមានអារម្មណ៍អាម៉ាស់យ៉ាងខ្លាំង ព្រមទាំងទទួលរងការស្តីបន្ទោសដាក់កំហុសដោយមិនសមហេតុផលចំពោះការរំលោភនោះ ជាពិសេស នៅពេលដែលជនរងគ្រោះត្រូវបាត់បង់ព្រហ្មចារី ។ ស្ត្រីប្រហែលជាមិនហ៊ានរាយការណ៍អំពីករណីបៀតបៀនកេរ្តិ៍ខ្មាស់ទេពីព្រោះគេយល់ថា ករណីនេះមិនទាន់ធ្ងន់ធ្ងរគ្រប់គ្រាន់សមនឹងប្តឹងផ្តល់ទេ ប្រសិនបើមិនទាន់មានការរំលោភកើតឡើងទេ ។ ការខ្វាយខ្វល់ជាទូទៅ ករណីទាំងនេះមានសភាពធ្ងន់ធ្ងរណាស់ នៅកម្ពុជាមានមនុស្សមួយចំនួនយល់ស្របទៅ និងជំនឿមួយដែលថា លុះត្រាតែមានការបាត់បង់ព្រហ្មចារីទើបបញ្ជាក់ថាជាករណីរំលោភបាន ។ ស្ត្រីអាចមិនចង់រាយការណ៍អំពីករណីរំលោភ ដោយសារតែពុំមានជំនឿជឿជាក់ទៅលើប្រព័ន្ធ

តុលាការ ដែលមានភាពទន់ខ្សោយ ពុករលួយ និងបញ្ហាការចំណាយក្នុងការប្តឹងផ្តល់ (រួមមានការពិនិត្យធ្វើកោសល្យវិច្ច័យនឹងទង្វើសុំលុយកាក់ក្រៅផ្លូវការជាដើម) ក្នុងដំណើរការប្តឹងផ្តល់នោះ ។ ប្រសិនបើជនរងគ្រោះណាម្នាក់សំរេចចិត្តឱ្យមានការធ្វើការស៊ើបអង្កេតដោយហ្មត់ចត់នោះ គាត់នឹងទទួលរងការបំភិតបំភ័យ និងរងគ្រោះថែមទៀតពីជនល្មើសដដែលនោះ ។

## ការរំលោភសេពសន្ថវៈជាក្រុម (សមូហភាព)

តារាងទី៣ បង្ហាញនូវចំនួនករណីដែលបានស៊ើបអង្កេតពីឆ្នាំ ២០០២-២០០៣ ។ អង្គការលីកាដូជឿជាក់ថាបែបរំលោភជាក្រុម (រំលោភដោយក្រុមមនុស្សប្រុស រាប់ពី ៣នាក់ឬច្រើនឡើងទៅ) កំពុងតែក្លាយទៅជាបញ្ហាដ៏ធម្មតាមួយ[20] ។ បញ្ហានេះពាក់ព័ន្ធទៅនឹងការរីករាលដាលនៃឯកសារអាសអាភាសពិសេសកើតឡើងក្នុងចំណោមកុមារ និងក្មេងជំទង់ ។ អង្គការលីកាដូក៏បានបញ្ជាក់បន្ថែមទៀតផងដែរថាមានការកើនឡើងនូវទំនោរដែលក្មេងប្រុសជំទង់ៗជាច្រើនចូលរួមក្នុងក្រុមបងធំ និងយកតម្រាប់តាមក្រុមបងធំនោះ ។

តុលាការជាធម្មតាអនុវត្តចំពោះក្រុមបងធំនេះយ៉ាងតឹងតែងជាទីបំផុត ប៉ុន្តែការយកចិត្តទុកដាក់អំពីផ្លូវច្បាប់ចំពោះបទល្មើសនេះអាចរារាំង ដោយសារតែសក្តានុពលក្នុងការរកប្រាក់ចំណូលបានខ្ពស់តាមរយៈការស៊ីសំណូក ។ បញ្ហានេះនឹងលើកយកមកពិភាក្សាលំអិត នៅផ្នែកបន្ទាប់ក្នុងរបាយការណ៍នេះ ។

**តារាងទី ៣ ការស៊ើបអង្កេតករណីរំលោភជាក្រុមក្នុងឆ្នាំ ២០០២-២០០៣ ។**

| កាលបរិច្ឆេទ | ករណីរំលោភជាក្រុម | ការផ្តន្ទាទោស |
|---|---|---|
| ២០០២ | ៨ | ១ |
| ២០០៣ | ១១ | ១ (១ កំពុងដំណើរការ) |

ប្រភព: រំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ *(របាយការណ៍សង្ខេបលីកាដូ ភ្នំពេញខែមិនា ឆ្នាំ២០០៤)*

## ជនល្មើស (ចារីជន)

ជនល្មើសដែលជាជនពេញវ័យ មានចេញមកពីក្រុមមនុស្សគ្រប់មុខងារនិងឋានៈនៃសង្គមទាំងអស់ ។ ប៉ុន្តែអង្គការលីកាដូបានកត់សំគាល់ឃើញមានក្រុមមួយចំនួន ដែលបង្ហាញតួលេខក្នុងការប្រព្រឹត្តិអំពើរំលោភ

[20] រំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ (របាយការណ៍សង្ខេបលីកាដូ ភ្នំពេញ ខែមិនា ឆ្នាំ២០០៤) ។

សេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ជាងគេនៅក្នុងស្ថិតិ[21] ។ ក្រុមទាំងនោះ គឺកសិករ និងអ្នកនេសាទដែលតាមស្ថិតិសង្កេតឃើញថាបានប្រព្រឹត្តបទល្មើសនេះក្នុងកំរិតខ្ពស់ជាងគេ ដែលគិតជាភាគរយមាន ២៩.៥% ក្នុងចំណោមជនជាប់ចោទទាំងអស់ ។ ចំនួនហាក់ដូចជាសមហេតុផលដែរ បើប្រៀបទៅនឹងចំនួនបុរសយ៉ាងច្រើនដែលប្រកបរបរក្នុងវិស័យទាំងនេះ ហើយអាចទាក់ទងទៅនឹងភាពក្រីក្រនៅតាមជនបទផងដែរ ។ ក្រុមទី២ អាចជាក្រុមមន្ត្រីរាជការដែលមាន ២៨% ។ មុននឹងធ្វើការកែទំរង់ច្បាប់នៅក្នុងឆ្នាំ២០០១ មន្ត្រីរាជការដែលត្រូវបានចោទប្រកាន់ពីបទល្មើសប្រភេទនេះមិនត្រូវបានចាប់ខ្លួន ហើយពុំមានការឯកភាពពីនាយកដ្ឋាន ឬក្រសួងទេ ហើយបញ្ហានេះបាននាំអោយមាននិទ្ទណ្ឌភាពក្នុងចំណោមមន្ត្រីរាជការ ។ បច្ចុប្បន្ននីតិវិធីនេះត្រូវបានផ្លាស់ប្តូរ ហើយនាយកដ្ឋាន ឬក្រសួងដែលពាក់ព័ន្ធនឹងជនជាប់ចោទនោះច្បាប់គ្រាន់តែតំរូវអោយជូនដំណឹងបីថ្ងៃមុនពេលចាប់ខ្លួនជនល្មើសតែប៉ុណ្ណោះ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីរយៈពេលខាងលើនេះបានទុកពេលគ្រប់គ្រាន់អោយជនល្មើសគេចខ្លួនពីការចាប់ខ្លួនដោយអាជ្ញាធរ ។ ក្រុមទី៣ ដែលមានស្ថិតិក្នុងការប្រព្រឹត្តិបទល្មើសខ្ពស់ដែរ គឺសិស្ស-និស្សិតដែលមាន ១៤% ។ "សិស្ស" ពុំមានក្រុមពិតប្រាកដទេ ដោយរួមមានគ្រប់កំរិតសិក្សាទាំងអស់ចាប់តាំងពីបឋមសិក្សារហូតដល់កំរិតឧត្តមសិក្សា ។ ក្រុមសិស្សដែលគួសបញ្ជាក់ថាត្រូវបានចោទប្រកាន់ច្រើនជាងគេ ព្រមទាំងជានិន្នាការមួយដែលគួរអោយព្រួយបារម្ភផងនៅកម្ពុជា គឺសិស្សដែលមានអាយុក្រោម ១៨ឆ្នាំ ។ អង្គការលីកាដូបានរាយការណ៍ថា មានកុមារាមានអាយុក្រោម ១៦ឆ្នាំ មានដល់ទៅចំនួន ៧% ។ ក្នុងចំណោមជនសង្ស័យនៃករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ទាំងអស់[22] ។

## ឧបសគ្គនានានៅក្នុងប្រព័ន្ធយុត្តាធិការ

ដំណើរការក្នុងការនាំខ្លួនជនសង្ស័យយកទៅផ្តន្ទាទោស គឺពោរពេញទៅដោយអំពើពុករលួយ ជនរងគ្រោះទទួលរងការឈឺចាប់ គ្រោះថ្នាក់ និងការចំណាយថវិកា ។ ប្រព័ន្ធតុលាការហាក់ដូចជាដាក់បន្ទុកហួសហេតុទៅលើភស្តុតាងដែលបន្សល់លើរាងកាយក្នុងករណីរំលោភសេពសន្ថវៈ ។ នៅក្នុងឱកាសជាញឹកញាប់គេសង្កេតឃើញថា ជនរងគ្រោះបំផ្លាញភស្តុតាង ដោយស្ថានភាពអាម៉ាស់ ឬលាក់ករណីនោះមិនព្រមរាយការណ៍ ដែលបណ្តាលអោយស្លាកស្នាមពិតៗដែលកើតឡើងពីការរំលោភត្រូវរលុបបាត់អស់ ។ លិខិតកោសល្យវិច្ច័យត្រូវបានចាត់ទុកថាជាភស្តុតាងដ៏សំខាន់បំផុតនៅក្នុងតុលាការ ប៉ុន្តែវេជ្ជបណ្ឌិតមួយចំនួននៅមានការយល់ដឹងកំរិតទាបនៅឡើយអំពីបញ្ហាការពិនិត្យធ្វើកោសល្យវិច្ច័យជូនជនរងគ្រោះនេះ ជាពិសេសក្នុងករណី ដែលពេលវេលាបានកន្លងផុតឆ្ងាយពីគ្រារវាងបទល្មើស និងការពិនិត្យធ្វើកោសល្យវិច្ច័យ

[21] រំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ : បទឧក្រិដ្ឋនៅក្នុងសហគមន៍ (Diane O' connel) របាយការណ៍ពិសេសរបស់លីកាដូ ខែកុម្ភៈ ឆ្នាំ២០០១) ទំ. ៥៤ ។

[22] ឯកសារដូចខាងលើ ទំ. ១២ ។

នោះ[23] ។ វេជ្ជបណ្ឌិតទារថ្លៃឈ្នួលធ្វើកោសល្យវិច្ច័យនោះផងដែរ ដែលស្ត្រីភាគច្រើនមិនមានលទ្ធភាពចំណាយក្នុងការធ្វើលិខិតពេទ្យមួយនេះបានទេ[24] ។ បន្ថែមពីលើនេះទៀត គឺស្ត្រីក៏ត្រូវសូកនគរបាល ដើម្បីអោយមានការស៊ើបអង្កេតនៅកន្លែងកើតហេតុដំបូង ។

គេបានមានជំនឿជាទូទៅថា នៅក្នុងប្រព័ន្ធតុលាការទាល់តែមានភស្តុតាង ដូចជា ចេញទឹកកាម ការប្រវាយប្រតប់គ្នា ការរំលោភដល់ទីជំរៅ និងស្នាមរហែកព្រហ្មចារីទើបចាត់ទុកថាមានអំពើរំលោភសេពសន្ថវៈកើតឡើង ។ ជំនឿខុសទំនងនេះ គឺជាការល្មើសទៅនឹងនិយមន័យនៃពាក្យរំលោភសេពសន្ថវៈនៅក្នុងមាត្រា៥ យ៉ាងច្បាស់ក្រឡែត ហើយពុំមានការទទួលខុសត្រូវដល់ការឈឺចាប់ជាច្រើនប្រភេទ ដែលកើតមានលើជនរងគ្រោះក្នុងករណីរំលោភសេពសន្ថវៈនេះ ។ ជាលទ្ធផលនៃទស្សនៈយល់ច្រឡំនេះ ទើបករណីរំលោភជាច្រើនត្រូវបានបន្ធូបន្ថយ ផ្លាស់ប្តូរបទចោទប្រកាន់ទៅជាករណីបៀតបៀនកេរ្តិ៍ខ្មាស់ទៅវិញ ។ ដូច្នេះ តំរូវការជាចាំបាច់បំផុតក្នុងការអប់រំ និងការកែទំរង់ច្បាប់ រួមទាំងប្រព័ន្ធយុត្តាធិការអំពីបញ្ហាករណីរំលោភសេពសន្ថវៈ និងករណីរំលោភផ្លូវភេទនានា។

## ដំណោះស្រាយក្រៅច្បាប់

យើងសង្កេតឃើញថាមានភាពខុសគ្នាផ្នែកច្បាប់យ៉ាងច្បាស់រវាងករណីរដ្ឋប្បវេណី និងករណីព្រហ្មទណ្ឌក្នុងប្រព័ន្ធតុលាការកម្ពុជា ។ ការទទួលយកសំណងរដ្ឋប្បវេណីនៅពេលដែលនីតិវិធីព្រហ្មទណ្ឌបានចាប់ផ្តើមនោះគឺជាអំពើខុសច្បាប់ ។ ក្នុងការអនុវត្តន៏ជាក់ស្តែងជនរងគ្រោះភាគច្រើនទទួលយកដំណោះស្រាយតាមរយៈការសងជំងឺចិត្តនៅគ្រប់កំរិតនៃការស៊ើបអង្កេតទាំងអស់ ហើយមន្ត្រីរដ្ឋាភិបាលជាច្រើនមានការពាក់ព័ន្ធដោយជៀសមិនផុតនៅក្នុងដំណើរការនៃការសម្របសម្រួលដោះស្រាយការសងជំងឺចិត្ត ។ អង្គការជំនួយផ្នែកច្បាប់កម្ពុជា (LAC) បានរាយការណ៏ថាពី ៦០%-៧០%នៃករណីរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ ដែលបានរាយការណ៏ត្រូវបានដោះស្រាយខាងក្រៅតុលាការ ។ ជនរងគ្រោះច្រើនតែជាពលរដ្ឋក្រីក្រ និងមានភាពតក់ស្លុតដោយសារការជួបប្រទះនូវរឿងដ៏អាក្រក់ (ពុំមែនជួបការលំបាកតែបទឧក្រិដ្ឋទេ ប៉ុន្តែអាចឧបសគ្គផ្នែកច្បាប់ទៀតផង) ហេតុដូច្នេះការមើលឃើញថាសំណងជំងឺចិត្ត គឺជាវិធីដោះស្រាយសមរម្យនឹងពេញចិត្ត ដើម្បីបញ្ចប់រឿងរ៉ាវ[25] ។ ប៉ុន្តែមានករណីជាច្រើនការដោះស្រាយក្រៅ

---

[23] មានករណីខ្លះ វេជ្ជបណ្ឌិតក៏ត្រូវទទួលរងការបំភិតបំភ័យឹងគំរាមកំហែង ដើម្បីកុំអោយផ្តល់លិខិតកោសល្យវិច្ច័យដល់ជនរងគ្រោះ ។ សូមអានឯកសារស្តីពីរំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ : បទឧក្រិដ្ឋនៅក្នុងសហគម (Diane O'connel) របាយការណ៏ពិសេសរបស់លីកាដូ ខែកុម្ភៈ ឆ្នាំ២០០១ ) ទំ. ៥៤ ។

[24] នៅក្នុងឆ្នាំ ២០០២ មានតែជនរងគ្រោះ ១១% ប៉ុណ្ណោះដែលអាចទទួលលិខិតកោសល្យវិច្ច័យបាន "រំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ ភ្នំពេញ ខែមិនា ឆ្នាំ២០០៤ ) ទំ. ៦ ។

[25] ចំនួនទឹកប្រាក់សំរាប់ដំណោះស្រាយក្រៅតុលាការប្រែប្រួល ប៉ុន្តែជាធម្មតារវាងពី ១០០-២០០ដុល្លា ។

តុលាការពីមុនមកជាប្រការគួរអោយភ័យ និងខ្លាចខ្លាំងណាស់ ។ ជនរងគ្រោះអាចត្រូវបានជំរុញអោយឈប់ប្តឹងដោយជនល្មើស ឬដោយប្រជាជននៅក្នុងភូមិឃុំ ។ ជនរងគ្រោះក៏អាចត្រូវបានគាបសង្កត់អោយសុខចិត្តទទួលយកដំណោះស្រាយក្រៅតុលាការដោយមន្ត្រីផ្នែកច្បាប់ ដូចជា ក្រឡាបញ្ជីដែលសង្ឃឹមថានឹងបានកំរៃពីការជួយសម្រុះសម្រួលក្នុងការដោះស្រាយនោះ ។ ដំណោះស្រាយ ដ៏សែនឈឺចាប់ជាទីបំផុតក្នុងឆាកជីវិត គឺជនរងគ្រោះត្រូវបានជុំរុញអោយរៀបអាពាហ៍ពិពាហ៍ជាមួយនឹងជនល្មើសជំនួសអោយការប្តឹងផ្តល់ ឬការដោះស្រាយដោយសងជំងឺចិត្តជាលុយកាក់វិញ ។ ហេតុនេះវាមិនអាចមានភាពត្រឹមត្រូវស្របតាមមាត្រាច្បាប់សំរាប់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ និងរំលោភផ្លូវភេទទេ ។

## ការទទួលខុសត្រូវចំពោះចំនួនករណីរំលោភកើនឡើងដែលបានរាយការណ៍

នៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ និងរដ្ឋាភិបាលមានការយល់ស្របគ្នា ដែលចំនួនករណីរាយការណ៍កំពុងកើនឡើង ។ នៅឆ្នាំ ២០០១ ករណីដែលបានរាយការណ៍មកលីកាដូត្រឹមតែ ១៤៦ ករណីតែប៉ុណ្ណោះ ។ នៅឆ្នាំ ២០០៣ ចំនួននេះបានកើនឡើងរហូតដល់ ១៧៧ ករណី ។ ប៉ុន្តែយើងក៏នៅមិនទាន់ដឹងថាតើការកើននេះវាជាការបង្ហាញនូវសុឆន្ទៈក្នុងការរាយការណ៍របស់ជនរងគ្រោះ អំពីករណីរំលោភនេះ ឬក៏ករណីរំលោភមានការកើនឡើងនៅទូទាំងប្រទេស ។ នៅពេលដែលគេលើកយកពាក្យនេះទៅសួរនាយិការ ប្រធានមជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) នឹងចោទសួរនាយកអង្គការសេវាអភិវឌ្ឍន៍សង្គមកម្ពុជា គ្មាននាយក-នាយិកាណាម្នាក់អាចកំណត់នូវហេតុផលនៃមូលហេតុអោយបានច្បាស់ចំពោះការកើនឡើងនូវចំនួនករណីរំលោភដែលបានរាយការណ៏នេះទេ[26] ។

ការស្រាវជ្រាវមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) នៅឆ្នាំ២០០២ បានសន្និដ្ឋានថា វាមានមូលហេតុដែលទាក់ទងគ្នាយ៉ាងខ្លាំងរវាងចំនួនអាជីវកម្មវីដេអូ ដែលនាំអោយគ្រោះថ្នាក់ ដូចជា ការបញ្ចាំងរឿងអាសអាភាសជាមួយនឹងការកើនឡើងនូវចំនួនករណីរំលោភសេពសន្ថវៈ[27] ។ មូលហេតុមួយទៀតដែលអាចនាំអោយមានការកើនឡើងនូវចំនួនករណីនេះផងដែរ គឺថាបទល្មើសប្រភេទនេះភាគច្រើន ជាករណីដែលល្បីៗ គឺជករណីរំលោភ ហើយសំលាប់អនិតិជនក៏ជាករណី ដែលនៅតែមិនទាន់ដោះស្រាយបាននៅឡើយ ។ បញ្ហានេះអាចនាំអោយកើតមាននិទ្ទណ្ឌភាពក្នុងចំណោមជនល្មើសមួយចំនួន ហើយថែមទាំងអាចជំរុញអោយមានការប្រព្រឹត្តិល្មើសថែមទៀត ។ បញ្ហានិទ្ទណ្ឌភាពនេះចេះតែបន្តមានឥតឈប់ឈរ ដោយសារតែគេបានពង្រឹងនូវជំនឿទស្សនៈមួយ ដែលនិយាយថា *ជនរងគ្រោះអាចសងជាប្រាក់កាសបានយ៉ាងងាយ* ។ អង្គការលីកាដូបានគូសបញ្ជាក់បន្ថែមទៀតអំពី

[26] បទឧក្រិដ្ឋដែលមិនអាចនិយាយបាន-កាសែតឌឹឃែមបូឌាដេលីចេញផ្សាយថ្ងៃទី១៣-១៤ ខែមិនា ឆ្នាំ២០០៤ ទំ. ៨-៩-១៥ ។
[27] មជ្ឈមណ្ឌល ដើម្បីជួយស្ត្រីមានវិបត្តិ-របាយការណ៏ប្រចាំឆ្នាំមករា-ធ្នូ ២០០២) ទំ. ៨ ។

មូលហេតុដែលចេះតែរីកធំឡើងៗនូវអំពើរំលោភនៅកម្ពុជា ដូចជាកំណើនការប្រើប្រាស់គ្រឿងញៀនសំរាប់រួមភេទ (គ្រឿងញៀនសំរាប់ធ្វើអោយមានសំរើប) ព្រមទាំងជំនឿនៅអាស៊ី ដែលជឿថាការបានរួមភេទជាមួយស្ត្រីនៅព្រហ្មចារីនឹងធ្វើអោយមានកំលាំងខាងផ្លូវភេទកាន់តែខ្លាំងឡើង ។ ជាការឆ្លើយតបទៅនឹងកំណើនការរីករាលដាលនៃមេរោគអេដស៍ បុរសច្រើនតែចូលចិត្តរួមភេទជាមួយនឹងកុមារីក្មេងៗ ហើយគេយល់ថាមិនសូវមានគ្រោះថ្នាក់ក្នុងការឆ្លងជំងឺ ។ មានពេលខ្លះស្ត្រីជាភរិយាមួយចំនួនបានជួយប្តីរបស់ខ្លួនអោយប្រព្រឹត្តល្មើសជាមួយស្ត្រីវ័យក្មេងទៀតផង ដោយគេយល់ថា ការធ្វើបែបនេះវាប្រសើរជាងការទុកអោយប្តីទៅរួមរ័ក្សជាមួយនឹងស្រីកំណាន់ ឬស្ត្រីរកស៊ីផ្លូវភេទដោយក្បត់ចិត្តលួចលាក់។ ច្បាស់ណាស់ដែលការសិក្សាស្រាវបន្តទៀតត្រូវការចាំបាច់ជាបន្ទាន់ ដើម្បីកំណត់អោយឃើញថា ហេតុអ្វីបានជាករណីរំលោភសេពសន្ថវៈមានការកើនឡើងក្នុងក៏រិតជាសមាមាត្រមួយ។ ជាពិសេស អង្គការលីកាដូ បានធ្វើការអប់រំលើកកំពស់ការយល់ដឹងអំពីការកើនឡើងនូវបញ្ហារំលោភសេពសន្ថវៈនៅក្នុងសង្គមកម្ពុជា ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏យើងនៅតែត្រូវមានការសិក្សាស្រាវជ្រាវថែមទៀត ។ ការយល់ដឹងអំពីឫសគល់របស់បញ្ហាអោយបានកាន់តែស៊ីជំរៅនឹងអាចធ្វើអោយសង្គមអង្គការមិនមែនរដ្ឋាភិបាលនានាព្រមទាំងរដ្ឋាភិបាលរួមទប់ស្កាត់ទៅនឹងបញ្ហាអោយកាន់តែទូលំទូលាយឡើង ។

## ការស្តារនីតិសម្បទារសំរាប់ជនរងគ្រោះ

អង្គការមួយចំនួនគ្រប់គ្រងគំរោងស្តារនិតិសម្បទារ និងមជ្ឈមណ្ឌលសំរាប់ជនរងគ្រោះដោយអំពើរំលោភផ្លូវភេទ[28] ។ មានបញ្ហាអតុល្យភាពមួយដែលត្រូវដោះស្រាយ គឺការផ្តល់អោយមានមជ្ឈមណ្ឌលអោយកាន់តែច្រើនកន្លែងនៅតាមបណ្តាខេត្ត ដូចជានៅខាងក្រៅទីក្រុងភ្នំពេញជាដើម ។ មានបញ្ហាមួយទៀត គឺការផ្គត់ផ្គង់ដែលមានស្រាប់ ហើយសព្វថ្ងៃភាគច្រើនគេទទួលជួយជនរងគ្រោះ ដោយហេតុផលខាងអាជីវកម្មផ្លូវភេទ និងជនរងគ្រោះដោយសារអំពើហិង្សាខាងផ្លូវភេទ រីឯជនរងគ្រោះនៅក្រៅបញ្ហាទាំងនេះមិនបានទទួលសេវាបំរើដែលពួកគេត្រូវការទេ ។ ក្នុងចំណោមបញ្ហាជាកង្វល់ធំៗផ្សេងទៀត គឺត្រូវការអោយមានអ្នកចិត្តសាស្ត្រ ដែលមានការហ្វឹកហ្វឺនបានត្រឹមត្រូវ អ្នកចិត្តសាស្ត្រ និងអ្នកពិគ្រោះប្រឹក្សាបញ្ហា ដើម្បីជួយជនរងគ្រោះ ។ អង្គការលីកាដូ បានអនុវត្តវិធីមួយចំនួន ដើម្បីដោះស្រាយបញ្ហានេះនៅក្នុងការិយាល័យកម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម ។ លីកាដូ ទទួលស្គាល់ថា "ការរំលោភសេពសន្ថវៈ គឺមានភាពស្និតទៅនឹងអំពើទារុណកម្មជាងបញ្ហាផ្លូវភេទ" ។ អង្គការនេះក៏បានធ្វើអោយមានគំរោងថែទាំ ដែលសំដៅដោះស្រាយការភ័យខ្លាចផ្នែកផ្លូវចិត្តរយៈពេលវែងដែលជនរងគ្រោះបានទទួល

[28] ការងារក្នុងវិស័យនេះ ត្រូវបានអនុវត្តដោយអង្គការទស្សនៈពិភពលោក (World Vision, LICADHO, CWCC, AFESIP, និង YWCC) ។

រងផលវិបាក ។ គំរោងនេះក៏បានផ្តោត ទៅលើកុមាររងគ្រោះផងដែរក្នុងគោលដៅ ដើម្បីបញ្ចៀសចេញពីផ្លូវគ្រោះថ្នាក់នៃការទទួលរងអំពើរំលោភក្លាយទៅជាអ្នករំលោភគេវិញនៅពេលអនាគត ។

## អំពើហិង្សាផ្នែកយេនឌ័រ

អំពើហិង្សាដែលប្រព្រឹត្តលើស្ត្រី និងកុមារទាំងក្នុងករណីគ្រួសារ និងក្នុងសង្គម គឺជាការកើតឡើងយ៉ាងឥតអៀនខ្មាស់ និងជារឿងធម្មតានៅកម្ពុជា ។ ដើមកំណើតនៃការប្រព្រឹត្តអំពើអាក្រក់មកលើស្ត្រីនេះអាចត្រូវបានដក់ស្មាមជាមួយនឹងទំលាប់វប្បធម៌ ដែលហ៊ុំព័ទ្ធតួនាទីរបស់ស្ត្រីជាអ្នកជំនួយការចំពោះបុរស ។ អំពើហិង្សាកាលពីមុនមកលើស្ត្រីក៏ត្រូវអាចរកឃើញនៅក្នុងវប្បធម៌ហិង្សា និងភាពឥតច្បាប់ទំលាប់ដែលកើតមានក្នុងសម័យខ្មែរក្រហម និងសម័យសង្គ្រាមក្នុងស្រុក ។ អំពើហិង្សាដែលចេះតែកើតមានដដែល១តាំងពីដើមមក គឺជាការផ្ទុយស្រឡះទៅនឹងប្រជាជាតិមួយ ដែលភាគច្រើនគោរពព្រះពុទ្ធសាសនាយ៉ាងលើសលុប ប៉ុន្តែអំពើហិង្សានេះអាចមើលឃើញដោយការបង្ហាញភ្លាម១តាមរយៈវត្តមាននៃអាវុធយុទ្ធភ័ណ្ឌ និងកាំភ្លើងខ្លីដែលមានស្រាប់ ។ ថ្វីត្បិតតែមានការរួមកំលាំងគ្នាព្រមទាំងកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លាដោយអង្គការមិនមែនរដ្ឋាភិបាល ដូចជាក្រុមការងារកាត់បន្ថយអាវុធក៏នៅតែមានអាវុធប្រល័យជីវិតប្រើផ្ទាល់ខ្លួនយ៉ាងច្រើននៅកម្ពុជា ។

## ការវាយប្រហារដោយទឹកអាស៊ីត

នៅខែធ្នូ ឆ្នាំ១៩៩៩ អ្នកចំរៀងដ៏ល្បីល្បាញម្នាក់ឈ្មោះ *តាត ម៉ារីណា* ត្រូវបានរំលោភបំពានរាងកាយដោយមនុស្សបីនាក់ចាក់ស្រោចជះទឹកអាស៊ីត បណ្តាលអោយខូចរូបរាងនាងជារៀងរហូត ។ ជនសង្ស័យ គឺជាភរិយារបស់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ម្នាក់ (និងកងការពារ២នាក់ទៀត) ។ មនុស្សទាំងនោះមិនទាន់ត្រូវបានចាប់ខ្លួនទេ ។ ករណីនេះបានធ្វើអោយមានការយកចិត្តទុកដាក់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិនានាចំពោះបាតុភូតនៃការវាយប្រហារដោយទឹកអាស៊ីតដ៏ច្រើនហួសហេតុនៅកម្ពុជា ព្រមទាំងនិទ្ទណ្ឌភាព ដែលជនល្មើសទទួលបានក្នុងកាលៈទេសៈពិសេសខ្លះនោះ ។

អង្គការលីកាដូបានធ្វើការកត់ត្រាករណីវាយប្រហារទឹកអាស៊ីតចំនួន ៤៤ ករណីពីឆ្នាំ ១៩៩៩ មកដល់ឆ្នាំ២០០២ កន្លងទៅនេះ ដែលគិតជាមធ្យមក្នុងរយៈពេល ២៥ថ្ងៃ មានករណីវាយប្រហារទឹកអាស៊ីត

មួយកើតឡើង[29] ។ ករណីវាយប្រហារដោយទឹកអាស៊ីតបានបណ្តាលអោយមនុស្ស ៦០ នាក់រងរបួស និង ៣ នាក់ទៀតបានស្លាប់ ។ មនុស្ស ១៨នាក់រងរបួសដោយគ្រោះថ្នាក់ចៃដន្យនោះគឺមានន័យថា ពួកគេនៅក្បែរមនុស្សដែលគេមានបំណងជះទឹកអាស៊ីតមកលើ ។ ករណីសោកនាដកម្មមួយ គឺស្ត្រីម្នាក់បានវាយប្រហារទៅចំលើកូនប្រុសរបស់ខ្លួន ដែលមានអាយុ ៥ឆ្នាំពីព្រោះកូននោះបានឈរនៅជិតជនដែលជាគោលដៅវាយប្រហារមកលើប្តីរបស់ស្ត្រីនោះ[30] ។ ក្នុងចំណោមជនរងគ្រោះរលាកពីការវាយប្រហារដោយទឹកអាស៊ីតទាំងនោះមានបុរស ៣០នាក់ និងស្ត្រី ៣១នាក់ ។ វាហាក់ដូចជាមិនឆ្លាតទេក្នុងការកំណត់នូវទំនោរដ៏ពិបាក នឹងលឿនពេកនៅក្នុងករណីមួយចំនួនតូច ។ ប៉ុន្តែ លីកាដូអាចនិយាយបានថា ករណីវាយប្រហារដោយទឹកអាស៊ីតភាគច្រើនដែលប្រព្រឹត្តដោយស្ត្រី គឺសំដៅទៅលើស្វាមីដែលរំលោភបំពានមកលើនាង ឬសំដៅទៅលើស្ត្រីកំណាន់ចិត្ត ឬប្រពន្ធថ្មីរបស់នៃស្វាមីបច្ចុប្បន្ន ឬពីអតីតកាល ។ បុរសដែលវាយប្រហារដោយទឹកអាស៊ីតលើស្ត្រី គឺធ្វើឡើងដោយសារតែមានចិត្តច្រណែនប្រច័ណ្ឌ និងការបោះបង់ចោលដោយជនរងគ្រោះ ។ តើឥទ្ធិពលអ្វីដែលនាំអោយការរំលោភដោយអាស៊ីតសាហាវយ៉ាងនេះ "ជនល្មើសជាធម្មតាមិនចង់សំលាប់ជនរងគ្រោះទេ ប៉ុន្តែចង់ធ្វើអ្វីមួយអោយអាក្រក់លើសការសំលាប់នេះទៅទៀត ដូចជាធ្វើអោយជនរងគ្រោះវេទនាអស់មួយជីវិតជាដើម ។" អាស៊ីតជាធម្មតាគេជះសំដៅទៅលើមុខជនរងគ្រោះ ។ ជនល្មើសចង់បំផ្លាញមុខនឹងធ្វើអោយជនរងគ្រោះមានមុខមាត់មើលដូចជាបីសាច ដូច្នេះគ្មាននរណាស្រឡាញ់ជនរងគ្រោះទៀតទេ "[31] ។

ជនរងគ្រោះដោយសារការរលាកទឹកអាស៊ីត កម្រនឹងមានអ្នកណាម្នាក់បានទទួលការព្យាបាលថែរក្សាអោយបានសមរម្យណាស់ (ទាំងផ្នែករាងកាយ និងផ្លូវចិត្ត) នូវលើមុខរបួសរបស់ពួកគេ ។ ប្រៀបធៀបទៅនឹងបទល្មើសហិង្សាផ្សេងៗទៀត អត្រានៃការចាប់ជនល្មើស គឺខ្ពស់សមរម្យ ១៣ករណីត្រូវចាប់ក្នុងចំណោម ៤៤ ករណីដែលបានស៊ើបអង្កេត ។ ប៉ុន្តែការផ្តន្ទាទោសដល់ករណីជះទឹកអាស៊ីតមិនដូចគ្នាទេ ដោយហេតុថាករណីនេះមិនទាន់ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់កម្ពុជានៅឡើយ ។ ឃែមបូវបានបញ្ចុះបញ្ចូលអោយដាក់បញ្ចូលទៅក្នុងពង្រាងច្បាប់ថ្មី ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនឹងជួយជនរងគ្រោះ ដែលសព្វថ្ងៃនៅកំពុងរង់ចាំរដ្ឋសភា ហើយក្រោយរុញត្រឡប់មកសាម៉ីក្រសួងវិញទើបធ្វើការអនុម័តជាក្រោយ ។

[29] ចំនួនសរុបករណីជះទឹកអាស៊ីតទំនងជាខ្ពស់ជាងនេះច្រើនណាស់ ប៉ុន្តែករណីមួយចំនួនពុំមានការរាយការណ៍ទេ អាស្រ័យដោយពុំមានជំនឿក្នុងប្រព័ន្ធច្បាប់ ការបំភិតបំភ័យ និងដោយជនរងគ្រោះខ្វះការយល់ដឹងអំពីសិទ្ធិរបស់ខ្លួន ។ សូមអានរបាយការណ៍ រស់នៅក្នុងភពអន្ធការ: ការវាយប្រហារដោយទឹកអាស៊ីតនៅកម្ពុជា (កម្មវិធីប្រឆាំងនឹងអំពើទារុណ្ណកម្ម លីកាដូ ឆ្នាំ២០០៣) ទំ.២ ។

[30] ប្រភពឯកសារដដែលដូចខាងលើ ទំ. ៧ ។

[31] ប្រភពឯកសារដដែល ទំ. ១ ។

# ការងារដោយបង្ខំលើស្ត្រី និងកុមារ

ការអោយនិយមន័យនៃពាក្យ "ការងារដោយបង្ខិតបង្ខំ" ជាការពិតគឺមានការលំបាកស្មុគស្មាញណាស់ ប្រសិនបើស្ត្រី ឬកុមារម្នាក់ចូលបំរើការងារណាមួយ ជាពិសេសការកេងប្រវ័ញ្ចនៅវិស័យអាជីវកម្មផ្លូវភេទ ឬបំរើតាមគេហដ្ឋាន ដោយសារភាពក្រីក្រ ការជំពាក់បំណុល និងកង្វះការអប់រំ តើពួកគេទាំងនោះត្រូវបាន "បង្ខិតបង្ខំ" ដែរឬទេ? បញ្ហាទាំងនេះនឹងត្រូវបានដោះស្រាយយ៉ាងទូលំទូលាយនៅក្នុងផ្នែកជាបន្តបន្ទាប់មកទៀតនេះ ។ ដើម្បីបញ្ជាក់អោយខ្លី ហើយកាន់តែច្បាស់ណាស់យោងតាមអនុសញ្ញារបស់អង្គការការងារអន្តរជាតិ (ILO) អនុសញ្ញាលេខ ២៩ ដែលហាមឃាត់ ការងារដោយបង្ខិតបង្ខំនឹងពាក់ព័ន្ធទៅ និងចំណងបំណុលត្រូវបានលើកយកប្រើជាការកំណត់និយមន័យ ។

អង្គការលីកាដូ និងវិទ្យាស្ថានការងារសេរីអាស៊ីអាមេរិក (AAFLI) បានធ្វើការទាក់ទាញឱ្យមានការយកចិត្តទុកដាក់ទៅលើលក្ខខណ្ឌដ៏គួរអោយភ័យខ្លាច ដែលកុមារអាយុក្រោម ១៥ឆ្នាំស៊ូទ្រាំធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ ចំការផលិតផលកសិកម្ម និងក្នុងវិស័យសំណង់ហេដ្ឋារចនាសម្ព័ន្ធនានា[32] ។

នៅក្នុងបរិយាកាសបែបនេះ គឺស្ថិតក្នុងសភាពមានគ្រោះថ្នាក់ខ្ពស់បំផុតដោយសារគ្រឿងម៉ាស៊ីន ហើយកម្រមានឱកាសទៅរៀននៅសាលាណាស់ ។ ការងារលើសម៉ោង និងការងារដ៏យ៉ាប់យឺននេះមិនសមផ្តល់ឱ្យពួកគេនូវប្រាក់ឈ្នួលដ៏តិចតួចបានត្រឹមតែ ៥ដុល្លាក្នុងមួយខែប៉ុណ្ណោះទេ ។ ក្នុងកាលៈទេសៈខ្លះកុមារធ្វើការជាមួយនឹងឪពុក-ម្តាយរបស់ពួកគេ ហេតុដូច្នេះប្រាក់ឈ្នួលរបស់ពួកគេត្រូវសរុបជាមួយប្រាក់ឈ្នួលប្រចាំខែរបស់ឪពុកម្តាយទាំងអស់ ។ ស្ថានភាពការងារនៅក្នុងវិស័យសេវាកម្មក៏ធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាដែរ ដែលមានថៅកែភោជនីយដ្ឋាន និងហាងលក់ស្រាផឹកកំសាន្ត (Bar) ចូលចិត្តនារីជំទង់ៗ ពីព្រោះពួកគេមានឥរិយាបទមិនរឹងរូសជាមួយនឹងការកេងប្រវ័ញ្ចលើពលកម្មពួកគេ ។

អង្គការជាច្រើន ដូចជា លីកាដូ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត ព្រមទាំងអង្គការអន្តរជាតិនានាដែលជាអង្គការការពារកុមារកំពុងសិក្សាការស្រាវជ្រាវនឹងលើកស្ទួយការយល់ដឹងអំពីស្ថានភាពដ៏យ៉ាប់យ៉ឺននៃពលកម្មកុមារ ។ អង្គការនានាដែលកំពុងធ្វើការនៅប្រទេសឥណ្ឌាដែលបញ្ហាពលកម្មកុមារជាបញ្ហាដ៏ធំមួយនៅទីនោះ បានធ្វើជាការបង្ហាញបំភ្លឺផ្លូវមួយដល់ប្រទេសផ្សេងៗទៀតក្នុងការស្វែងរកដំណោះស្រាយបញ្ហានេះ ។ ដំណើរជាវិជ្ជមានមួយក្នុងការកាត់បន្ថយពលកម្មកុមារឥឡូវនេះកំពុងចាប់ផ្តើមលេចឡើងដោយមានការបង្កើតសម្ព័ន្ធភាពថ្នាក់តំបន់ និងអន្តរជាតិដែលអាចចែកចាយនូវបទពិសោធន៍

---

[32] សូមអាន ពលកម្មកុមារនៅកម្ពុជា (វិទ្យាស្ថានការងារសេរីអាស៊ី អាមេរិក និងលីកាដូ ខែកញ្ញា ឆ្នាំ១៩៩៦) -ស្ត្រីធ្វើការងារនៅកម្ពុជា ( Astrid Aafjes & Bana Athreya, LICADHO និងវិទ្យាស្ថានការងារសេរីអាស៊ីអាមេរិក ) ។

ប្រយុទ្ធប្រឆាំងនឹងបញ្ហាដោយផ្អែកលើ *"ការឆ្លងកាត់"* ព្រំដែន ។ វិធីសាស្ត្រក្នុងតំបន់មួយដែលឆ្លើយតបទៅនឹងបញ្ហានោះ គឺការបង្កាប់បញ្ហា ពីព្រោះថាពលករបង្ខិតបង្ខំមួយចំនួនធំត្រូវបានជួញដូរឆ្លងកាត់ព្រំដែនតាមបែបលក្ខណៈអន្តរជាតិ បញ្ហានេះយើងសូមលើកយកមកពិភាក្សាលំអិតថែមទៀតនៅក្នុងផ្នែកដែលពាក់ព័ន្ធទៅនឹងការជួញដូរស្ត្រី និងកុមារ ។

# ការសុំកូនចិញ្ចឹម

រាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានចុះហត្ថលេខានៅលើអនុសញ្ញាទីក្រុងឡាអេ ស្តីពីការសុំកូនពីប្រទេសមួយទៅប្រទេសមួយនៅឡើយទេ ហើយថែមទាំងមានច្បាប់ក្នុងស្រុករបស់ខ្លួនដ៏ទន់ខ្សោយនៅឡើយក្នុងកិច្ចការពារជនរងគ្រោះដោយបទល្មើសដែលពាក់ព័ន្ធនឹងការសុំកូនចិញ្ចឹមនេះ ។ អង្គការលីកាដូបានកំណត់ថាការសុំកូនខុសច្បាប់ជាសំខាន់ គឺគោលដៅនៃការសុំសំរាប់លើទីផ្សារក្នុងសហរដ្ឋអាមេរិកដែលវាជាបញ្ហាធ្ងន់ធ្ងរនឹងកំពុងតែរីកធំឡើង[33] ។ នៅឆ្នាំ២០០២ កម្ពុជាត្រូវបានអះអាងជាទូទៅថាមានការកើនឡើងនូវដំណើរការសុំកូនចិញ្ចឹមយ៉ាងលឿនក្នុងពិភពលោក (ពី៣-៤ខែ) ដែលបានបង្កើនសកម្មភាពទីផ្សារទិញដូរទារក និងការជួញដូរកុមារ ។

អ្នកសម្របសម្រួល (អ្នកដើររកក្មេង) ក្នុងការសុំកូនពីររូបបានដើរបោកបញ្ឆោតស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះ ដូចជាស្ត្រីទីទាល់ក្រ ស្ត្រីលែងលះគ្រួសារ និងស្ត្រីមេម៉ាយជាដើម ។ គេបានអោយអំណោយជាប្រាក់តិចតួច (រវាងពី ៣០ ទៅ ១០០ដុល្លា) ជាថ្នូរនឹងការអនុញ្ញាតអោយគេយកកូនទៅដាក់មណ្ឌលកុមារកុមារកំព្រា[34] ។ ប្រសិនបើ ពុំមានជំនួយផ្នែកច្បាប់ និងការជួយពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលនានាទេនោះ ពួកគេទាំងនោះទំនងជាមិនបានឃើញមុខកូនរបស់គេវិញឡើយ ។

នៅពេលដែលកុមារណាម្នាក់ត្រូវបានយកទៅដល់ផ្ទះល្វែងសុំកូនចិញ្ចឹមឯកជន កុមារទាំងនោះនឹងត្រូវចុះផ្សាយនៅក្នុងវិបសាយភាសាបរទេស (Website) ដើម្បីស្វែងរកអនាគតឪពុកម្តាយចិញ្ចឹមនៅលើពិភពលោក ។ ឯកសារផ្លូវការចាំបាច់សំរាប់ការសុំកូន គ្រាន់តែតំរូវអោយមន្ត្រីថ្នាក់ភូមិ/ឃុំឯកភាពថាកុមារពិតជាកំព្រាមែន ហើយមន្ត្រីថ្នាក់ក្រសួងគ្រាន់តែពិនិត្យមើលឯកសារបន្ថែមទៀតនឹងឯកភាពលើឯកសារនោះតែប៉ុណ្ណោះ ។ ដំណើរការរៀបចំឯកសារនោះពោរពេញទៅដោយអំពើពុករលួយ និងការសូក

[33] បទល្មើសទាក់ទងទៅនឹងដំណើរការសុំកូនចិញ្ចឹមអន្តរជាតិ នៅកម្ពុជា (របាយការណ៍សង្ខេបរបស់លីកាដូ ខែមករា ឆ្នាំ២០០២) ។

[34] អង្គការលីកាដូមិនអាចដឹងបានច្បាស់នូវស្ថានភាពរបស់ទារក និងកុមារដែលអាចត្រូវបានបំបែកចេញពីឪពុក-ម្តាយ របស់កុមារទាំងនោះ ហើយក្រោយមកត្រូវលក់ដូរអោយពួកអ្នកស្វែងរកសុំកូនចិញ្ចឹម ។

ប៉ាន់ ដែលកើតឡើងគ្រប់ដំណាក់កាល ប៉ុន្តែនៅក្នុងដំណើរការនៃការសុំកូននេះចិញ្ចឹមពុំបានទទួលស្គាល់ថាមានកើតអំពើបែបនេះទេ ។

ការទិញដូរទារក និងការសុំកូនខុសច្បាប់ពិបាកទប់ស្កាត់ណាស់ ពីព្រោះស្ត្រីពុំមានការយល់ដឹងអំពីសិទ្ធិរបស់ពួកគេរងគ្រោះដោយសារការបំភិតបំភ័យ ហើយពួកអ្នកដើរស្វែងរកទារកកុមារតូចៗនោះច្រើនតែអ្នកមានអំណាច និងមានទំនាក់ទំនងទៅនឹងមនុស្សដែលអាចគេចផុតពីការចោទប្រកាន់បាន ។ ចន្លោះពីឆ្នាំ២០០០-២០០២ អង្គការលីដូបានស៊ើបអង្កេតទៅលើមណ្ឌលកុមារឯកជនចំនួន៤កន្លែង ដែលបានជួយសម្របសម្រួលដល់ការសុំកូនជាមួយ នឹងភ្នាក់ងារសុំកូនអាមេរិក ។ ក្នុងចំណោមកុមារ ១៥នាក់ ដែលពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេតនោះកុមារចំនួន ១០នាក់ ត្រូវបានវិលត្រឡប់ទៅគ្រួសាររបស់គេវិញ ក្រោយពីអង្គការលីកាដូបានធ្វើការស៊ើបអង្កេតរួច ហើយមានកុមារ ៣នាក់ត្រូវបានសុំយកទៅសហរដ្ឋផុតស្រេចហើយ និង ២នាក់ ទៀតតាមរកមិនឃើញ ។ ទោះជាមានករណីជាក់ស្តែងបែបនេះក៏ដោយ នៅក្នុងករណីនោះ ក៏មានតែមនុស្ស ៧នាក់តែប៉ុណ្ណោះដែលត្រូវបានចោទប្រកាន់ជាផ្លូវការនៅក្នុងឆ្នាំ២០០២[35] ។ រាជរដ្ឋាភិបាលកម្ពុជាបានចេញនូវការហាមប្រាម ផ្អាកជាបន្ទាន់នានាមួយចំនួនស្តីពីការសុំកូនចិញ្ចឹមឆ្លងដែនទៅអន្តរជាតិ ដើម្បីជាការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍ជាសាធារណៈដ៏អាម៉ាស់ ហើយក៏បានផ្តល់សច្ចាប័នដល់អនុក្រឹត្យថ្មីមួយស្តីពីនីតិវិធីក្នុងការសុំកូននេះ ។ ប្រតិកម្មឆ្លើយតបក៏នៅតែមិនអាចកាត់បន្ថយនូវបទល្មើស ដែលរដ្ឋាភិបាលអន្តរជាតិបានស្តីបន្ទោសរួចមកហើយនោះដែរថាជាអំពើ "គួរអោយស្អប់ខ្ពើមជាទីបំផុត [36]" ។

ទំរង់សុំកូនចិញ្ចឹមដ៏យូរអង្វែងមួយនៅកម្ពុជាគឺប្រពៃណីសុំក្មេងពីគ្រួសារក្រីក្រ ជាធម្មតាច្រើនតែក្មេងស្រី ដើម្បីយកធ្វើជាអ្នកបំរើក្នុងគេហដ្ឋាន ។ គេបានផ្តល់ចំណីអាហារ និងសំលៀកបំពាក់ដល់កុមារ ហើយជាថ្នូរ "អាណាព្យាបាល" ច្រើនតែគិតថាគេមានអំណាចបញ្ជាអោយធ្វើអ្វីបានតាមចិត្ត ។ មានករណីជាច្រើនបញ្ហានេះបាននាំអោយមានលក្ខខណ្ឌដូចគ្នាទៅនឹងទាសករ ហើយកុមារក៏អាចទទួលរងគ្រោះយ៉ាងខ្លាំងដោយអំពើរំលោភលើរាងកាយ និងផ្លូវភេទ ។ អង្គការលីកាដូធ្លាប់បានសង្កេតឃើញរួចមកហើយថា ករណីទាំងនេះពិបាកក្នុងការស៊ើបអង្កេត និងជួយអន្តរាគមន៍ជាទីបំផុត ពីព្រោះយើងមិនអាចចូលជួបកុមារនៅក្នុងផ្ទះរបស់អាណាព្យាបាលបាន[37] ។ ករណីមួយក្នុងចំណោមករណីមួយចំនួន ដែលលីកាដូអាចស៊ើបអង្កេតបានក្នុងពេលថ្មីៗនេះ គឺជាករណីកុមារីម្នាក់ដែលមានអាយុ ៨ឆ្នាំ ត្រូវបានគេ

[35] ប្រភពឯកសារដដែល ទំ. ៣ ។

[36] ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា (Ken Whidemann) ដកស្រង់ចេញពី "ការរំលោភដែលទាក់ទងទៅនឹងដំណើរការសុំកូនចិញ្ចឹមនៅកម្ពុជា (របាយការណ៍សង្ខេបរបស់លីកាដូ ខែមករា ឆ្នាំ ២០០២)" ទំ. ៤ ។

[37] ពលកម្មកុមារនៅកម្ពុជា (វិទ្យាស្ថានការងារសេរីអាស៊ី អាមេរិក និងអង្គការលីកាដូ ខែកញ្ញា ឆ្នាំ ១៩៩៦) ។

ធ្វើបាបជាប្រចាំយូរមកហើយដោយអាណាព្យាបាល ជាស្ត្រីម្នាក់មានឥទ្ធិពលនៅក្នុងនយោបាយ និងសេដ្ឋកិច្ចនៅកម្ពុជា ។ ករណីនោះត្រូវបានដឹងដល់អង្គការលីកាដូតាមរយៈអ្នកជិតខាងម្នាក់ដែលប្រាប់ដោយប្រយ័ត្នប្រយែង ។ ថ្វីត្បិតតែមានភស្តុតាង នៃការរំលោភបំពានលើរូបរាងកាយដែលត្រូវព្យាបាលយ៉ាងប្រុងប្រយ័ត្នអាណាព្យាបាលជាស្ត្រីនោះត្រឹមតែទទួលទោសព្យួរមួយឆ្នាំតែប៉ុណ្ណោះនៅពេលកាត់ក្តី ។

## អនុសាសន៍

- បង្កើនចំនួនមន្ត្រីអនុវត្តច្បាប់ជាស្ត្រីភេទ និងមន្ត្រីផ្នែកច្បាប់ដែលមានអំណាចក្នុងការអនុវត្តន៍ទៅលើអំពើហិង្សាដែលបានប្រព្រឹត្តិល្មើសទៅលើស្ត្រីអោយបានច្រើន ។
- កាត់បន្ថយវប្បធម៌និទ្ទណ្ឌភាពដែលមានដ៏លើសលុប ដោយការខិតខំប្រឹងប្រែងជាប្រចាំ ដើម្បីនាំជនល្មើសទៅផ្តន្ទាទោស ( ព្រមទាំងលើកកំពស់ការយល់ដឹងអំពីបញ្ហានេះផង) ។
- ផ្សព្វផ្សាយព័ត៌មានថែមទៀតសំរាប់ស្ត្រី ស្តីពីសិទ្ធិរបស់ពួកគេ និងវិធីប្រតិបត្តិ ព្រមទាំងជួយប្រសិនបើស្ត្រីត្រូវរងគ្រោះ ឬស្វែងរកការជួយដល់ស្ត្រីដទៃ ឬកុមារ ។
- ធ្វើការស្រាវជ្រាវបន្ថែមទៀតទៅលើការកើនឡើងនូវចំនួនករណីនៃការរំលោភសេពសន្ថវៈ ។
- ផ្តល់ការអប់រំដោយសន្តិវិធីដល់សហគមន៍នឹងដាក់បញ្ចូលទៅក្នុងគំរោងមេរៀនតាមសាលារៀន នានា ដើម្បីជំនះអំពើហិង្សាដែលជិតដាមជាប្រវត្តិសាស្ត្រហើយកប់យ៉ាងជ្រៅនៅក្នុងសហគម ។
- បន្តពិនិត្យតាមដានផ្តល់សេវាពិគ្រោះប្រឹក្សាបញ្ហា និងព្យាបាលដល់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សា ជាពិសេសក្រុម គឺទៅលើជនរងគ្រោះជាអនិតិជន ។ ការផ្តល់ម្ហូបអាហារ ដល់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់គួរតែបែងចែកអោយដាច់ពីសេវា ដែលផ្តល់ដល់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ។
- ផ្តល់សេវាព្យាបាលពិសេសដល់ជនរងគ្រោះដោយរលាកទឹកអាស៊ីត (ទាំងការព្យាបាលខាងផ្លូវចិត្តផងដែរ) ។
- ដាក់កំហិត/ពិនិត្យការលក់ដូរអាស៊ីត ( ដូចជាអាស៊ីតស៊ុលផួរិក អាស៊ីតសំរាប់អាគុយ អាស៊ីតនីទ្រិក និងអាស៊ីតហ៊ីដ្រូក្លូលិកជាដើម ) ។
- រៀនសូត្រនឹងចែកចាយបទពិសោធន៍ជាមួយប្រទេសដទៃ ដូចជាប្រទេសប៉ាគីស្ថាន និងបង់ក្លាដេស ដែលមានបទពិសោធន៍យូរអង្វែងក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាប្រើទឹកអាស៊ីតធ្វើជាអាវុធវាយប្រហារនៅក្នុងតំបន់ ។
- រាជរដ្ឋាភិបាលកម្ពុជាត្រូវចុះហត្ថលេខាអនុសញ្ញាទីក្រុងឡាអេ ស្តីពីការសុំកូនចិញ្ចឹមឆ្លងកាត់ប្រទេស ហើយក្រុមសង្គមស៊ីវិលត្រូវបញ្ចុះបញ្ចូលដើម្បីអោយមានការរឹតបន្តឹង និងការអនុវត្តន៍ច្បាប់ស្តីពីការសុំកូនចិញ្ចឹមអន្តរជាតិ ដើម្បីការពារជនរងគ្រោះនៅក្នុងអាជីវកម្មនេះ (កុមារ ឪពុក ម្តាយពី

កំណើត ព្រមទាំងឪពុក-ម្តាយចិញ្ចឹមនៅបរទេស) ។ កម្ពុជាមិនត្រូវអោយគេមើលឃើញថាជាប្រទេសមួយសំរាប់ទិញដូរទារកទេ ។

- ឪពុក-ម្តាយត្រូវនាំកូនទៅចុះបញ្ជីអត្រានុកូលដ្ឋាននឹងត្រូវមានលិខិតបញ្ជាក់កំណើតសំរាប់កូនគ្រប់ៗគ្នា ។ ការធ្វើយ៉ាងនេះអាចជួយប្រយុទ្ធប្រឆាំង និងការអះអាងថាជាកុមារកំព្រាដោយក្លែងបន្លំ ។
- ភ្នាក់ងាររដ្ឋាភិបាលកម្ពុជា និងអន្តរជាតិ (ជាពិសេសសហរដ្ឋអាមេរិក) ត្រូវសហការនៅក្នុងការស៊ើបអង្កេតបទល្មើសក្នុងការផ្តល់ព័ត៌មានអំពីជនល្មើសដែលពាក់ព័ន្ធទៅនិងការជួញដូរមនុស្សអន្តរជាតិ ។
- ត្រូវបន្តធ្វើការស្រាវជ្រាវនឹងប្រឹងប្រែងថែមទៀត ដើម្បីអោយបានដឹងទៅដល់កុមារ ដែលបានត្រូវគេ "សុំយកទៅចិញ្ចឹមរួចហើយ" នៅក្នុងស្ថានភាពជាអ្នកបំរើ ឬទាសករនៅតាមគេហដ្ឋាននានា ។

# V- ស្ត្រី និងកុមារដែលត្រូវបានគេជួញដូរ និងបានធ្លាក់ទៅក្នុងអាជីវកម្មផ្លូវភេទ

## មាត្រា ៦

> *រដ្ឋភាគីទាំងឡាយត្រូវប្រកាន់យកវាល់វិធានការសមស្របទាំងអស់ ទាំងបញ្ញត្តិច្បាប់ផង ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ និងអាជីវកម្មផ្នែកពេស្យាកម្មនារីភេទ ។*

ការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងអនិតិជនបានធ្វើអោយមានការយកចិត្តទុកដាក់ពីសំណាក់ពិភពលោកទាំងមូល ។ ឧស្សាហកម្មផ្លូវភេទនៅ កម្ពុជាត្រូវបានចាប់ផ្តើមធ្វើអាជីវកម្មនៅដើមទសវត្សឆ្នាំ១៩៩០ ហើយបានរីករាលដាលយ៉ាងលឿន ដោយមានមនុស្សផ្លាស់ទីលំនៅមកប្រកបរបរនេះបណ្តោះអាសន្នយ៉ាងច្រើន ។ ចាប់តាំងពីពេលនោះមកកម្ពុជាចាប់មានឈ្មោះយ៉ាងអសោចថាជាប្រទេសមួយដែលទទួលនឹងនាំចេញនូវស្ត្រី និងកុមារ ហើយមានឈ្មោះថាជាប្រទេសមួយដែលមានស្ត្រី និងកុមារធ្លាក់ចូលក្នុងមុខរបរផ្លូវភេទយ៉ាងច្រើនផងដែរ ។ យោងតាមក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទារ បានអោយដឹងថា" ទីតាំងភូមិសាស្ត្ររបស់ប្រទេស ភាពក្រីក្រ ការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ និងហេដ្ឋារចនាសម្ព័ន្ធខ្ទេចខ្ទាំដោយសារសង្គ្រាម ក៏ដូចជាអំពើពុករលួយបានបង្កើតនូវបរិយាកាសមួយសំរាប់ពួកជួញដូរមនុស្ស ។" [38]

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា "ការជួញដូរស្ត្រី និងកុមារ គឺជាទំរង់នៃអំពើហិង្សាដ៏អាក្រក់បំផុតប្រឆាំងនឹងស្ត្រី ។"[39] ក្រៅពីបានដាក់អំពើពេស្យាចារជាអំពើខុសច្បាប់នៅឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអោយប្រើច្បាប់មួយស្តីពីការបង្ក្រាបអំពើចាប់ជំរិត ជួញដូរនឹងធ្វើអាជីវកម្មលើមនុស្ស ។ ច្បាប់នេះត្រូវបានគេយល់ថាមិនគ្រប់គ្រាន់ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងបញ្ហា ហើយក្រសួងយុត្តិធម៌ បច្ចុប្បន្នកំពុងធ្វើពង្រាងច្បាប់មួយអោយមានលក្ខណៈទូលំទូលាយជាងនេះ ។ រដ្ឋាភិបាលបានដាក់ចេញនូវវិធានការសំខាន់ៗមួយចំនួន ដើម្បីកាត់បន្ថយអំពើជួញដូរមនុស្សនឹងធ្វើអាជីវកម្មផ្លូវភេទ[40] ។ មានជំនួយពីអង្គការមិន

---

[38] បញ្ជាក់នៅក្នុងការអនុវត្តន៍ច្បាប់: ឧបសគ្គនឹងត្រូវជំនះដោយរបៀបណា ។ សិក្ខាសាលាស្តីពីការការពារច្បាប់ និងការអនុវត្តន៍ច្បាប់ក្នុងអំពើជួញដូរស្ត្រី និងកុមារ ( សន្ទរកថាថ្លែងដោយ វេជ្ជបណ្ឌិត ពុង ឈីវកេក លីកាដូ ភ្នំពេញខែវិច្ឆិកា ឆ្នាំ២០០០ ) ទំ. ១ ។

[39] របាយការណ៍ដំបូង-ទី២ និងទី៣ ស្តីពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិស្តីពីការលប់បំបាត់រាល់ទំរង់នៃអំពើហិង្សាប្រឆាំងនឹងនារីភេទនៅកម្ពុជា ( រាជរដ្ឋាភិបាលកម្ពុជា ខែតុលា ឆ្នាំ២០០៣) ទំ. ៣២ ។

[40] វិធានការទាំងនេះត្រូវបានគូសបញ្ជាក់នៅក្នុងរបាយការណ៍របស់រាជរដ្ឋាភិបាលស្តីពីការអនុវត្តន៍អនុសញ្ញាស្តីពីការលប់បំបាត់នូវរាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ឆ្នាំ២០០៣ ។ ...យុទ្ធសាស្ត្ររួមមានការបិទខារ៉ាអូខេ កន្លែងកំសាន្ត និងក្លិបរាត្រី ការ

មែនរដ្ឋាភិបាល និងអង្គការមូលនិធិយ៉ាងច្រើនក្នុងការស្រាវជ្រាវនឹងអនុវត្តយន្តការការពារស្ត្រីអោយមានប្រសិទ្ធិភាព ។ ប៉ុន្តែជាទូទៅគេទទួលស្គាល់ថាជាអំពើជួញដូរ និងការកេងប្រវ័ញ្ចស្ត្រីគ្រប់ទំរង់ទាំងអស់នៅតែកំពុងកើនឡើងជាលំដាប់ ។

## ហេតុអ្វីបានជាស្ត្រីកម្ពុជាធ្លាក់ចូលក្នុងនឹងនៅបន្តប្រកបមុខរបរផ្លូវភេទនេះ ?

ស្ត្រីជាច្រើនត្រូវបានជួញដូរចូលនឹងចេញពីកម្ពុជាដើម្បីបំរើក្នុងវ័យផ្លូវភេទ ប៉ុន្តែចំនួនស្ត្រីច្រើនបំផុតគឺត្រូវបានជួញដូរនៅប្រទេសកម្ពុជានេះតែម្តង ។ មានស្ថិតិដ៏សាំញ៉ាំមួយ ដែលចង់បង្ហាញពីចំនួនស្ត្រីក្នុងឧស្សាហកម្មផ្លូវភេទនៅកម្ពុជា ។ ប៉ុន្តែតួលេខទាំងនេះ មានការប្រែប្រួលយោងទៅតាមនិយមន័យខុសៗគ្នានៃពាក្យ "ស្ត្រីរកស៊ីផ្លូវភេទ" និងការវិវត្តន៍នៃវិធីសាស្ត្រក្នុងការស្រាវជ្រាវ ។ យោងតាមលោក *ស្តែនហ្វាត* ដែលបានផ្តល់នូវស្ថិតិប៉ាន់ស្មានយ៉ាងទាបបំផុតមានស្ត្រីបំរើផ្លូវភេទ ១៨.២៥៦នាក់ (រួមទាំងអ្នកប្រកបរបរនេះដោយផ្ទាល់ និងដោយប្រយោល) នៅក្នុងកំឡុងពេលឆ្នាំ ២០០២-២០០៣[41] ។ ការប៉ាន់ស្មានខ្ពស់បំផុត គឺពី៨០.០០០ ទៅ ១០០.០០០នាក់ ដែលបានប៉ាន់ស្មានដោយរបាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សកម្ពុជារបស់ក្រសួងផែនការក្នុងឆ្នាំ ២០០០[42] ។ ការប៉ាន់ស្មានទាំងពីរនេះបានបង្ហាញនូវស្ថានការណ៍អាសន្នមួយ ។

ស្ត្រីកម្ពុជាអាចត្រូវបានអូសទាញអោយចូលទៅក្នុងមុខរបរផ្លូវភេទ ពីព្រោះភាពក្រីក្រ ខ្វះការអប់រំ និងការបាក់បែកសន្តិសុខគ្រួសារ ព្រមទាំងការកើនឡើងនូវអំពើហិង្សាក្នុងគ្រួសារ ។ ស្ត្រីមួយចំនួនអាចចាត់ទុកវាថាការចូលបំរើនៅក្នុងផ្ទះបនជាការងារធម្មតាមួយ ដូចជាម៉ាស្សានឹងលក់ស្រាបៀរជាដើម ថាជាការជ្រើសរើសដោយខ្លួនឯង ។ ប៉ុន្តែ យោងតាមការស្រាវរបស់មជ្ឈមណ្ឌលកម្ពុជា ដើម្បីស្ត្រីជួយមានវិបត្តិបានអោយដឹងថា នារីរកស៊ីផ្លូវភេទ ៦៤.៤៥% ត្រូវបានបង្ខំអោយធ្វើការងារនេះ ចំណែកឯស្ត្រី ៥២.៩% ទៀតចាញ់បោកគេដោយចង់បានការងារល្អ ហើយ ១១.០៤ %ត្រូវគ្រួសារនាំយកមកលក់ ចុងក្រោយស្ត្រីចំនួន ០.៥៨% ត្រូវគេរំលោភផ្លូវភេទ[43] ។ ក្នុងករណី ដែលស្ត្រីត្រូវបានជួញដូរទាំងនៅក្រៅនិងនៅក្នុងប្រទេស

---

បង្កើតក្រុមប្រឹក្សាកុមារ ក្នុងការពិនិត្យតាមដានការធ្វើអាជីវកម្ម អនិតិជន ការបង្កើតក្រុមប្រឹក្សាជាតិ ដើម្បីស្ត្រី ឃ្លាំពិនិត្យតាមការប្រយុទ្ធប្រឆាំងនឹងការធ្វើអាជីវកម្មលើស្ត្រី និងការបង្កើតឡើងនូវគណៈកម្មការប្រតិបត្តិច្បាប់ ដែលគាំទ្រដោយអង្គការមូលនិធិ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដើម្បីហ្វឹកហ្វឺនសភ្នាក់ងារអនុវត្តន៍ច្បាប់ដែលជាវិធានការការពារ ។

41 ការវាស់ស្ទង់ចំនួនស្ត្រី និងកុមារដែលត្រូវបានជួញដូរនៅកម្ពុជា: ការសិក្សាតាមវិធីសាស្ត្រសង្កេតផ្ទាល់នៅតាមមូលដ្ឋាន (Thomas M. Steinfatt,) សកលវិទ្យាល័យ Miami ឆ្នាំ ២០០៣ ទំ. ១១

42 របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជា ឆ្នាំ ២០០០: កុមារ និងការងារ (ក្រសួងផែនការ ឆ្នាំ ២០០០) ទំ. ១០

43 មជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ -ជួយស្ត្រីដើម្បីអោយពួកគេចេះជួយខ្លួនគេ ( របាយការណ៍ប្រចាំឆ្នាំ ខែ មករា -ធ្នូ ឆ្នាំ ២០០២ របស់មជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ ) ទំ. ១៧

ដើម្បីគោលបំណងផ្លូវភេទ ភាគរយនៃពួកអ្នកដែលអះអាងថាពួកគេបានបោកប្រាស់ ដោយការសន្យាថាផ្តល់ការងារល្អជាងមុននោះត្រូវបានកើនឡើង ។

មានករណីបែបនេះយ៉ាងច្រើនលើសលុបដែលធ្វើទុក្ខទោសមានអំពើរំលោភ អំពើហិង្សា និងស្ថានភាពដ៏គួរអោយរន្ធត់ដែលស្ត្រីត្រូវស្ថិតនៅក្នុងផ្ទះបននៅទូទាំងប្រទេសកម្ពុជា ។ នារីរកស៊ីផ្លូវភេទត្រូវបានគេយល់ឃើញថាជាកម្មសិទ្ធិរបស់មេបន ។ ដូចជាមេបនយល់ថា គាត់មានអំណាចឃុំឃាំងនឹងវាយដំនារីតាមចិត្ត ប្រសិនបើពួកគេមិនធ្វើតាមមេបននោះ ។ នៅក្នុងករណីខ្លះមេបនសង្ឃឹមថានារីរកស៊ីផ្លូវភេទបំរើភ្ញៀវរហូត ៤០នាក់ក្នុងមួយថ្ងៃ ។ នេះពុំមែនជារឿងប្លែកទេចំពោះមេបនក្នុងការផ្តល់អោយស្ត្រីនូវគ្រឿងញៀន ដើម្បីអោយពួកគេធ្វើតាម ។ ស្ត្រីបំរើផ្លូវភេទមួយចំនួនបានក្លាយទៅជាញៀនណាកូទិក ដែលជួយពន្យល់អំពីមូលហេតុថា ហេតុអ្វីបានជាពួកគេបន្តរស់នៅនឹងវិលត្រឡប់មកផ្ទះបនវិញ ។

## និទ្ទណ្ឌភាពផ្នែកច្បាប់ចំពោះជនល្មើសប្រព្រឹត្តអំពើជួញដូរមនុស្ស និងមេបន

បទឧក្រិដ្ឋដែលពាក់ព័ន្ធ និងការកេងប្រវ័ញ្ចផ្លូវភេទស្ត្រីភាគច្រើនត្រូវបានប្រព្រឹត្តដោយគ្មានទោសពៃរ៍ (និទ្ទណ្ឌភាព) ។ មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីមួយចំនួនបានធ្វើមិនដឹងមិនឮចំពោះបញ្ហានេះ ហើយបែរជាចូលរួមពាក់ព័ន្ធនៅក្នុងបទល្មើសនេះដោយការទទួលសំណូកទៅវិញ ។ យោងតាមរបាយការណ៍របស់កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម-លីកាដូ "មុខរបរសាច់ឈាមនេះ គឺជារបរដែលរកស៊ីកាក់កប ដូចមុខរបរកាក់កបផ្សេងៗទៀតនៅកម្ពុជាដែរ មុខរបរនេះត្រូវបានគ្រប់គ្រងដោយមនុស្សដែលមានអាវុធ និងមានអំណាច ។" នគរបាល និងកងរាជអាវុធហត្ថ កងទ័ព និងមន្ត្រីរាជការផ្សេងៗទៀតបានលូកដៃយ៉ាងជ្រៅចូលទៅក្នុងពាណិជ្ជកម្មបែបនេះ ដោយការគ្រប់គ្រង ឬការពារអំពើជួញដូរមនុស្សយ៉ាងសកម្មជុំវិញផ្ទះបន [44] ។ ចំពោះករណីជួញដូរមនុស្សជនល្មើសក៏អាចសង្ឃឹមថាបានទទួលជំនួយពីសំណាក់មន្ត្រីអន្តោប្រវេសន៍ផងដែរ នៅក្រុង-ខេត្តដែលមានការជួញដូរមនុស្សជាទ្រង់ទ្រាយធំ ដូចជានៅទីប្រជុំជនប៉ោយប៉ែត (តាមបណ្តោយព្រំដែនថៃ) នៅស្វាយរៀង និងនៅកំពង់ចាម (តំបន់ព្រំដែនជាប់វៀតណាម) ។ និយាយអោយខ្លី "អំពើជួញដូរមនុស្ស គឺជាគំរូអាក្រក់មួយដែលប្រកបដោយនិទ្ទណ្ឌភាព ហើយបានក្លាយទៅជាបញ្ញត្តិមួយ ដែលការផ្តន្ទាទោសត្រូវបានចាត់ទុកជារឿងធម្មតាទៅវិញ[45] ។ ជាការស្ទើរតែមិនអាចរៀបរាប់ចំនួនអំពើរំលោភដ៏គួរអោយព្រឺព្រួចដែលសំបូរបំផុតក្នុងករណីជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ។ ឧទាហរណ៍ ជាក់ស្តែងមួយគឺរឿងរបស់ស្ត្រីម្នាក់ដែលត្រូវបានធ្វើឃាតដោយ *មាច ប៊ុនរិទ្ធ* ដែលជាមេបនដ៏ល្បីល្បាញខាងវាយដំ ធ្វើទុក្ខ

---

[44] "មិនសមរស់នៅជាមនុស្ស" អំពើទារុណកម្មនៅកម្ពុជា (Jason Barber) របាយការណ៍កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម (PAT) លីកាដូ ឆ្នាំ២០០០) ទំ. ៤

[45] របាយការណ៍ស្តីពីសិទ្ធិមនុស្ស (សមាគមន៍កម្ពុជា ដើម្បីអភិវឌ្ឍន៍ និងសិទ្ធិមនុស្ស ភ្នំពេញខែមករា ឆ្នាំ២០០៤) ទំ. ៦៧

ទោសនឹងជួញដូរមនុស្សនៅតំបន់ប៉ោយប៉ែត ។ គេបានល្បីថា មានយោធាដ៏មានអំណាចនៅពីក្រោយខ្នង និងការពារគាត់ជាខ្នងបង្អែកក្នុងការរកស៊ីនេះ ។ នៅក្នុងខែមិថុនា ឆ្នាំ១៩៩៨ គាត់បានវាយដំស្ត្រីម្នាក់ដែលមានអាយុ ២៤ឆ្នាំនៅក្នុងផ្ទះបន ។ ថ្វីត្បិតតែនាងបានរងរបួសក្តី នាងត្រូវបានគេឃុំទុកក្នុងបន្ទប់ដ៏ក្រខ្វក់មួយ ហើយមិនអោយនាងព្យាបាលអស់រយៈពេលបីថ្ងៃ ។ ក្រោយមក នាងក៏បានស្លាប់នៅក្នុងគ្លីនិកមួយនៅក្នុងតំបន់នោះ ។ ក្រោយពេលនោះ *មាច ប៊ុនរិទ្ធ* ត្រូវបានចាប់ខ្លួននឹងចោទប្រកាន់ ។ ថ្វីត្បិតតែមានសាក្សី (ដែលហ៊ានចេញមុខ) ព្រមទាំងភស្តុតាងដ៏ច្រើនលើសលុប ក៏ករណីនោះត្រូវបានលើកលែងការចោទប្រកាន់ដោយសំអាងថាពុំមានភស្តុតាងគ្រប់គ្រាន់ ។ ក្រោយមកជនរូបនោះមានសេរីភាព ហើយវិលត្រឡប់ទៅប្រព្រឹត្តមុខរបរដូចដើមវិញ[46] ។

ពេស្យាចារ និងអំពើជួញដូរមនុស្សជាមុខរបរខុសច្បាប់ ហើយសកម្មភាពទាំងពីរនេះមានភាពស្មុគស្មាញ និងពិបាកក្នុងការប្រយុទ្ធប្រឆាំងដោយពួកអ្នករកស៊ីទាំងនោះច្រើនតែមានខ្នងបង្អែកការពារ ហេតុនេះទើបពួកគេចេះតែរួចទោសជានិច្ច ។ ការពិតទៅមានតែប្រជាជនសាមញ្ញធម្មតាតែប៉ុណ្ណោះ ដែលរងការដាក់ទណ្ឌកម្មចំពោះទង្វើពាក់ព័ន្ធនៅក្នុងរឿងដូចពោលខាងលើ ។ ភាគច្រើនជនទាំងនេះជាជនក្រីក្របំផុតក្នុងចំណោមជនក្រីក្រទាំងពួង ដូចជាម្តាយដែលលក់កូនស្រីរបស់ខ្លួនក្នុងតំលៃព្រមព្រៀងមួយ ។ ចំពោះក្នុងបញ្ហានេះ តំរូវអោយមានការខិតខំប្រឹងប្រែងរួមគ្នាយ៉ាងខ្លាំង ដើម្បីកាត់បន្ថយនូវវប្បធម៌និទ្ទណ្ឌភាព និងអំពើពុករលួយនៅជុំវិញមុខរបរអាជីវកម្មផ្លូវភេទនេះ ។

វិធីសាស្ត្រមួយក្នុងការកំចាត់អំពើនេះ គឺការព្យាយាមនៃការផ្តល់អំណាចចំពោះស្ត្រីរកស៊ីផ្លូវភេទដើម្បីអោយពួកគេចេះជួយខ្លួនទេ ។ ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDA) បានលើកទឹកចិត្តអោយស្ត្រីរកស៊ីផ្លូវភេទបង្កើតសហជីពរបស់ពួកគេ ដើម្បីការពារនារីទាំងឡាយដែលប្រកបរបរនៅក្នុងវិស័យនេះ ។ ប៉ុន្តែច្បាប់សមាគមនេះមិនសង្ឃឹមថា មានការចូលរួមច្រើនពីស្ត្រី ដែលត្រូវគេឃុំឃាំងក្នុងផ្ទះបននៅកម្ពុជា ឬទីណាដទៃទៀតនោះទេ ។ អង្គការផ្សេងៗទៀតក៏បានព្យាយាមការពារស្ត្រី ដែលងាយរងគ្រោះបំផុតក្នុងផ្ទះបនផងដែរ ដោយជួយផ្តល់ប្រាក់លោះអោយមេបនជាថ្នូរនឹងការដោះលែងរបស់ពួកគេ ។ ការធ្វើបែបនេះជាការជួយអោយមានមធ្យោបាយគ្រប់គ្រាន់ក្នុងការគេចខ្លួន តែទង្វើបែបនេះ វាដូចជារបររកស៊ីជាមួយ និងទំនិញប្រើប្រាស់ទៅវិញ តែទីបំផុតវាទៅជាអំពើធ្វើអាជីវកម្មលើមនុស្សដដែល ។

## ស្ត្រីវៀតណាមបំរើផ្លូវភេទនៅកម្ពុជា

46 ករណីនេះត្រូវបានបញ្ជាក់នៅក្នុងអំពើពុករលួយ និងអាជីវកម្មផ្លូវភេទ (សន្ទរកថាថ្លែងដោយលោកស្រីវេជ្ជ. ពុង ឈីវកេក ប្រធានអង្គការលីកាដូ នៅមុខវត្តបុទុម ខែ ធ្នូ ឆ្នាំ ២០០១) ទំ. ២

គេប៉ាន់ស្មានថា ៥០% នៃនារីបំរើផ្លូវភេទនៅកម្ពុជា គឺជាជនជាតិវៀតណាម[47] ។ ភាគច្រើនមានប្រភពមកពីតំបន់ដីសណ្តរទន្លេមេគង្គ ហើយដែលជ្រៀតចូលតាមច្រកបៀងព្រំដែនរបស់កម្ពុជា និងច្រើនតែមានអ្នកជំនាញខាងជួញដូរមនុស្សជួយផង រួមជាមួយនឹងការផ្សំគំនិតរបស់ប៉ូលីសការពារព្រំដែនពុករលួយផង[48] ។ និយាយជាទូទៅស្ត្រីវៀតណាមធ្លាក់ចូលក្នុងរបររកស៊ីផ្លូវភេទ ដោយមានហេតុផលខុសពីស្ត្រីកម្ពុជា ។ ប៉ុន្តែយើងក៏មិនអាចនិយាយថា ស្ត្រីវៀតណាមរកស៊ីរបរផ្លូវភេទនេះដោយឆន្ទៈរបស់ខ្លួនគេដែរ មួយភាគធំបាននិយាយដោយស្មោះត្រង់ថា ដើម្បីជួយដោះបំណុលគ្រួសារដែលជំពាក់នៅក្នុងទឹកដីរបស់គេ ។ ចំណុចសំខាន់ គឺពួកគេបានក្លាយទៅជាកម្មករជាប់កិច្ចសន្យា ហើយមិនចង់ចាកចេញពីផ្ទះបនទេរហូតដល់សងបំណុលរួច ។ មកដល់ពេលនេះគួរអោយខ្វាយខ្វល់ដែរ ដោយអនុស្សារណៈយោគយល់នៅមិនទាន់បានចុះហត្ថលេខានៅឡើយជាមួយភាគីវៀតណាម ។ នារីវៀតណាមមិនគ្រាន់តែគ្រោះថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រឈមនឹងការចាប់ខ្លួនរបស់នគរបាលដោយសារតែបានរំលោភច្បាប់អន្តោប្រវេសន៍ទៀតផង ។ បញ្ហានេះការងារសង្គ្រោះនិងការស្តារនីតិសម្បទារជាមួយស្ត្រីរកស៊ីផ្លូវភេទវៀតណាម គឺកាន់តែលំបាក ស្មុគស្មាញជាងការធ្វើការងារជាមួយនារីកម្ពុជាទៅទៀត[49] ។

# កម្មវិធីស្តារនីតិសម្បទារ និងសមាហរណកម្មដល់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សនឹងកេងប្រវ័ញ្ចផ្លូវភេទ

ត្រូវទទួលស្គាល់ថា ពុំមែនគ្រប់ស្ត្រីទាំងអស់ ដែលប្រកបរបរផ្លូវភេទត្រូវបានបង្ខំអោយបន្តនៅក្នុងផ្ទះបនទេ ។ មានស្ត្រីមួយចំនួនបានសុខចិត្តនៅដោយស្ម័គ្រចិត្ត ។ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការផ្សេងៗទៀត ជាពិសេសអង្គការដែលជួយសង្គ្រោះត្រូវប្រុងប្រយ័ត្នមិនត្រូវយកចិត្តទុកដាក់ចំពោះមនសិការខុសរបស់ស្ត្រីដែលស្វែងរកការគាំទ្រជួយនោះ ។ ក្រសួងកិច្ចការនារី និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដូចជាមជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ និងលីកាដូបានអនុវត្តកម្មវិធីស្តារនីតិសម្បទារនេះ ។ កម្មវិធីស្តារនីតិសម្បទារផ្តោតទៅលើការផ្តល់សន្តិសុខ ជំនួយផ្នែកសតិអារម្មណ៍ និងការពិគ្រោះប្រឹក្សាបញ្ហា

---

47 ស្ថិតិនេះផ្តល់ដោយរដ្ឋភិបាល របាយការណ៍ដំបូង ទី២ និងទី៣ ស្តីពីការអនុវត្តន៍អនុសញ្ញាស្តីពីការលប់បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ខែតុលា ឆ្នាំ២០០៣) ប៉ុន្តែលោក Steinfatt បានលើកឡើងថាចំនួនអាចតិចជាងនេះប្រហែលជា ៤៣%-តាមឯកសារ "ការវាស់វែងចំនួនស្ត្រី និងកុមារដែលត្រូវជួញដូរនៅកម្ពុជា" ការសិក្សាដោយវិធីសាស្ត្រសង្កេតផ្ទាល់នៅមូលដ្ឋានដោយ ( Thomas M. Steinfatt សកលវិទ្យាល័យម៉ាយមី ឆ្នាំ ២០០៣ ) ។

48 មិនដូចប្រទេសថៃទេ ប្រទេសវៀតណាមមិនទាន់បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ (MoU) ជាមួយនឹងភាគីកម្ពុជាទេអំពីបញ្ហាអំពើជួញដូរមនុស្សនេះ ។ គេសង្ឃឹមថា (MoU)នេះនឹងត្រូវចុះហត្ថលេខានៅឆ្នាំ២០០៤ ។

49 ក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះមានការសង្គ្រោះស្ត្រីវៀតណាមួយចំនួនចេញពីផ្ទះបន ហើយយកទៅដាក់ក្នុងមណ្ឌលស្តារនីតិសម្បទារគ្រាន់តែជាការគេចពីផ្ទះបនម្តងម្កាលប៉ុណ្ណោះ ។

សេវាគាំទ្រទូទៅ និងការឧបត្ថមដល់វគ្គហ្វឹកហ្វឺនវិជ្ជាជីវៈនានា (ដល់ស្ត្រី និងកុមារ) កម្មវិធីសមាហរណកម្មមាន ដូចជាផ្តល់កន្លែងស្នាក់នៅសមរម្យសំរាប់ជនរងគ្រោះ ។ យោងតាមមជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិបានអោយដឹងថា ជនរងគ្រោះជាច្រើនមានការភ័យខ្លាចក្នុងការត្រឡប់ទៅភូមិ-ឃុំរបស់ពួកគេវិញ ពិសេសខ្លាចមានការរំលោភម្តងទៀត និងការបណ្តេញចេញពីសហគមន៍ ។ នីតិសម្បទារួមមាន ដូចជាការផ្តល់ជំរើសការងារ និងកន្លែងរស់នៅផ្សេងៗដល់ជនរងគ្រោះនៅក្នុងប្រទេសកម្ពុជា ។

## សុខភាពចំពោះស្ត្រីបំរើផ្លូវភេទ

នារីបំរើផ្លូវភេទប្រឈមមុខជាមួយ និងការគំរាមកំហែងពីរបែប គឺសុខភាព និងសន្តិសុខ ។ បញ្ហាទីមួយ គឺជាការកើនឡើងនូវអំពើហិង្សាមកលើស្ត្រី និងកុមារនៅក្នុងវិស័យផ្លូវភេទនេះ បញ្ហាទីពីរ គឺជាការឆ្លងជំងឺតាមរយៈការរួមភេទ ដូចជាជំងឺ HIV/AIDS ជាដើម ។ នៅឆ្នាំ ១៩៩៩ គេបានប៉ាន់ប្រមាណថាមានការឆ្លងជំងឺអេដស៏នៅក្នុងចំណោមនារីប្រកបរបររកស៊ីផ្លូវភេទ ដោយផ្ទាល់មាន ៣៣.២% នារីបំរើផ្លូវភេទជាលក្ខណៈពាណិជ្ជកម្មមាន ១៩.៨% និងនារីបំរើផ្លូវភេទជាលក្ខណៈឯកជនផ្ទាល់ខ្លួនមាន ១៦.៧%[50] ។ ចំនួននេះបានបង្ហាញនូវការថយចុះ បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ ហើយតួលេខនេះអាចចុះថែមទៀត ដោយនារីបំរើផ្លូវបានទទួលជំនួយឧបត្ថម និងព័ត៌មានស្តីពីកិច្ចការពារខ្លួនអំពីជំងឺអេដស៏ច្រើនជាងមុន ។

## ការជួញដូរស្ត្រី និងកុមារដែលពុំមែនជាបុព្វហេតុជួញដូរផ្លូវភេទ

ពលរដ្ឋកម្ពុជាត្រូវបានគេជួញដូរដូចជា ***"ទំនិញប្រើប្រាស់"*** ក្នុងគោលបំណងធ្វើអាជីវកម្មពុំមែនបុព្វហេតុខាងបំរើផ្លូវភេទ ។ វិធីដែលពួកជួញដូរមនុស្សទាំងនោះទទួលបានជោគជ័យទូទៅ គឺពួកគេដើរបោកប្រាស់បុរស-ស្ត្រី និងកុមារក្រីក្រងាយរងគ្រោះ ហើយគេអាចប្រព្រឹត្តទៅដោយគ្មានទោសពៃរ៍ ដោយមានការរួមសមគំនិតនឹងការពារពីសំណាក់មន្ត្រីរដ្ឋាភិបាល និងមន្ត្រីអនុវត្តច្បាប់ខ្លះនានា ។

នៅប្រទេសថៃ វៀតណាម និងប្រទេសអាស៊ានជាច្រើនទៀតនៅតែជាប្រទេស ដែលទទួលពលករជួញដូរពីកម្ពុជាក្នុងកំរិតកាន់តែទាបជាងមុន ។ ការប៉ាន់ស្មានថានៅឆ្នាំ ២000 មានពលករដែលជំពាក់បំណុល ៨៨.000 នាក់នៅក្នុងប្រទេសថៃ[51] ។ ចំនួននេះរួមទាំងបុរស និងស្ត្រីដែលត្រូវជួញដូរទៅប្រទេសថៃ (ច្រើនតែស្ម័គ្រចិត្តដោយមានការសន្យាថា មានការងារល្អៗ) តែក្រោយមកត្រូវបានគេប្រើដូចជាទាស

[50] អ្នកឃ្លាំមើល HIV ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងនឹងជំងឺ HIV/AIDS រោគសើរស្បែក និងរោគសង្គម ឆ្នាំ២000 ។

[51] ការអនុវត្តន៍ច្បាប់: ឧបសគ្គ និងត្រូវជំនះដោយរបៀបណា ។ សិក្ខាសាលាស្តីពីការការពារផ្លូវច្បាប់ និងការអនុវត្តន៍ច្បាប់ស្តីពីអំពើជួញដូរស្ត្រី និងកុមារ (សន្ទរកថាថ្លែងដោយ វេជ្ជ. ពុង ឈីវកេក ភ្នំពេញឆ្នាំ២000 ទំ. ១ ។

ករនៅក្នុងវិស័យនេសាទ លី សែង កំពង់ផែ ការដ្ឋានសំណង់ និងក្នុងវិស័យសេវាកម្មជាច្រើនថែមទៀត ។ គេមានសេចក្តីរាយការណ៍ថា មានបុរសជាច្រើនដែលធ្វើការនៅក្នុងកន្លែងលីសែងធ្ងន់ៗត្រូវបានគេបង្ខំអោយប្រើប្រាស់ថ្នាំញៀន (ណាកូទិក) ដើម្បីអោយមានកំលាំងធ្វើការខ្លាំងក្លា[52] ។ នៅក្នុងការបោសសំអាតថ្មីៗនេះនៅទីក្រុងបាងកក ក្រុមនគរបាលបានរំដោះទាសករជំទង់ៗជនជាតិកម្ពុជាចំនួន ១៨នាក់ (ក្នុងនោះមានកុមារី ៣នាក់) ។ ក្រុមនគរបាលបានរាយការណ៍ថាកម្មករ ៥នាក់ក្នុងចំណោមទាំងអស់នោះគ្រោះថ្នាក់ដាច់ម្រាមដៃដោយការប្រើប្រាស់ម៉ាស៊ីនផលិតកំប៉ុង ហើយពួកទាំងនោះត្រូវរក្សាទុកក្នុងស្ថានភាពមួយដ៏គួរអោយរន្ធត់ជាទីបំផុត[53] ។

មុខរបរដ៏កាក់កបមួយទៀតសំរាប់ពួកជួញដូរមនុស្ស គឺ "ការនាំចេញ" កុមារទៅប្រទេសថៃ ឬទៅវៀតណាម ដើម្បីយកទៅធ្វើជាអ្នកសុំទាន ឬក្រុមឆក់ប្លន់[54] ។ យោងតាមស្ថិតិជាផ្លូវការរបស់ប្រទេសថៃបានបញ្ជាក់ថា ខណៈនេះយ៉ាងហោចណាស់មានកុមារកម្ពុជា ៥០០នាក់ កំពុងសុំទានតាមដងវិថីនានាក្នុងទីក្រុងនៃប្រទេសថៃ[55] ។ នៅវៀតណាម ចំនួននេះអាចខ្ពស់អាចស្មើ ឬអាចខ្ពស់ជាង ។ នៅពេលដែលកុមារទៅដល់ទីក្រុងទាំងនេះ កុមារទាំងនោះនឹងត្រូវគ្រប់គ្រងដោយមនុស្សមានអំណាចមួយចំនួន ជាធម្មតាពួកគេជាមនុស្ស ដែលស្ថិតក្នុងក្រុមម៉ាហ្វីយ៉ា ហើយជាអ្នកដើរប្រមូលលុយដែលកុមារសុំបានទាំងអស់ ដោយមិនទុកអោយបន្តិចបន្តួចសំរាប់រស់ឡើយ ។ ការដើរយ៉ាងប្រញាប់ប្រញាល់តាមវិថីក្នុងទីក្រុងព្រៃនគរបានលាតត្រដាងអោយឃើញថា កុមារទាំងនោះមានទំលាប់ប្រឈមមុខនិងការគំរាមកំហែងនូវអំពើហិង្សាពីសំណាក់ក្រុមក្មេងជំទង់ៗ ដែលបានបង្កើតឡើងក្នុងទីក្រុង ដែលកំពុងប្រកបរបរសុំទានដូចគ្នា ។

ការជួញដូរគ្រឿងញៀននឹងជួញដូរស្ត្រីបានក្លាយទៅជាសម្ព័ន្ធមិនបរិសុទ្ធនៅកម្ពុជាបច្ចុប្បន្ន ។ ពួកជនល្មើសជួញដូរមនុស្សបានប្រើស្ត្រីឆ្លងដែនទៅប្រទេសថៃធ្វើជាអ្នកដឹកជញ្ជូនថ្នាំញៀនហេរ៉ូអ៊ីន និងយ៉ាម៉ា ។ ក្រៅពីគ្រោះថ្នាក់ដល់សុខភាព ដែលអាចមើលឃើញច្បាស់ ដោយការដឹកជញ្ជូនគ្រឿងញៀនតាមទ្រង់ទ្រាយផ្សេងៗ គឺស្ត្រីទាំងនេះជាអ្នកប្រឈមមុខ និងការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរដោយប្រហាជីវិត ប្រសិនបើអាជ្ញាធរថៃចាប់ខ្លួនបាន ។

---

[52] ពលករទេសន្តប្រវេសន៍ទៅប្រទេសថៃ : ការវាយតំលៃដំបូង (ចាន់ សុផល និងសុវណ្ណារិទ្ធ- វិទ្យាស្ថានអភិវឌ្ឍន៍ ធនធានកម្ពុជា ខែមិថុនា ឆ្នាំ១៩៩៩ ទំ. ៨

[53] "ក្រុមនគរបាលបានបោសសំអាតហាងលក់បង្អែម សង្គ្រោះក្មេងជំទង់កម្ពុជា ១៨ នាក់" កាសែតបាងកកប៉ុស្តិ៍ ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៣) ។

[54] ជនពិការ និងស្ត្រីមានកូនតូចៗក៏ជាគោលដៅរបស់ពួកជួញដូរមនុស្ស ដែលយកពួកគេទៅឱ្យសុំទានក្នុងប្រទេសជិតខាងផងដែរ ។

[55] បញ្ជាក់នៅក្នុងរបាយការណ៍ "មិនសមរស់នៅជាមនុស្ស": អំពើទារុណកម្មនៅកម្ពុជា (Jason Barber) កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម PAT របាយការណ៍លីកាដូ ឆ្នាំ២០០០ ទំ. ៦៩ ។ តួលេខនេះត្រូវបានកត់ត្រា ដោយម៉ត់ហ្មត់ តែតាមការពិតប្រហែលជាស្ថិតិលើសពីនេះទៅទៀត ។

# អនុសាសន៍

- ឃៃមបូរ និងអង្គការសង្គមស៊ីវិលផ្សេងៗទៀតត្រូវបន្តបញ្ចុះបញ្ចូលក្រសួងយុត្តិធម៌ ដើម្បីអោយមានការកែទំរង់នឹងងបង្កើតនូវច្បាប់ថ្មី ដើម្បីប្រឆាំងការជួញដូរមនុស្ស ដែលប្រកបដោយគតិយុត្តិទូលំទូលាយត្រឹមត្រូវសមរម្យ ។
- ត្រូវប្រើគ្រប់មធ្យោបាយទាំងអស់ ដើម្បីអនុវត្តច្បាប់បច្ចុប្បន្ន ដែលការពារស្ត្រីពីអំពើរំលោភផ្លូវភេទនឹងជួញដូរមនុស្ស ។ សកម្មភាពទាំងនេះត្រូវតែមានដំណើរការ ដើម្បីជំនះវប្បធម៌និទ្ទណ្ឌភាព និងអំពើពុករលួយ ។
- គួរគិតគូរដល់ការដំឡើងប្រាក់ខែមន្ត្រីរាជការ ដោយបញ្ហានេះជាមធ្យោបាយ និងជាគន្លឹះមួយក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងចំណោមមន្ត្រីរាជការ ។
- ការហ្វឹកហ្វឺន និងការអប់រំបន្ថែមទៀតដល់មន្ត្រីនគរបាលព្រំដែន ដែលធ្វើការងារប្រកៀកនឹងមជ្ឈមណ្ឌលជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ។
- តំរូវអោយមានការសិក្សាស្រាវជ្រាវថែមទៀត (ទាំងនៅកម្ពុជា និងវៀតណាម) ដើម្បីស្វែងរកមធ្យោបាយក្នុងការជួយនារីបំរើផ្លូវភេទជនជាតិវៀតណាមនៅកម្ពុជាអោយបានប្រសើរជាងមុន ។ បោសសំអាតផ្ទះបនទានា និងការបញ្ជូនជនជាតិវៀតណាមទាំងនោះត្រឡប់ទៅវិញមិនអាចជាដំណោះស្រាយល្អបំផុតទេ ។
- ត្រូវបន្តបញ្ចប់អនុស្សារណៈយោគយល់រវាងកម្ពុជា និងវៀតណាម ដើម្បីការពារស្ត្រីបំរើផ្លូវភេទជាជនជាតិវៀតណាមពីការរងគ្រោះដោយការជួញដូរក្លាយទៅជាជនអន្តោប្រវេសន៍ខុសច្បាប់ ។
- បន្តការអប់រំស្តីពី HIV/AIDS ដល់ស្ត្រីរកស៊ីផ្លូវភេទ និងក្រុមបុរសដែលចូលចិត្តស្ត្រីទាំងនោះ ដូចជាមន្ត្រីយោធា និងនគរបាល ព្រមទាំងពួកកម្មករ ដែលតែងតែចល័តចុះឡើងដូចជាអ្នកនេសាទត្រី ។
- ធ្វើការត្រួតពិនិត្យឈាមដល់នារីបំរើផ្លូវភេទ និងក្រុមអតិថិជនសំខាន់ៗរបស់ពួកគេអោយបានជាប្រចាំ ។
- បង្កើនមូលនិធិនឹងផ្តល់ជំនួយដល់ក្រសួងកិច្ចការនារី និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀតដើម្បីអនុវត្តកម្មវិធីស្តារនីតិសម្បទារ និងការតាំងទីលំនៅថ្មីដល់ស្ត្រី ដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទអោយមានប្រសិទ្ធិភាព ។
- គួរផ្តោតការយកចិត្តទុកដាក់អោយបានខ្លាំងទៅលើក្រុមនារីក្មេងៗអោយមានជំនាញ ដែលអាចផ្តល់ដល់ពួកគេមានលំនឹងក្នុងជីវិត និងក៏ជាមធ្យោបាយមួយក្នុងការទប់ស្កាត់ពួកគេកុំអោយធ្លាក់ចូលទៅក្នុងអាជីវកម្មបំរើផ្លូវភេទនេះ ។

- កំចាត់ចោលនូវស្លាកស្នាមអាក្រក់ ដែលជិតជាប់នឹងជនរងគ្រោះដោយអាជីវកម្មភេទ ដែលជាឧបសគ្គដល់ការស្តារនិតិសម្បទារ និងការវិលត្រឡប់ទៅតាំងទីលំនៅឡើងវិញនៅក្នុងសហគមន៍ ។

# VI- ស្ត្រីក្នុងពន្ធនាគារ

ដោយសារមានរូបភាពជាក់ស្តែងនៅគុកទួលស្លែងនាទីក្រុងភ្នំពេញ កាលពីរបបកម្ពុជាប្រជាធិប-តេយ្យបានធ្វើឱ្យប្រទេសកម្ពុជាទទួលនូវភាពអាម៉ាស់គួរឱ្យសោកស្តាយនៅលើឆាកអន្តរជាតិ ។ ចាប់ពីពេលនោះមកការកែលំអ ដែលត្រូវធ្វើឱ្យប្រសើរឡើងជាអតិបរិមានោះបានជិតដាមនៅក្នុងប្រព័ន្ធព្រហ្មទណ្ឌកម្ពុជា ។ ប្រការខាងលើនេះបណ្តាលឱ្យទៅជាលក្ខខណ្ឌដល់សកម្មភាពតាមដានត្រួតពិនិត្យអំពីការគោរពសិទ្ធិមនុស្ស និងសុខមាលភាពរបស់ទណ្ឌិតនៅតាមពន្ធនាគារទូទាំងប្រទេស[56] ។ ប៉ុន្តែ ទោះជាបានធ្វើយ៉ាងនេះក្តីក៏ស្ថានភាពនោះនៅខ្វះខាតច្រើនណាស់សំរាប់ស្ថានភាពស្ត្រី និងកុមារដែលនៅជាប់ឃុំឃាំងនោះ[57] ។ បទបញ្ញត្តិដែលទាក់ទងទៅ និងកម្មវិធីការងារការពារស្ត្រី (កូន១របស់ពួកគេ) ព្រមទាំងអនិតិជនត្រូវពួកអ្នកយាម រួមទាំងប្រធានពន្ធនាគារនិយាយចំអកឡកលើយនឹងមើលស្រាល ។ ចំនួនស្ត្រីប្រមាណ ៦% និងអនិតិជន ៤% ក្នុងចំណោមអ្នកជាប់ចោទទាំងអស់នៅកម្ពុជា អាចត្រូវរងការភ័យខ្លាចយ៉ាងខ្លាំងក្លា[58] នឹងទទួលការឈឺចាប់ហួសប្រមាណពីសំណាក់ដោយអ្នកទោសបុរសនៅទីនោះទៀតផង[59] ។

## ស្ថានភាពរស់នៅ

យោងតាមច្បាប់ ស្ត្រី និងអនិតិជនត្រូវបានផ្តល់កិច្ចការពារបន្ថែមនៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌ ។ ជនទាំងនេះតំរូវអោយដាក់នៅក្នុងកន្លែងមួយដាច់ដោយឡែក ហើយដែលអ្នកយាមបុរសចូលទៅពិនិត្យក្នុងអាគារ ឬបន្ទប់ឃុំឃាំងរបស់ស្ត្រី ត្រូវតំរូវអោយមានអ្នកយាមជាស្ត្រីភេទចូលទៅជាមួយដែរ ។ ប៉ុន្តែបញ្ញត្តិនេះមិនសូវបានប្រតិបត្តិតាមទេ ហើយជនជាប់ចោទជាស្ត្រីភេទធម្មតាត្រូវបានដាក់នៅក្នុងអាគារ

---

[56] កិច្ចការនេះជាដំបូងចាប់ផ្តើមដោយអង្គការលីកាដូ អង្គការគ្រូពេទ្យគ្មានព្រំដែនក្នុងឆ្នាំ ១៩៩៤ ។

[57] យោងតាមច្បាប់កម្ពុជា មិនអនុញ្ញាតអោយយកកុមារអាយុក្រោម ១៣ឆ្នាំដាក់ពន្ធនាគារបានទេ ប៉ុន្តែច្បាប់នេះមិនត្រូវបានយកមកអនុវត្តអោយបានត្រឹមត្រូវទេ ។ សូមអាន" Less than Human " អំពើទារុណកម្មនៅកម្ពុជា (ដោយ Jason Barber) កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម (PAT) របាយការណ៍លីកាដូ ខែមិថុនា ឆ្នាំ២000 ទំ.៥១ ។

[58] នៅឆ្នាំ ១៩៩៩ តាមរបាយការណ៍លីកាដូ មានស្ត្រី ១៧៦នាក់ និងអនិតិជន ១២0នាក់នៅក្នុងពន្ធនាគារកម្ពុជា ។ អ្នកទោសទាំងអស់មាន ៣.00៧នាក់ ។ ភាគច្រើននៃស្ត្រីទាំងនេះត្រូវបានឃុំឃាំងដោយសារជំពាក់បំណុល ហើយត្រូវបានឃុំឃាំងក្នុងកន្លែងដែលមានការយាមកាមយ៉ាងតឹងរឹងជាទីបំផុត ។ មានបញ្ជាក់ក្នុង "Less than Human "អំពើទារុណកម្មនៅកម្ពុជា (ដោយ Jason Barber) កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម (PAT) របាយការណ៍លីកាដូ ខែមិថុនាឆ្នាំ២000 ទំ.៥៥ ។

[59] ពាក្យថា "អ្នកទោស" និង "ពិរុទ្ធជន" ត្រូវបានប្រើជាមួយគ្នាសំដៅលើមនុស្សដែលគេឃុំឃាំងនៅក្នុងពន្ធនាគារ ។ ពាក្យនេះប្រើរួមទាំងបុរស និងស្ត្រីដែលត្រូវបានកាត់ទោសរួច (និងកំពុងជាប់ទោស) ព្រមទាំងប្រើលើមនុស្សដែលកំពុងរង់ចាំការកាត់ក្តីផងដែរ ។

ពន្ធនាគាររួមគ្នាទាំងអស់ ហើយត្រូវឃាមកាមដោយឆ្មាំពន្ធនាគារជាបុរស[60] ។ ការស្នាក់នៅសំរាប់ជនជាប់ចោទ "*រួមគ្នា*" ជាធម្មតាមានសភាពក្រខ្វក់ខ្លាំងណាស់ ហើយថែមទាំងបរិវេណចង្អៀតថែមទៀត ដែលអាចនាំអោយមានការខ្វះអនាម័យ និងខ្វះភាពដាច់ដោយឡែក ។ ស្ត្រីម្នាក់បានប្រាប់លីកាដូអោយដឹងថា គាត់ត្រូវ ដាក់នៅក្នុងបន្ទប់មួយតូចចង្អៀតដែលមានមនុស្ស ២៦នាក់[61] ។

សុខភាពរបស់ស្ត្រីនៅក្នុងពន្ធនាគារមានស្ថានភាពធ្ងន់ធ្ងរ ។ មួយភាគបួននៃស្ត្រីដែលបានឆ្លងសម្ភាសន៏នៅក្នុងប្រព័ន្ធព្រហ្មទណ្ឌទាំងអស់បាននិយាយថា ពួកគេមិនដែលបានទទួលការព្យាបាលអោយបានសមរម្យទេ[62] ។ នៅក្នុងពេលខ្លះមានការព្យាបាលតំរូវអោយមានការបង់ប្រាក់ ។ ចំណុចនេះជាការប្រកាសប្រាប់អោយដឹងនូវបរិយាកាសមួយដែលគ្មានអនាម័យ និងការខ្វះខាតអាហារដែលនាំអោយមានជំងឺនានា ជាពិសេសប្រភេទជំងឺឆ្លង ។ ស្ត្រីមួយចំនួនធំមានជំងឺរលាកប្រព័ន្ធបន្តពូជ និងអ្នកផ្ទុក HIV/AIDS ក៏កំពុងរីករាលដាលនៅក្នុងពន្ធនាគារកម្ពុជាផងដែរ ។ ជាធម្មតា ពុំមានការបំបែកជនជាប់ចោទដែលមានជំងឺអោយនៅដាច់ពីគ្នាទេ ធ្វើដូច្នេះជំងឺអាចរាលដាលពាសពេញទាំងពន្ធនាគារតាមរយៈការចាក់សាក់រួម និងអំពើសេពសន្ថវៈជាដើម ។

ការផ្តល់ម្ហូបអាហារមិនបានគ្រប់គ្រាន់នៅពន្ធនាគារនានាជាច្រើន ។ បុគ្គលិកសិទ្ធិមនុស្សបានសន្និដ្ឋានថា រាជរដ្ឋាភិបាលពុំបានគោរពតាមកាតព្វកិច្ចក្នុងការផ្គត់ផ្គង់អ្នកទោសទេ ។ ដូចដែលអ្នកស៊ើបអង្កេតអង្គការសហប្រជាជាតិម្នាក់បានលើកឡើង "មនុស្សដែលត្រូវកាត់អោយជាប់ពន្ធនាគារមិនគួរបង្ខំដាក់ទណ្ឌកម្មដោយវិធីបង្អត់អាហារទេ ។ រដ្ឋាភិបាលមួយដែលមិនអាចចិញ្ចឹមអ្នកទោសបានពុំមានសិទ្ធិរក្សាការឃុំឃាំងពួកគេអោយនៅមួយកន្លែងបានទេ "[63] ។ ស្ត្រីជាមនុស្សដែលងាយរងគ្រោះខ្ពស់ជាងគេនៅពេលដែល ការហូបចុកមិនគ្រប់គ្រាន់ពីព្រោះពួកគេទំនងជាមិនសូវបានទទួលម្ហូបអាហារបន្ថែមខាងក្រៅពីគ្រួសារដូច បុរសទេ ។

---

[60] នៅក្នុងឆ្នាំ ២០០០ តាមរបាយការណ៏បានអោយដឹងថា មានតែពន្ធនាគារព្រៃសមួយទេដែលមានកន្លែងសំរាប់ស្ត្រី និងអនិតិជនដាច់ពីគ្នាសូមអាន "Less than Human" អំពើទារុណកម្មនៅកម្ពុជា (ដោយ Jason Barber) កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម (PAT) របាយការណ៏លីកាដូ ខែមិថុនា ឆ្នាំ ២០០០ ទំ.៥១ ។

[61] ជនគ្មានទោសពៃរ៍ : របាយការណ៏លីកាដូ ស្តីពីសិទ្ធិកុមារដែលធំឡើងនៅក្នុងពន្ធនាគារ (Hilary Margolis), លីកាដូ ខែមិថុនា ឆ្នាំ២០០២ ) ទំ. ២៤ ។

[62] ជនគ្មានទោសពៃរ៍ : របាយការណ៏លីកាដូ ស្តីពីសិទ្ធិកុមារដែលធំឡើងនៅក្នុងពន្ធនាគារ (Hilary Margolis), លីកាដូ ខែមិថុនា ឆ្នាំ២០០២ ) ទំ. ៣ ។

[63] Less than Human " ទារុណកម្មនៅកម្ពុជា (ដោយ Jason Barber) កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម (PAT) របាយការណ៏លីកាដូ ខែមិថុនា ឆ្នាំ២០០០ ទំ.៥៤ ។

អង្គការមនុស្សធម៌ជាច្រើន ដូចជា កម្មវិធីស្បៀងអាហារពិភពលោក និងអង្គការលីកាដូបាន ផ្តល់អាហារបន្ថែមដល់អ្នកទោស ប៉ុន្តែនោះគ្រាន់តែជាការដំណោះស្រាយម្តងម្កាលតែប៉ុណ្ណោះ ហើយទង្វើបែបនេះបានធ្វើអោយរដ្ឋាភិបាលមិនចង់ទទួលខុសត្រូវ ដែលនេះជាភារកិច្ចរបស់រដ្ឋក្នុងការផ្គត់ផ្គង់ថែរក្សាអ្នកទោសទាំងនោះ ។

# ការរំលោភបំពានលើអ្នកទោស និងពិរុទ្ធជន

ការធ្វើទារុណកម្មជាទូទៅ ដែលធ្លាប់មានពីពុនមកលើអ្នកទោសត្រូវបានថយចុះចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ ១៩៩០ មក ។ កត្តានេះអាស្រ័យដោយការពិនិត្យតាមដានយ៉ាងជិតដល់ការបញ្ចុះបញ្ចូល និងការលើកកំពស់នៃការយល់ដឹងដល់អនុរក្សពន្ធនាគារអំពីវិធាន និងបទបញ្ញត្តិនានាក្នុងការគ្រប់គ្រងពិរុទ្ធជនក្រោមការទទួលខុសត្រូវរបស់ពួកគេ ។ ប៉ុន្តែទោះ ជាយ៉ាងក៏ដោយនៅមានពន្ធនាគារជាច្រើននៅតែប្រើប្រាស់ឧបករណ៍ធ្វើទារុណកម្មចាស់ៗ ដើម្បីដាក់អ្នកទោសអោយនៅមួយកន្លែងដូចដើមដដែលព្រមទាំងបញ្ជាអ្នកទោសដូចគ្នា ដើម្បីត្រួតត្រាអ្នកទោសដទៃទៀតក្នុងគោលបំណងដាក់វិន័យលើអ្នកទោសផ្សេងទៀត ។ ការធ្វើទារុណកម្មច្រើនតែប្រព្រឹត្តឡើងជារបៀបទារុណកម្មលាក់កំបាំង និងអាចធ្វើឡើងដោយការវាយដំ ឬរបៀបជាការប្រមាថមើលងាយក៏មាន ។

របៀបធ្វើទារុណកម្មដោយកលល្បិចខ្ពស់មកលើស្ត្រីនៅក្នុងពន្ធនាគារ ដូចជាអំពើរំលោភសេពសន្ថវៈ និងរំលោភផ្លូវភេទបានកើតមានឡើងដោយអ្នកយាម ឬអ្នកគ្រប់គ្រងពន្ធនាគារ ឬអ្នកទោសដូចគ្នា ។ ក្នុងករណីមួយដែលលីកាដូបានស៊ើបអង្កេតលើករណីស្ត្រីម្នាក់ត្រូវបានអ្នកយាមបង្ខំអោយក្លាយទៅជាអ្នកបំរើផ្លូវភេទនៅក្នុងពន្ធនាគារ[64] ។ ករណីមួយដ៏គួរអោយអណោចអធម្ម ដែលអង្គការលីកាដូបានដឹង គឺកើតឡើងនៅពន្ធនាគារខេត្តកោះកុង ក្នុងចន្លោះឆ្នាំ ១៩៩៦-៩៧ :

នៅខែមិថុនា ឆ្នាំ១៩៩៧ ក្រុមគ្រូពេទ្យរបស់អង្គការលីកាដូបានជួបប្រទះស្ត្រីម្នាក់ ដែលកំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយនៃជំងឺអេដស៍របស់ខ្លួន នៅក្នុងបន្ទប់មួយជាមួយនឹងស្ត្រីម្នាក់ទៀតដែលមានកូនបីនាក់ ។ ស្ត្រីម្នាក់ដែលស្គាល់ថា ឈ្មោះ *ទូច* អាយុ ២៧ឆ្នាំ មានជំងឺរ៉ាំរ៉ៃ ។ មន្ត្រីពេទ្យបានឃើញនាងកំពុងដេកត្រាំនៅក្នុងថ្លុកលាមក និងទឹកនោម ។ តាមបញ្ជីពន្ធនាគារ ស្ត្រីឈ្មោះ *ទូច* ត្រូវបានឃុំឃាំងពីឆ្នាំ១៩៩៦ ។ ក្រោយពីចូលមកដល់ពន្ធនាគារភ្លាមមានអ្នកទោសម្នាក់ទៀតបានបបួលនាងឱ្យរត់គេចចេញពីពន្ធនាគារ ។ ជាការឆ្លើយតបទៅនឹងអំពើនោះ អ្នកយាមបានចាប់ស្ត្រីទាំងពីរនាក់សម្រាតខោអាវទាំងអស់ហើយបានរំលោភនាងតាមរន្ធគូថព្រមទាំងយកធាងដូងមកចាក់រន្ធគូថនាងផង ។ ប៉ុន្មាន ខែក្រោយមកស្ត្រីឈ្មោះ *ទូច* នោះត្រូវបានគេវាយដំម្តងទៀត ដោយចោទប្រកាន់ថា នាងបានយករឿងនេះទៅនិយាយប្រាប់មន្ត្រីតុលាការ

[64] ឯកសារដដែល ទំ. ៥១

ប៉ុន្មានឆ្នាំក្រោយមកទៀត *ទូច* ត្រូវអ្នកទោសម្នាក់រំលោភនាងម្តងទៀត ហើយក៏មានផ្ទៃពោះ ។ នៅពេលគ្រូពេទ្យអង្គការលីកាដូទៅពិនិត្យសុខភាពនាង ទើបដឹងថាកូនបានស្លាប់ទាំងនៅក្នុងផ្ទៃទៅហើយ ។ ទោះបីជាគេបានបញ្ជូននាងទៅមន្ទីរពេទ្យកាលពី ពីរ-បីសប្តាហ៍មុន (ដោយមានការស្នើសុំរបស់អង្គការជំនួយផ្នែកច្បាប់កម្ពុជា) នាងត្រូវបាននាំចេញពីមន្ទីរពេទ្យមកវិញមួយថ្ងៃក្រោយ ដោយបុគ្គលិកមន្ទីរពេទ្យបានអះអាងថាពុំមានធនធានគ្រប់គ្រាន់សំរាប់មើលនាងនៅក្នុងមន្ទីរពេទ្យ ។ អង្គការលីកាដូក៏បានរៀបចំអោយនាងបានត្រឡប់ទៅមន្ទីរពេទ្យវិញ ដើម្បីទទួលការព្យាបាល ប៉ុន្តែប៉ុន្មានថ្ងៃក្រោយពីបុគ្គលិកលីកាដូ ចាកចេញពីកោះកុងស្ត្រីរងគ្រោះឈ្មោះ *ទូច* ក៏បានស្លាប់ ។ តាមការពិនិត្យក្រោយពេលស្លាប់បានបង្ហាញនាងមានផ្ទុកមេរោគអេដស៏[65] ។

ករណីស្ត្រីឈ្មោះ *ទូច* បញ្ជាក់នូវអំពើអាក្រក់ដែលគួរអោយស្អប់ខ្ពើមនឹងរន្ធត់ជាទីបំផុតនៅក្នុងប្រព័ន្ធព្រហ្មទណ្ឌកម្ពុជា ។ តាំងពីឆ្នាំ ១៩៩៧ មានការកែលំអក្នុងការថែទាំ និងតម្លាភាព (ទោះបីជាមិនអាចធ្វើបានទាំងអស់ក៏ដោយ) តែទំនងជានៅមានអំពើសាហាវផ្សេងទៀតអាចកើតមានឡើងវិញម្តងទៀត ។ ករណីរបស់ស្ត្រីរងគ្រោះ *ទូច* បានបង្ខិតបង្ខំអោយនាងមិនអោយតក់ស្លុត (ទោះជារឿងនោះជារឿងគួរអោយរន្ធត់ខ្លោចផ្សារជាទីបំផុតក្តី) ប៉ុន្តែជាការបញ្ជាក់សារឡើងវិញនូវតំរូវការអោយមានការប្រុងប្រយ័ត្ននឹងថែទាំជាប្រចាំដល់ស្ត្រីនៅក្នុងពន្ធនាគារកម្ពុជានានា ។

## កុមារធំដឹងក្តីនៅក្នុងពន្ធនាគារ

ច្បាប់កម្ពុជាបានអនុញ្ញាតអោយម្តាយចិញ្ចឹមកូននៅក្នុងពន្ធនាគារ ជាសំណាងដែរដែលចំនួនស្ត្រីមានកូននៅក្នុងពន្ធនាគារមានបរិមាណតិចតួចនៅឡើយ ។ នៅឆ្នាំ ២០០១ អង្គការលីកាដូបានសម្ភាសន៍ម្តាយទាំង ១៣នាក់ ដែលខ្លះកើតកូននៅក្នុងពន្ធនាគារ និងខ្លះទៀតនាំកូនមករស់នៅជាមួយដោយគិតថា គ្មានជំរើសណាផ្សេងទៀតក្នុងការថែទាំពួកគេឡើយ[66] ។ គេបានដឹងព័ត៌មានតិចតួចតែប៉ុណ្ណោះអំពីផលប៉ះពាល់ដល់កុមារទាំងនោះនៅពេលពួកគេធំដឹងក្តីឡើង ដោយស្ថានភាពនៅក្នុងពន្ធនាគារ ។ យោងតាមការស្រាវជ្រាវមួយចំនួន ដែលបានធ្វើឡើង យើងអាចដឹងពីស្ថានភាពក្នុងពន្ធនាគារ ដែលមានភាពយ៉ាប់យ៉ឺនយ៉ាងខ្លាំងសំរាប់កុមារទាំងនោះ ។ ម្តាយភាគច្រើនបានរាយការណ៍ថាកូនៗរបស់ពួកគេមានបញ្ហាសុខភាពជាប្រចាំ

---

[65] Less than Human " អំពើទារុណកម្មនៅកម្ពុជា (ដោយ Jason Barber) កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម (PAT) របាយ ការណ៍លីកាដូ ខែមិថុនា ឆ្នាំ២០០០ ទំ.៥៣ ។

[66] សូមអាន ជនគ្មានទោសពីរក្នុងពន្ធនាគារ : របាយការណ៍របស់លីកាដូស្តីពីសិទ្ធិកុមារធំដឹងក្តីនៅក្នុងពន្ធនាគារ (Hilary Margolis), លីកាដូ ខែមិថុនា ឆ្នាំ២០០២ ។

ដោយគ្មានម្ហូប អាហារគ្រប់គ្រាន់ និងមានឱកាសរៀនសូត្របានតិចតួចបំផុត[67] ។ បញ្ហាគួរអោយបារម្ភផ្សេងទៀត ដែលបុគ្គលិកលីកាដូបានសង្កេតឃើញ គឺភាពងាយរងគ្រោះរបស់កុមារពីសំណាក់ការរំលោភបំពានរបស់អ្នកយាម និងអ្នកទោសដទៃៗទៀត (ជាពិសេសជនល្មើសក្នុងករណីរំលោភនៅក្នុងបន្ទប់ឃុំឃាំងក្បែរៗនោះ) ។ បញ្ហា មួយទៀតដែលអាចបន្ទុចបង្អាក់ដល់ការលូតលាស់ផ្នែកសុខមាលភាពកុមារ គឺខ្វះការណែនាំល្អសំរាប់ពួកគេ ។ នៅក្នុងឆ្នាំ២០០២ លីកាដូ គឺជាអង្គការមិនមែនរដ្ឋាភិបាលតែមួយគត់ ដែលបានស្រាវជ្រាវអំពីបញ្ហានេះ ហើយផ្គត់ផ្គង់ម្ហូបអាហារ និងការព្យាបាលចំពោះកុមារដែលធំដឹងក្តីនៅក្នុងពន្ធនាគារ ។

## អនុសាសន៍

- បន្តការត្រួតពិនិត្យតាមដានយ៉ាងប្រុងប្រយ័ត្ន អំពីសិទ្ធិមនុស្ស និងសុខភាពនៅក្នុងពន្ធនាគារនានាទូទាំងប្រទេស ដើម្បីបង្កើនតម្លាភាពនៅក្នុងប្រព័ន្ធព្រហ្មទណ្ឌ ។
- អប់រំអ្នកយាម និងមន្ត្រីគ្រប់ថ្នាក់អំពីបទបញ្ញត្តិនានាពាក់ព័ន្ធនឹងការឃុំឃាំងនៅក្នុងពន្ធនាគារ ។ ដាក់ទណ្ឌកម្មអោយបានតឹងរឹង ប្រសិនបើប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនេះ។
- ត្រូវដាក់ស្ត្រី និងអនិតិជនអោយនៅក្នុងកន្លែងឃុំឃាំងដាច់ដោយឡែក ។
- បង្កើនចំនួនអ្នកយាមជាស្ត្រីភេទអោយបានច្រើន ។
- បញ្ចុះបញ្ចូលរដ្ឋាភិបាលអោយផ្តល់ធនធានថែមទៀត ដើម្បីផ្គត់ផ្គង់ម្ហូបអាហារថែទាំ សុខភាព និងការអប់រំដល់អ្នកទោស ។
- បន្តការស្រាវជ្រាវនឹងការពារដល់កុមារដែលធំដឹងក្តីឡើងក្នុងពន្ធនាគារ ។

---

[67] អ្នកស្រាវជ្រាវបានរៀបរាប់នូវអ្វីដែលគេបានរកឃើញដោយទទួលស្គាល់ថាស្ត្រីទាំងនោះមិនអាចរៀបរាប់ប្រាប់ អោយអស់ដូចដែលពួកគេចង់ទេ ដោយមានវត្តមានអ្នកយាមនៅទីនោះ ។ សូមអាន : ជនគ្មានទោសពៅក្នុងពន្ធនាគារ : របាយការណ៍របស់លីកាដូស្តីពីសិទ្ធិកុមារធំដឹងក្តីនៅក្នុងពន្ធនាគារ (Hilary Margolis), លីកាដូ ខែមិថុនា ឆ្នាំ២០០២ ទំ. ២០-២១ ។

## VII- ស្ត្រីនៅតាមជនបទ

### មាត្រា ១៤

*១- រដ្ឋភាគីទាំងឡាយត្រូវគិតគូរដល់បញ្ហា ជាពិសេសដែលនារីនៅជនបទត្រូវប្រឈមមុខព្រមទាំងតួនាទីដ៏សំខាន់របស់នារីនៅជនបទក្នុងការរស់រានផ្នែកសេដ្ឋកិច្ចសំរាប់ គ្រួសាររបស់ពួកគេរួមបញ្ចូលទាំងការងាររបស់នារីទាំងនោះនៅក្នុងវិស័យគ្មានចំណូលនៃសេដ្ឋកិច្ចទៀតផង ហើយរដ្ឋភាគីទាំងឡាយត្រូវប្រកាន់យកនូវវិធានការសមស្របនានា ដើម្បីធានាដល់ការអនុវត្តន៏បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះចំពោះនារីនៅជនបទផង ។*

*២- រដ្ឋភាគីទាំងឡាយត្រូវអនុវត្តវិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទនៅជនបទ ដើម្បីអោយអ្នកទាំងនោះអាចចូលរួម និងទទួលបាននូវអត្ថប្រយោជន៍ពីកិច្ចអភិវឌ្ឍន៍...*

នៅឆ្នាំ ២០០៣ ប្រជាជនកម្ពុជា ៨៤% ដែលរស់នៅតាមជនបទក្តីមាន ៩០% នៃពលរដ្ឋដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រនៃតំបន់ជនបទ គឺភាគច្រើនជាស្ត្រីភេទ[68] ។ ស្ថានភាពស្ត្រីកម្ពុជានៅជនបទគឺមានភាពស្មុគស្មាញ និងភាពមិនស្រួលស្រណុកយ៉ាងខ្លាំង ។ ក្រៅពីប្រពៃណីរើសអើងជាទូទៅដែលអាចឆ្លុះបញ្ចាំងឃើញយ៉ាងលើសលុបនៅក្នុងប្រទេសអាស៊ីភាគអាគ្នេយ៍ជាច្រើន ស្ត្រីកម្ពុជាត្រូវប្រឈមមុខនឹងបញ្ហាដ៏ធំ (គ្មានពីរ) ទាក់ទងទៅនឹងប្រវត្តិសាស្ត្រ និងបរិបថផ្នត់គំនិតនយោបាយសង្គមរបស់កម្ពុជា ។

## ការវិលវល់នៃវឌ្ឍន៍ភាពក្រីក្រទៅនិងឧបសគ្គ ដែលប្រឈមនឹងការអភិវឌ្ឍន៍សំរាប់ស្ត្រីជនបទ

តាមការប៉ាន់ស្មានបានអោយដឹងថា ៥០%នៃស្ត្រីជនបទ គឺមិនចេះអក្សរ និងមិនបានបញ្ចប់បឋមសិក្សា[69] ។ តាមតួលេខនេះ មួយផ្នែកយើងអាចពន្យល់បានថាដោយសារសាលារៀនមួយចំនួនធំត្រូវបានបំផ្លិចបំផ្លាញនៅក្នុងសម័យខ្មែរក្រហម និងការរំខានដោយសង្គ្រាមស៊ីវិល ដែលបន្តរហូតមកដល់ទសវត្សឆ្នាំ១៩៩០ ។ បញ្ហានេះក៏អាចយល់បានដែរនៅក្នុងបរិបថប្រពៃណីដែលមានស្រាប់ចំពោះស្ត្រី និងការខ្វះខាត

---

[68] យេនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ (ផ្នែកអង្គការមិនមែនរដ្ឋាភិបាល និងបញ្ហា- ឯកសារស្តីពីការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០០៣) ទំ. ៣៧ ។

[69] ឯកសារដដែល ។

ធនធានជាទូទៅក្នុងការចំណាយសំរាប់ការសិក្សា ។ កង្វះការអប់រំជារបាំងរាំងស្ទះមួយយ៉ាងធំដល់ស្ត្រីក្នុងការយល់ដឹងអំពីសិទ្ធិស្មើភាព និងការពារតាមផ្លូវច្បាប់របស់ខ្លួន ។ បញ្ហានេះអាចធ្វើអោយពួកគេងាយរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងអំពើរំលោភបំពានដែលចេះតែកើតមានឡើងមិនឈប់ឈរ។ វាអាចធ្វើអោយលំបាកផងដែរដល់ស្ត្រីជនបទក្នុងការទំលុះទំលាយភាពក្រីក្រ ដែលមានគ្របសង្កត់ជានិរន្តដោយគ្រាន់ធ្វើការស្តារនៅក្នុងវិស័យកសិកម្ម ដែលពុំមែនជាវិស័យអាជីវកម្មពាណិជ្ជកម្ម ។

បញ្ហាដ៏ធ្ងន់ធ្ងរមួយទៀត ដែលប៉ះពាល់ដល់ស្ត្រីជនបទកម្ពុជា គឺបញ្ហាជំងឺ និងពិការភាព ។ តាមរបាយការណ៍របស់កិច្ចអភិវឌ្ឍន៍អង្គការសហប្រជាជាតិនៅ ឆ្នាំ២០០៣ បានលាតត្រដាងអោយដឹងថាមានបុគ្គលិកសុខាភិបាលរបស់រដ្ឋាភិបាលតែ១៣% ប៉ុណ្ណោះដែលរស់នៅជនបទ ដូចនេះហើយទើបជំងឺដែលអាចព្យាបាលបានជាច្រើនក្លាយទៅជាជំងឺធ្ងន់ធ្ងរ ដោយពុំមានការយកចិត្តទុកដាក់ក្នុងការព្យាបាលអោយបានជិតដល់និងទាន់ពេល ។ បញ្ហានេះ បានធ្វើអោយសមត្ថភាព និងការគាំទ្រគ្រួសាររបស់ស្ត្រីជនបទចុះទន់ខ្សោយយ៉ាងខ្លាំង ។

ថ្វីត្បិតតែមានការខិតខំប្រឹងប្រែងរបស់ក្រុមបោសសំអាតមីនជាច្រើន កម្ពុជានៅតែជាប្រទេសមួយដែលសំបូរដោយគ្រាប់មីននៅលើពិភពលោក ហើយថែមទាំងមានសមាមាត្រជនពិការបុរស និងស្ត្រីខ្ពស់ទៀតផង ។ ស្ត្រីពិការច្រើនតែជឹតជាប់នូវស្លាកស្នាមសុបិន្តអាក្រក់ និងត្រូវបានគេរើសអើងនៅក្នុងសហគមន៍ព្រមទាំងមិនងាយរកគូរស្រករបានទេ ។ ស្ថានភាពស្ត្រីមេគ្រួសារនោះកាន់តែគ្រោះថ្នាក់ថែមទៀតនៅពេលដែលអ្នករកប្រាក់ចំណូល តែម្នាក់ឯង គឺជាមនុស្សបាត់បង់សមត្ថភាពដែលត្រូវរកប្រភពចំណូលផ្សេងៗទៀតនោះ។

រាជរដ្ឋាភិបាលកម្ពុជា (ជាពិសេស ក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជនក៏ដូចជា អង្គការផ្តល់មូលនិធិ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានផ្តួចផ្តើមកម្មវិធីជាច្រើន ដើម្បីដោះស្រាយបញ្ហាការងារស្ត្រីនៅជនបទ ។ ជាពិសេសអង្គការ UNDP នៅកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីដៃគូរ ដើម្បីសមភាពយេនឌ័រ (Partnership for Gender Equity, PGE, ) និងយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ ។ នៅដើមឆ្នាំ ២០០៣ UNDP បានបញ្ជាក់អោយដឹងថា កម្មវិធី PGE ដែលជាដៃគូរជាមួយនឹងក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជនជាមួយធនាគារពិភពលោកបានធ្វើការស្វែងរកមតិគាំទ្រដោយជោគជ័យ ក្នុងការបញ្ចូលបញ្ហាសមភាពយេនឌ័រទៅក្នុងយុទ្ធសាស្ត្រជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ គឺត្រូវបានចាត់ទុកថាជាជោគជ័យមួយក្នុងចំណោមជោគជ័យនានានៅលើពិភពលោក ចំពោះការបញ្ជ្រាបយេនឌ័រ[70] ។

[70] ដៃគូរដើម្បីសមភាពយេនឌ័រ (កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ UNDPឆ្នាំ ២០០៣) ទំ. ១ ។

## ស្ត្រីមេគ្រួសារ

ភាពក្រីក្រយ៉ាងច្រើនលើសលុបមាននៅក្នុងបញ្ហាដែលស្ត្រីជាមេគ្រួសារ (FHH) ។ ជាពិសេសស្ត្រីជាមេគ្រួសារងាយរងគ្រោះអំពីបញ្ហាបាត់បង់ដីធ្លី ។ យោងតាមការសិក្សាស្រាវជ្រាវដែលធ្វើឡើងនៅឆ្នាំ ២000 ជាមធ្យមមួយគ្រួសារមានដីមួយហិកតា ប៉ុន្តែគ្រួសារ ដែលស្ត្រីជាមេគ្រួសារនោះមានដីត្រឹមតែជាង 0. ៥0 ហិកតាតែប៉ុណ្ណោះ[71] ។ ទំហំដីនេះ មិនគ្រប់គ្រាន់ទេសំរាប់គ្រួសារមួយដែលមានសមាជិក ៤នាក់ក្នុងការចិញ្ចឹមជីវិត ។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារក៏ងាយគ្រោះថ្នាក់ និងរងការបំភិតបំភ័យថែមទៀតពីសំណាក់ពួកអ្នកដើររឹបអូសដីធ្លីដែលទាមទារយកដីរបស់ពួកគេ ។ ស្ត្រីពុំមានធនធានអ្វីដើម្បីទប់ទល់នឹងការទាមទារយកដីនេះនៅក្នុងប្រព័ន្ធតុលាការទេ ហើយអាចជាមនុស្សដែលគេរើសអើងក្នុងការកាត់ក្តីនៅក្នុងសហគមន៍ ។

សមាមាត្រដ៏ធំមួយនៃស្ត្រីមេគ្រួសារ គឺជាគ្រួសារអតីតៈយុទ្ធជន ។ មិនដូចនៅប្រទេសវៀតណាមជាប្រទេសជិតខាងទេ ដែលស្ត្រីជាគ្រួសារអតីតៈយុទ្ធជនត្រូវបានគេគោរព និងផ្តល់របបសោធន ចំណែកស្ត្រីមេម៉ាយនៅកម្ពុជាវិញ ពុំមានការគាំទ្រពីរដ្ឋាភិបាលទេ ។ ភាពស្មុគស្មាញនៃសង្គ្រាមស៊ីវិលដ៏រំជើបរំជួលបានញាំញីកម្ពុជាអស់រយៈពេលជាច្រើនទសវត្សបានធ្វើអោយបញ្ហាផ្តល់សោធនក្លាយទៅជាបញ្ហានយោបាយដ៏ស្មុគស្មាញមួយ ដែលពិបាកដោះស្រាយនៅក្នុងសម័យកាលស្តារឡើងវិញក្រោយសង្គ្រាមថ្មីៗនេះ ។

## ស្ត្រីក្នុងការកែទំរង់ជនបទ និងកិច្ចអភិវឌ្ឍន៍សហគមន៍

តំរូវការរីកចំរើននៃនយោបាយវិមជ្ឈការថ្មីៗនៅកម្ពុជាបានផ្តល់ឱកាសមួយដល់ស្ត្រីក្នុងការចូលរួមក្នុងវេទិការសំរេចចិត្តនៅថ្នាក់មូលដ្ឋាន ។ ក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជន រួមជាមួយកម្មវិធីសីលាបានលើកទឹកចិត្តការបញ្ជ្រាបយេនឌ័រទៅក្នុងប្រព័ន្ធវិមជ្ឈការ តាំងពីឆ្នាំ១៩៩៨ ស្ត្រីមានត្រឹមតែ ៤0% នៅក្នុងតំណាង ឃុំក្នុងខេត្តភាគខាងលិចនៃប្រទេសកម្ពុជា[72] ។ ប៉ុន្តែ ស្ថិតិនេះមិនបានប្រាប់យើងថាតើស្ត្រីអាចទទួលការតែងតាំងរបស់ពួកគេប្រកបដោយប្រសិទ្ធិភាព ឬក៏ពួកគេគ្រាន់តែមានឈ្មោះកាន់ដំណែងសាមញ្ញតែប៉ុណ្ណោះទេ។ ចំពោះបញ្ហានេះតំរូវអោយមានការសិក្សាស្រាវជ្រាវបន្ថែមទៀត បើប្រៀបធៀបទៅ នឹងការ

---

[71] កម្មសិទ្ធិដីធ្លី : លក់ និងការប្រមូលផ្តុំនៅកម្ពុជា: ការពិនិត្យសារឡើងវិញនូវទិន្នន័យប្រភេទទី ២ និងទិន្នន័យ ប្រភេទទី ១ ពីការសិក្សាស្រាវជ្រាវ ៤ ថ្មីៗ- ឯកសារការងារ ១៦ ( វិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា ឆ្នាំ២000) ។ បញ្ជាក់នៅក្នុងរបាយការណ៍ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅកម្ពុជា (គណៈកម្មការអង្គកាមិនមែនរដ្ឋាភិបាលស្តីពី CEDAW ឆ្នាំ២00១ )ទំ. ៤៨ ។

[72] របាយការណ៍ដំបូង ទី ២ និង ទី ៣ ស្តីពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅកម្ពុជា ( រាជរដ្ឋាភិបាលកម្ពុជា ខែតុលា ឆ្នាំ២00៣ ) ទំ. ៣៩ ។

រកឃើញនៅវៀតណាមបានលាតត្រដាងអោយឃើញថា ស្ត្រីនៅក្នុងរដ្ឋាភិបាលជនបទត្រូវបានបង្ករការលំបាកនឹងចាញ់បញ្ឆោតដោយសហការីបុរសរបស់ពួកគេ ។

## ស្ត្រីក្នុងវិស័យកសិកម្ម

ការលំបាកដែលស្ត្រីប្រឈមមុខក្នុងវិស័យកសិកម្មនឹងត្រូវបានលើកយកមកពិភាក្សាលំអិតនៅក្នុងផ្នែកទី VIII (ស្ត្រីក្នុងការងារ) ។ ជាការល្អបំផុតដែលលើកឡើងយកមកបញ្ជាក់ម្តងហើយម្តងទៀតអំពីសារសំខាន់ក្នុងការរួមចំណែករបស់ស្ត្រីនៅក្នុងវិស័យកសិផលិតកម្ម ដែលច្រើនតែត្រូវគេមិនសូវអោយតំលៃនោះ ។ តាមការគណនាស្ត្រីមាន ៦៥%ក្នុងវិស័យកសិកម្ម និង៨០% ក្នុងវិស័យផលិតកម្មម្ហូបអាហារ ពួកគេគួរតែជាគោលដៅដែលត្រូវទទួលបានផលប្រយោជន៍ពីគំរោងមីក្រូឥណទាន និងគំរោងផ្សព្វផ្សាយកសិកម្មនានាអោយបានសមរម្យ ។ គួរតែមានការលើកទឹកចិត្តស្ត្រី អោយចូលរួមហ្វឹកហ្វឺនធ្វើជាមន្ត្រីផ្សព្វផ្សាយសំរាប់ជាភ្នាក់ងារកសិកម្មអោយបានច្រើន គឺអាចធ្វើឱ្យប្រសើរឡើងដល់ស្ថានភាពស្ត្រីទូទៅនៅក្នុងសហគមន៍ ។

## អនុសាសន៍

- តំរូវអោយមានមូលនិធិបន្ថែមទៀត ដើម្បីអោយស្ត្រីនៅជនបទមានលទ្ធភាពទទួលបាននូវសេវាព្យាបាល និងលទ្ធភាពបណ្តុះបណ្តាលអប់រំកាន់តែប្រសើរឡើង ។
- បន្តផ្តល់មូលនិធិនឹងគាំទ្រដល់សកម្មភាពបោសសំអាតមីន ។
- ភាពចាំបាច់ ការពិនិត្យតាមដាននូវលទ្ធផលនិងសមិទ្ធិផលនៃការបញ្ជ្រាបយេនឌ័រនៃយុទ្ធសាស្ត្រជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រអោយមានប្រសិទ្ធិភាព ។
- ត្រូវមានការសិក្សាស្រាវជ្រាវបន្តទៀតអំពីតួនាទីអភិវឌ្ឍន៍សហគមន៍ និងគោលនយោបាយដែលស្ត្រីអាចដើរតួបាននៅក្នុងវេទិការអភិបាលកិច្ចជនបទ និងអភិវឌ្ឍន៍សហគមន៍ ។
- ស្រីត្រូវបានលើកទឹកចិត្ត និងផ្តល់ទំនុកចិត្តក្នុងការចូលរួមយ៉ាងសកម្មនូវរាល់ការសំរេចចិត្តក្នុងកិច្ចអភិវឌ្ឍន៍សហគមន៍ ។
- គំរោងមីក្រូឥណទាន និងការផ្សព្វផ្សាយកសិកម្មគួរផ្តោតលើគោលបំណងស្ត្រីអោយបានច្រើន ។ គួរលើកទឹកចិត្តអោយស្ត្រីភេទធ្វើជាអ្នកហ្វឹកហ្វឺន និងអ្នកសម្របសម្រួលនៅក្នុងគំរោងការនេះ ។
- គួរតែបង្កើនថវិកាដល់ក្រសួងកសិកម្ម ដើម្បីអោយឆ្លើយតបទៅនឹងភាគរយប្រជាជនដ៏ខ្ពស់នៅក្នុងវិស័យនេះ ។

# VIII - ស្ត្រី និងសុខភាព

## មាត្រា ១២

> *១- រដ្ឋភាគីត្រូវប្រកាន់យកនូវរាល់វិធានការសមស្រប ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទនៅក្នុងវិស័យសុខាភិបាល ដើម្បីធានាការទទួលបាននូវកិច្ចការ ដែលទាក់ទិនទៅនឹងផែនការគ្រួសារថែមទៀតផង ។*
>
> *២- ក្រៅពីបញ្ញត្តិដែលបានចែងនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ រដ្ឋភាគីទាំងឡាយត្រូវធានាដល់នារីភេទនូវរាល់សេវាសមស្រប ដែលទាក់ទងទៅនឹងការពរពោះ ការសំរាលកូន និងក្រោយសំរាលកូន ដោយផ្តល់សេវាទាំងឡាយឥតគិតថ្លៃ ប្រសិនបើជាចាំបាច់កាផ្តល់នូវម្ហូបអាហារមានជីវជាតិក្នុងរយៈពេលពរពោះ និង ពេលបំបៅកូនផងដែរ ។*

បញ្ហាសុខភាពរបស់ពលរដ្ឋកម្ពុជាទាំងអស់ត្រូវបានចែងនៅក្នុងមាត្រា ៧២ នៃរដ្ឋធម្មនុញ្ញដែលសង្កត់ធ្ងន់ទៅលើការមិនរើសអើងក្នុងវិស័យសុខាភិបាល ព្រមទាំងការពិគ្រោះយោបល់ផ្នែកពេទ្យដោយឥតគិតថ្លៃដល់ពលរដ្ឋក្រីក្រ ។ រដ្ឋាភិបាលកម្ពុជាមានមោទនភាពចំពោះប្រព័ន្ធសុខាភិបាលជាតិរបស់ខ្លួនដែលបានទទួលការគាំទ្រយ៉ាងច្រើនពីសំណាក់អង្គការមូលនិធិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ។ ចំពោះមោទនភាពនេះ វាមានការជឿនលឿនខ្លះ ដូចដែលមានការអភិវឌ្ឍន៏ពិត១នៅលើចំណុចសុច្ចនករ (បង្ហាញ) សំខាន់១ដូចជាអត្រាអាយុរំពឹងទុករបស់ស្ត្រី អត្រាមរណៈកុមារ និងមាតាជាដើម[73] ។ ប៉ុន្តែយោងតាមរបាយការណ៏របស់រាជរដ្ឋាភិបាលហាក់ដូចជាមានចេតនាលាក់បាំងនូវភាពខុសគ្នាយ៉ាងធំ រវាងសេវាសុខភាពនៅជនបទ និងនៅទីក្រុង ព្រមទាំងការរាលដាលនៃជំងឺអេដស៏ដ៏គួរអោយភ័យខ្លាចក្នុងចំណោមស្ត្រីកម្ពុជាទាំងឡាយ ។

## លទ្ធភាពក្នុងការទទួលបានសេវាសុខភាពមានគុណភាព

របាយការណ៏ផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការអនុវត្តន៏អនុសញ្ញាស្តីពីការលប់បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) បានបញ្ជាក់ថា មានមន្ទីរពេទ្យជាតិចំនួន ៨កន្លែង

---

[73] គួរកត់សំគាល់ថា ទោះជាមានសញ្ញាថាសុខភាពស្ត្រីមានការកើនឡើងនៅក្នុងទសវត្សកន្លងទៅក្តី ក៏អត្រាមរណៈរបស់កុមារ និងមាតានៅតែខ្ពស់ជាងប្រទេសនានានៅអាស៊ី ។

មន្ទីរពេទ្យបង្អែកខេត្ត ២៤ មន្ទីរពេទ្យបង្អែកស្រុកចំនួន ៤៤ និងមណ្ឌលសុខភាពចំនួន ៨១២កន្លែងក្នុងឆ្នាំ ២០០៣ ។ មណ្ឌលសុខភាពនិមួយៗផ្តល់សេវា ដល់ប្រជាពលរដ្ឋពី ៨.០០០-១២.០០០ នាក់ [74] ។

នៅក្នុងការបដិបត្តិមានការប្រមូលផ្តុំចំពោះបុគ្គលិកសុខាភិបាល និងសេវាកម្មនៅក្នុងទីក្រុង និងទីប្រជុំជននានា ហើយមានតិចតួចបំផុតនៅតាមជនបទ ។ គណៈកម្មការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាស្តីពីអនុសញ្ញា (CEDAW) បានធ្វើការប៉ាន់ប្រមាណនៅក្នុងការវាយតំលៃមធ្យោបាយសុខាភិបាលនៅជនបទថាប្រហែល៤០% នៃស្ត្រីជនបទជួបប្រទះការលំបាកអំពីការដឹកជញ្ជូនភោគផល[75] ។ ស្ត្រីនៅជនបទ និងនៅទីក្រុងបានបញ្ជាក់ដូចគ្នាពីការលំបាកថែមទៀតអំពីបញ្ហាថ្លៃខ្ពស់ពេកក្នុងសេវាព្យាបាលជម្ងឺ ព្រមទាំងការ លំបាកក្នុងការជួបពិគ្រោះគ្រូពេទ្យខាងផ្នែកសុខភាពស្ត្រី ។

និយាយជាទូទៅ ក៏រិតជំនាញឯកទេសរបស់បុគ្គលិកសុខាភិបាលសាធារណៈត្រូវបានចាត់ទុកថានៅទាបនៅឡើយ ហើយជាពិសេសនៅតាមតំបន់ដាច់ស្រយ៉ាលនៃប្រទេសកម្ពុជាតែម្តង ។ ប្រាក់ខែរបស់បុគ្គលិកសុខាភិបាលដែលមានសមត្ថភាពស្ទួចស្តើងជាទីបំផុត ហើយចាំបាច់ត្រូវរកការងារធ្វើក្នុងគ្លីនិកឯកជន ដើម្បីរកប្រាក់ចំណូលបន្ថែម ឬយកថ្លៃខ្ពស់ទៅលើសេវាដែលខ្លួនបានផ្តល់ ។ ដរាបណាប្រាក់បៀវត្សរដ្ឋនៅតែទាប ហើយគ្មានការលើកទឹកចិត្តដល់បុគ្គលិកសុខាភិបាល ដែលចេញទៅធ្វើការនៅតំបន់ជនបទដាច់ស្រយាលនោះ ទំនងជាគុណភាពសេវាសុខភាពសាធារណៈនឹងពុំមានភាពប្រសើរជាងមុនទេ ។

## ការគាំពារមាតាទារក

កន្លងមកមានការលូតលាស់ប្រសើរឡើងគួរអោយកត់សំគាល់អំពីអត្រាមរណៈមាតាដែលថយពីការស្លាប់ ៩០០នាក់ ក្នុងចំណោមការផ្តល់កំណើតចំនួន ១០០.០០០នាក់ក្នុងឆ្នាំ ១៩៨៩ មកនៅត្រឹមតែ ៤៣៧ នាក់ក្នុងឆ្នាំ ២០០០[76] ។ ទោះជាយ៉ាងនេះក្តីក៏នៅមានស្ត្រីជាង ២០០.០០០ រងគ្រោះពីការមានផ្ទៃពោះប្រកបដោយភាពស្មុគស្មាញក្នុងមួយឆ្នាំៗ[77] ។ បញ្ហាទាំងនេះកើតឡើងដោយសារតែភាពក្រីក្រ ដែលនាំអោយមានជំងឺជាធម្មតាដូចជាជំងឺខ្វះឈាមជាដើម ប៉ាន់ស្មានមើលទៅមានស្ត្រីមានផ្ទៃពោះ ៦៦% ដែលបាន

---

[74] របាយការណ៍ដំបូង របាយការណ៍ទី២ និងទី៣ ស្តីពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ ទំរង់នៃការរើសអើងប្រឆាំង នឹងនារីភេទនៅកម្ពុជា ( រាជរដ្ឋាភិបាលកម្ពុជា ខែតុលា ឆ្នាំ២០០៣) ទំ. ៦៩

[75] របាយការណ៍ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅកម្ពុជា (គណៈកម្មការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាស្តីពី CEDAW ឆ្នាំ ២០០១ ) ទំ. ៤៣ ។

[76] ការសិក្សាស្រាវជ្រាវអំពីប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ ២០០០ : របាយការណ៍ដំបូង (វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ និងក្រសួងសុខាភិបាល ឆ្នាំ២០០០ ) ទំ. ១៧ ។

[77] យេនឌ័រ និងការកាត់បន្ថយភាពក្រីក្រ-ឯកសារនៃផ្នែកអង្គការមិនមែនរដ្ឋាភិបាល និងបញ្ហានានាស្តីពីការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០០៣ ទំ. ៣៩ ។

រងគ្រោះ ដោយសារជំងឺនោះ[78] ។ ឧបសគ្គដែលនាំអោយពិបាករកការថែទាំមាតា ដែលមានគុណភាពសមរម្យ ក៏ជាកត្តារួមចំណែកសំខាន់មួយដែលនាំអោយមានកំណើនមរណៈទារក និងមាតាផងដែរ ។ ស្ត្រីមួយចំនួន ជាពិសេសស្ត្រី ដែលរស់នៅជនបទច្រើនទទួលការជួយសម្រាលកូនដោយសារតែសេវាគ្មាន គុណភាព (ហៅថាឆ្មបជនបទ) ។ ឆ្មបជនបទត្រូវបានចាត់ទុកថាជាមនុស្ស ដែលគេទុកចិត្តនៅក្នុងភូមិ -ឃុំ ពួកគេអនុវត្ត បែបបុរាណដែលអាចធ្វើអោយមានបញ្ហាដល់មាតា និងទារក ដូចជាការហាមមិនអោយបរិភោគអាហារ ដែលមានរសជាតិមួយចំនួន ហើយមាតាអាចបរិភោគបាន ព្រមទាំងមិនអនុញ្ញាតអោយមាតាបំបៅដោះកូនរយៈពេលពីរថ្ងៃក្រោយសំរាលកូនជាដើម ។ ក្រសួងសុខាភិបាលបានប្រកាសថា នៅខ្វះឆ្មបដែលមានការហ្វឹកហ្វឺនត្រឹមត្រូវចំនួន ១000នាក់ក្នុងឆ្នាំ ២00៣ ហើយព្រមទាំងបានសន្យាថានឹងជំរុញកម្មវិធីហ្វឹកហ្វឺនឆ្មបនេះ[79] ។ ការស្រាវជ្រាវរបស់លីកាដូបានបង្ហាញថា ចំនួននេះអាចប៉ាន់ស្មានខុសពីចំនួនគិលានុប្បដ្ឋ ដែលត្រូវបានហ្វឹកហ្វឺនធ្វើជាឆ្មប ដោយអង្គការមិនមែនរដ្ឋាភិបាលនានាដូចជា អង្គការគ្រូពេទ្យគ្មានព្រំដែនជាដើមដែលធ្លាប់បានបំពេញការងារយ៉ាងសកម្ម ក្នុងគំរោងសុខភាពមាតាទារកនៅជនបទទូទាំងប្រទេសកម្ពុជា ។

## ការពន្យាកំណើត

នៅក្នុងឆ្នាំ២00៣ អត្រាកំណើតបានថយចុះមកនៅត្រឹមស្ត្រីម្នាក់មានកូន ៤នាក់ដែលជាការបង្ហាញនូវការថយចុះ ១,៤% នៅក្នុងរយៈពេល ១0 ឆ្នាំកន្លងមកនេះ ។ ការថយចុះនេះមានការទាក់ទងទៅការអប់រំបានល្អ និងការយល់ច្បាស់អំពីការអនុវត្តន៍នូវការពន្យារកំណើត ។ តាមការស្រាវជ្រាវបានអោយដឹងថាបច្ចុប្បន្ននេះមានស្ត្រី ២៤% កំពុងប្រើប្រាស់បច្ចេកទេសការពារកុំអោយមានកំណើត និងការពន្យាកំណើតដែលចំនួននេះមាន ១% តែប៉ុណ្ណោះក្នុងឆ្នាំ ១៩៩៥[80] ។ ប៉ុន្តែនៅតែត្រូវការអោយមានការផ្សព្វផ្សាយព័ត៌មានអំពីកិច្ចការពារកំណើតដោយផ្ទាល់មាត់នៅតាមជនបទ ដែលមានការយល់ដឹងតិចតួច ព្រមទាំងមានសមត្ថភាពក្នុងការបង្កើតកូនច្រើននៅឡើយ ។

តាមការសិក្សាស្រាវជ្រាវអំពីប្រជាសាស្ត្រកម្ពុជា និងសុខភាព នៅឆ្នាំ២000 បានប៉ាន់ស្មានថាស្ត្រី ៦%ដែលបានសម្ភាសន៍សុទ្ធតែធ្លាប់រំលូតកូន ហើយស្ត្រី ៣0% ក្នុងចំណោមស្ត្រីខាងលើនេះនិយាយថា ពួក

---

[78] របាយការណ៍ដំបូង ទី២ និងទី៣ អំពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិ ស្តីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ខែតុលា ឆ្នាំ២00៣) ទំ ៧៤ ។

[79] របាយការណ៍ដំបូង ទី២ និងទី៣ អំពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិស្តីការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំង នឹងនារីភេទនៅកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ខែតុលា ឆ្នាំ២00៣) ទំ ៧២ ។

[80] ដកស្រង់ចេញពីប្រភពឯកសារដដែល ។

គេបានរំលូតកូននៅផ្ទះជាធម្មតា ហើយមានការជួយដោយឆ្មប[81] ។ អំពីបញ្ហារំលូតកូននៅកម្ពុជាស្រ្តីធ្វើឡើងក្នុងការលាក់កំបាំង ព្រមទាំងនៅមានការអៀនខ្មាស់យ៉ាងខ្លាំងជាទីបំផុត ។ បញ្ហានេះអាចរារាំងស្រ្តីក្នុងការរកការពិគ្រោះ និងដំបូន្មានពីគ្រូពេទ្យដែលមានជំនាញខ្ពស់ ។ ដូច្នេះតំរូវអោយមានការអប់រំថែមទៀតអំពីទីកន្លែង និងរបៀបដែលស្រ្តីអាចរកគ្រូពេទ្យជំនាញ ដើម្បីជួយក្នុងការរំលូតកូនចេញ ។

# អនុសាសន៍

- តំរូវអោយមានការស្រាវជ្រាវលំអិតថែមទៀតស្តីពីសូចនករសុខភាពបច្ចុប្បន្ននៅកម្ពុជា ។ បច្ចុប្បន្ននេះហាក់ដូចជាមានការពឹងផ្អែកទៅលើការសិក្សាស្រាវជ្រាវអំពីប្រជាសាស្រ្ត និងសុខភាពឆ្នាំ២០០០ យ៉ាងលើសលុប ។ របាយការណ៏នេះត្រូវតែធ្វើអោយមានព័តិមានថ្មីថែមទៀត ។
- កែលំអគុណភាពប្រព័ន្ធសុខមាលភាពសាធារណៈជាទូទៅតាមរយៈការលើកកំពស់ប្រាក់បៀវត្សដើម្បីអូសទាញអោយមានគ្រូពេទ្យដែលមានជំនាញខ្ពស់ចូលមកធ្វើការ ។
- ធានាអោយស្រ្តីនៅតាមតំបន់ដាច់ស្រយាលបានទទួលបាននូវសេវាំសុខភាព ដែលមានគុណភាពដោយផ្តល់នូវការលើកទឹកចិត្តដល់បុគ្គលិកសុខាភិបាលដែលធ្វើការនៅតំបន់ដាច់ជនបទទាំងនោះ ។
- លើកទឹកចិត្តដោយមានការជ្រើសរើសគ្រូពេទ្យស្រ្តីអោយចូលបំរើក្នុងផ្នែកសុខាភិបាលអោយបានច្រើន ។
- គួរអោយមានការប្រែប្រួលជាលំដាប់ដល់ឆ្មបជនបទនៅក្នុងផ្នែកការថែទាំសុខភាពមាតា ។ ត្រូវធ្វើយ៉ាងណាកុំអោយឆ្មបទាំងនោះអនុវត្តវិធីសាស្រ្តបូរាណ ដែលនាំអោយមានបញ្ហាដល់ស្រ្តី និងការរំលូតកូននៅតាមផ្ទះ ហើយត្រូវលើកទឹកចិត្តពួក គាត់អោយបំរើការជាភ្នាក់ងារទំនាក់ទំនងរវាងស្រ្តីទើបសំរាលកូន ស្រ្តីមានផ្ទៃពោះ និងពេទ្យឆ្មបជំនាញ នៅក្នុងសហគមន៏វិញ ។
- ខិតខំប្រឹងប្រែងបន្តទៀតក្នុងការប្រើប្រាស់ការឃោសនាផ្សព្វផ្សាយអំពីការការពារ ។
- កំណើតជាពិសេសផ្សព្វផ្សាយដល់បុរសនៅតាមជនបទនានា ។

---

[81] ការសិក្សាស្រាវជ្រាវអំពីប្រជាសាស្រ្ត និងសុខភាពកម្ពុជា ឆ្នាំ២០០០ : របាយការណ៏របស់វិទ្យាស្ថានស្ថិតិក្រសួង ផែនការ និងក្រសួងសុខាភិបាល ឆ្នាំ២០០០ ) ទំ. ១៦ ។

# IX- ស្ត្រីបំរើការងារ

## មាត្រា ១១

> *១. រដ្ឋភាគីត្រូវចាត់វិធានការសមស្របក្នុងការលុបបំបាត់នូវការរើសអើងប្រឆាំងនឹងនារីភេទនៅក្នុងវិស័យការងារ...*
>
> *២. ដើម្បីទប់ស្កាត់ការរើសអើងប្រឆាំងនឹងនារីភេទដែលឈរលើមូលដ្ឋានអាពាហ៍ពិពាហ៍ ឬមាតុភាព និងដើម្បីធានាដល់សិទ្ធិការងារយ៉ាងមានប្រសិទ្ធិភាពរបស់គេនោះ...*

ច្បាប់រដ្ឋធម្មនុញ្ញនៃមាត្រា ៣៦-១៧២-១៨៨ ដែលពាក់ព័ន្ធទៅនឹងច្បាប់ការងារកម្ពុជា បានចែងថាស្ត្រីមានសិទ្ធិស្មើគ្នានៅក្នុងវិស័យការងារទាំងអស់ ។ ប៉ុន្តែបញ្ហានេះ សូម្បីតែរដ្ឋាភិបាលក៏សារភាពថា ច្បាប់ទាំងនេះពុំមានការត្រួតពិនិត្យឱ្យបានត្រឹមត្រូវទេ[82] ។ ការទទួលស្គាល់នេះ ជាការប្រកាសអោយដឹងចាប់ពីថ្ងៃនេះតទៅ (២០០៤) ថាស្ត្រី គឺជាផ្នែកទាំងមូលនៃកំលាំងការងាររបស់ប្រទេសជាតិ ។ នៅឆ្នាំ២០០៣ មានស្ត្រី ៧៣.៥% បានចូលរួមក្នុងកំលាំងពលកម្មជាតិ ។ ការងារទាំងនោះរួមមានការងារក្រៅពីកសិកម្ម ៧៥% ការងាររាជការ ៣២.២% ការងារក្នុងវិស័យឯកជន ៤០% និង៨៧% នៃកម្មកររោងចក្រទាំងអស់ (ភាគច្រើន គឺការងាររោងចក្រឧស្សាហកម្មកាត់ដេរ)[83] ។ ស្ថិតិនេះមិនបានលើកឡើងនូវការពិតដែលស្ត្រីជាច្រើនបានបំរើការនៅក្នុងផ្នែកក្រៅផ្លូវការពិសេសក្នុងផ្នែកជំនួញខ្នាតតូចជាច្រើន ដូចជាអ្នកបំរើតាមភោជនីយដ្ឋាន និងជាអ្នកបំរើតាមគេហដ្ឋាននានា ដែលសូម្បីតែការអនុវត្តន៍សិទ្ធិការងារជាមូលដ្ឋានបំផុតក៏អនុវត្តមិនបានផង ។

## បៀវត្សស្មើគ្នា

នៅក្នុងទ្រឹស្តី ស្ត្រីគួរទទួលបានប្រាក់បៀវត្សសំរាប់ការងាររបស់ខ្លួន ។ ប៉ុន្តែបើប៉ាន់ស្មានមើលទៅជាមធ្យមស្ត្រីបានទទួលប្រាក់ឈ្នួលតិចជាងបុរស ៣០% ចំពោះការងារប្រហាក់ប្រហែលគ្នា ។ និយោជកច្រើនតែយល់ព្រមផ្តល់ការងារដល់ស្ត្រី (និងកុមារ) ដោយពួកគេជាទូទៅពុំសូវដឹងអំពីសិទ្ធិក្នុងការទទួលបានប្រាក់ខែស្មើគ្នារបស់ពួកគេ ហើយព្រមទទួលយកប្រាក់ខែទាប និងបរិយាកាសការងារដ៏លំបាក ។

---

[82] របាយការណ៍ដំបូង ទី២ និងទី៣ អំពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិស្តីពីការលប់បំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងនារីភេទនៅកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ខែតុលា ឆ្នាំ២០០៣) ទំ. ៦៨ ។

[83] យេនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ (ឯកសារផ្នែកអង្គការក្រៅរដ្ឋាភិបាល និងបញ្ហានានាស្តីពីការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០០៣ ទំ. ៣៥ ។

# សន្តិសុខការងារ និងការគាំពារមាតាទារកដែលកំពុងបំរើការងារ

និយោជកទាំងឡាយកម្រផ្តល់សន្តិសុខការងារក្នុងទំរង់ជាសោធន ឬផ្តល់ប្រាក់ឈ្នួលនៅពេលឈឺណាស់ ។ វាបានក្លាយទៅជាការអនុវត្តន៍ជាគោលការណ៍មួយចំពោះមន្ត្រីរាជការ និងបុគ្គលិកសង្គមស៊ីវិលទាំងអស់ក្នុងការទទួលបាននូវការធានាសុវត្ថិភាពការងារ ប៉ុន្តែគេបានទុកឆន្ទានុសិទ្ធិ និងមេត្តាករុណាអោយនិយោជកឯកជនធ្វើបញ្ញត្តិនេះទៅវិញ ។ ជាលទ្ធផលស្ត្រីកម្ពុជាជាច្រើនមិនដែលបានដឹងថាពួកគេត្រូវបានទទួលនូវប្រយោជន៍អ្វីមួយផង ។ ទាំងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ច្បាប់ការងារកម្ពុជា និងរដ្ឋធម្មនុញ្ញបានចែងនូវការហាមឃាត់ការបញ្ឈប់ការងារស្ត្រីមានផ្ទៃពោះ ។ មន្ត្រីរាជការត្រូវបានអនុញ្ញាតអោយឈប់សំរាកមាតុភាពរយៈពេលបីខែ ដោយនៅតែទទួលបានប្រាក់ពេញដដែល ។ នៅក្នុងទ្រឹស្តីកម្មកររោងចក្រ និងឧស្សាហកម្មផ្សេងៗទៀតក៏ត្រូវអនុញ្ញាតអោយឈប់សំរាប់លំហែរមាតុភាព ៩០ថ្ងៃ ដោយត្រូវបានទទួលប្រាក់ខែពាក់កណ្តាល ។ នៅក្នុងការអនុវត្តន៍ជាក់ស្តែងសិទ្ធិនេះពិបាកក្នុងការអនុវត្តន៍ណាស់ ហើយក៏នៅតែអាស្រ័យទៅនឹងចិត្តមេត្តាករុណារបស់និយោជកដដែល ។ និយោជកជាច្រើនដោយចង់បានប្រាក់ចំណេញច្រើន ហើយដោយការចំណាយដល់កម្មករច្រើនពេកអាចរកល្បិចក្នុងការដេញកម្មករស្ត្រីមានផ្ទៃពោះចោល ។ នៅក្នុងកាលៈទេសៈខ្លះគេបានបង្ខំអោយឈប់សំរាកនៅផ្ទះក្រោយពីមានផ្ទៃពោះពីព្រោះគ្មានទារកដ្ឋានសំរាប់កុមារ និងគ្មាននរណាមើលកូនអោយស្ត្រីទាំងនោះ[84] ។

# ស្ត្រីក្នុងឧស្សាហកម្មកាត់ដេរ

បច្ចុប្បន្នឧស្សាហកម្មកាត់ដេរ គឺជាវិស័យឈានមុខនៅក្នុងនៅកម្ពុជា ។ ក្នុងឆ្នាំ២០០១ វិស័យនេះបាននាំមកនូវប្រាក់ចំណូលនាំចេញ ៩០% នៃទំនិញនាំចេញរបស់ប្រទេសទាំងមូល នៅក្នុងឆ្នាំ ២០០៣ វិស័យបានផ្តល់ការងារដល់ស្ត្រី ២០% ក្នុងចំណោមស្ត្រីដែលមានអាយុពី ១៨-២៥ឆ្នាំ[85] ។ វាជារឿងធម្មតាទៅហើយដែលរោងចក្ររបស់បរទេសទាំងនោះ អាចប្រព្រឹត្តិនូវនិទ្ទណ្ឌភាពចំពោះបុគ្គលិកស្ត្រី ។ ប្រាក់បៀវត្សទាបបំផុតតាមច្បាប់សំរាប់កម្មករកាត់ដេរម្នាក់ គឺ ៤៥ដុល្លាក្នុងមួយខែ ចំពោះការងារ ៤៨ម៉ោងក្នុងមួយសប្តាហ៍ ។ អាស្រ័យដោយមានកម្មករស្ត្រីច្រើនលើសតំរូវការនៅលើទីផ្សារការងារ និយោជកតែងតែរំលោភលើបទដ្ឋានច្បាប់ដែលតំរូវ និងប្រាក់ឈ្នួលបន្ថែមម៉ោង ។ តាមការស្រាវជ្រាវបានរកឃើញថាប្រាក់ខែទាបធ្វើអោយកម្មករមួយចំនួនរកប្រាក់ចំណូលបន្ថែមដោយតាមរយៈធ្វើជាស្ត្រីបំរើភេទ ។

---

84 គួរកត់សំគាល់ថា ក្រុមហ៊ុនដែលមានបុគ្គលិកលើសពី ១០០ នាក់ឡើងទៅច្បាប់តំរូវអោយមានទារកដ្ឋានសំរាប់បុគ្គលិកកម្មករ ។

85 កម្ពុជា : គន្លឹះឧស្សាហកម្មកាត់ដេរ នៃពិភពលោក (Oxfam GB) ទំ. ៣ ។

បទដ្ឋានជាមូលដ្ឋានសំរាប់សុខភាព និងសុវត្ថិភាពក្នុងកន្លែងធ្វើការងារក៏កម្របានត្រួតពិនិត្យណាស់[86] ។ បុគ្គលិកសិទ្ធិមនុស្ស ក៏បានយកចិត្តទុកដាក់ចំពោះស្ថានភាពការងារ ដែលគ្រោះថ្នាក់ដល់កម្មករនៅក្នុងរោងចក្រមួយចំនួនមានស្ត្រីបានពុល ឬស្ថិតក្នុងស្ថានភាពរងគ្រោះដែលនាំអោយប៉ះពាល់ដល់សុខភាព[87] ។ អង្គការលីកាដូ និងវិទ្យាស្ថានការងារសេរីអាស៊ីអាមេរិក (AAFLI) បានបញ្ជាក់បន្ថែមពីការបង្ខិតបង្ខំនៅក្នុងរោងចក្រកាត់ដេរកម្ពុជា[88] ។ គេបានរាយការណ៍ថាស្ត្រីត្រូវបានគេបង្ខំអោយបង់ប្រាក់ផាកពិន័យទៅនិយោជក ប្រសិនបើ បដិសេធមិនព្រមធ្វើការថែមម៉ោង ឬនៅថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ ។ នៅក្នុងករណីពិសេសបន្ទាន់គេបានបិទទ្វាររោងចក្រមិនអោយកម្មករចេញទេ រហូតដល់កម្មករទាំងអស់បានបំពេញតាមផែនការបន្ថែមម៉ោងនោះរួចរាល់[89] ។ សុខភាព និងសុវត្ថិភាពពាក់ព័ន្ធទៅនឹងការអនុវត្តន៏នេះ គឺជាភស្តុតាងផ្ទាល់ខ្លួន ។

បច្ចុប្បន្ននេះ កម្មកររោងចក្រមានការស្ទាក់ស្ទើរក្នុងការទាមទារកែលំអស្ថានភាពប្រាក់ខែ និងបរិស្ថានក្នុងកន្លែងធ្វើការរបស់ពួកគេអាស្រ័យដោយស្ថានភាពក្នុងការទាមទារជាមួយនិយោជកមានភាពទន់ខ្សោយ ។ ប្រាក់ខែជាចំនួនមួយច្រើនបើប្រៀបធៀបទៅនឹងការងារក្នុងវិស័យផ្សេងទៀត ហើយបានអូសទាញស្ត្រីយ៉ាងច្រើនអោយចង់ធ្វើដោយគេអាចបានសល់ថវិកាខ្លះផ្ញើអោយគ្រួសាររបស់ពួកគេ ។ រាជរដ្ឋាភិបាលកម្ពុជាមិនហ៊ានជុំរុញអោយការទាមទារជាមួយក្រុមហ៊ុនជាទំរង់សហជីពកម្មករទេ ដោយខ្លាចពួកអ្នកវិនិយោគទាំងនោះឈប់វិនិយោគនៅក្នុងប្រទេស ។ ចំណុចនេះវាបានផ្ទុយទៅនឹងអនុសញ្ញាលេខ ៩៨ និង១៥៤ របស់អង្គការពលកម្មពិភពលោក (ILO) ដែលធានាអោយមានការទាមទារជាលក្ខណៈទ្រង់ទ្រាយធំ ។

នៅឆ្នាំ ២00៥ ប្រទេសកម្ពុជានឹងចូលជាសមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោក "WTO" ។ អនុលោមទៅតាមប្រព័ន្ធកូតាពន្ធដាថ្មីនឹងចុងបញ្ចប់នៃកិច្ចព្រមព្រៀង (Multifibre) ដែលធានាអោយផលិតករកម្ពុជាមានទីផ្សារខ្លះនៅសហរដ្ឋអាមេរិក តាមការអនុវត្តន៏ក្នុងកិច្ចព្រមព្រៀងនេះរោងចក្រមួយចំនួននឹងទៅវិនិយោគនៅកន្លែងផ្សេងវិញ ។ ចរន្តផ្លាស់ប្តូរនេះនឹងចោទជាបញ្ហាមួយយ៉ាងធំចំពោះកម្មករស្ត្រីទាំងជំនាញ និងពាក់កណ្តាលជំនាញដ៏ច្រើនអនេក ដែលអាចងាយរងគ្រោះដោយសារអំពើកេងប្រវ័ញ្ចក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ។

---

[86] ប្រភពឯកសារដដែល ។

[87] ឧទាហរណ៏-គណៈកម្មាការប្រព្រឹត្តិកម្មអង្គការសិទ្ធិមនុស្ស ។ វេជ្ជបណ្ឌិត ពុង ឈីវកេក បានរាយការណ៏នៅរោងចក្រកាត់ដេរមួយមិនបានប្រើម៉ាស់បាំងមុខទេ ។

[88] ពលកម្មកុមារនៅកម្ពុជា (វិទ្យាស្ថានការងារសេរីអាស៊ីអាមេរិក និងលីកាដូ ខែកញ្ញា ឆ្នាំ១៩៩៦) ស្ត្រីធ្វើការងារ នៅកម្ពុជា ( Astrid A afjes & Bama Athreya, LICADHO និង AAFLI) ។

[89] ស្ត្រីធ្វើការងារនៅកម្ពុជា ( Astrid A afjes & Bama Athreya, LICADHO និង AAFLI) ទំ. ១១ ។

## ស្ត្រីក្នុងវិស័យកសិកម្ម

នៅតំបន់ជនបទកម្ពុជា (ដែលមានប្រជាពលរដ្ឋ ៨៥% រស់នៅ) ស្ត្រីជាង ៦៥% ជាកសិករ ហើយស្ត្រីបានរួមចំណែក ៨០% នៅក្នុងសកម្មភាពផលិតម្ហូបអាហារ[90] ។ ភាគច្រើននៃពលករទាំងនេះបានចូលរួមក្នុងការងារកសិកម្ម ដើម្បីចិញ្ចឹមជីវិត និងជាការងារកសិកម្ម ដែលពុំមានប្រាក់ឈ្នួល ។ ស្ត្រីទាំងនេះច្រើនពុំសូវបានរៀនសូត្រជ្រៅជ្រះទេ មានឱកាសតិចតួចបំផុតក្នុងការរកការងារក្រៅពីកសិកម្ម ដូច្នេះត្រូវជាប់នៅក្នុងការវិវត្តន៍នៃភាពក្រីក្រឥតឈប់ឈរ ។

មានតំរូវការមួយយ៉ាងខ្លាំងអំពីសេវាផ្សព្វផ្សាយកសិកម្ម ដើម្បីអោយបានទៅដល់ស្ត្រីជនបទ ព្រមទាំងអាចលើកស្ទួយបច្ចេកទេសកសិកម្មដោយមានការកែលំអ និងមាននិរន្តភាពជានិច្ច ។ ព្រមជាមួយគ្នានេះដែរក៏ត្រូវអោយស្ត្រីរៀនសូត្រអំពីជំនាញទីផ្សារផងដែរ ហើយត្រូវលើកទឹកចិត្តអោយធ្វើការនៅក្នុងសហករណ៍កសិកម្មខ្នាតតូច ជាពិសេសការងារចិញ្ចឹមជីវិតដែលចំណាយដើមទុកតិច និងមានប្រសិទ្ធិភាព ។ ក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជនរួមជាមួយនឹងអង្គការមិនមែនរដ្ឋបាលមួយចំនួនបានជួយស្ត្រីអោយមានលទ្ធភាពក្នុងការខ្ចីទុន ដើម្បីរៀបចំសហគ្រាសខ្នាតតូច ប៉ុន្តែតំរូវអោយមានវិធីសាស្ត្រមីក្រូឥណទានរឹងមាំជាងនេះទៅទៀត ។ ពួកគេត្រូវរៀនសូត្រយកគំរូតាមគំរោងមីក្រូឥណទានណាដែលអនុវត្តបានជោគជ័យ ហើយក៏ត្រូវរៀនសូត្រពីប្រទេសជិតខាងដូចជាវៀតណាម និងហ្វីលីពីនជាដើម ។

## ពលករទេសន្តប្រវេសន៍ (ពលករចំណាកស្រុក)

ដោយយកលំនាំតាមប្រទេសផ្សេងៗទៀត ដូចជាហ្វីលីពីន និងវៀតណាមជាដើមកម្ពុជាក៏បាននាំពលករស្ត្រីចេញទៅក្រៅប្រទេសយ៉ាងច្រើនធ្វើជាអ្នកបំរើតាមគេហដ្ឋាននានានៅប្រទេសអាស៊ីមួយចំនួនដូចជា កូរ៉េខាងត្បូង និងម៉ាឡេស៊ីជាដើម ។ មានស្ត្រីមួយចំនួនរកបានការងារធ្វើតាមរយៈអំពើជួញដូរមនុស្ស និងអន្តោប្រវេសន៍ខុសច្បាប់ (សូមអានចំណុច IV ខ) ហើយស្ត្រីមួយចំនួនទៀតបានការងារធ្វើនៅតាមគេហដ្ឋានឯបរទេសដោយស្របច្បាប់ ។

បច្ចុប្បន្ន នៅកម្ពុជាមានក្រុមហ៊ុនឯកជនចំនួន ៥ ដែលផ្តល់ការហ្វឹកហ្វឺនអំពីការងារក្នុងគេហដ្ឋានដល់ស្ត្រីរួចបញ្ជូនទៅប្រទេសកូរ៉េខាងត្បូង និងម៉ាឡេស៊ី [91] ។ ការងាររបស់ក្រុមហ៊ុនទាំងនេះ ត្រូវមានការ

---

[90] យេនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ (ឯកសារផ្នែកអង្គការមិនមែនរដ្ឋាភិបាល និងបញ្ហាស្តីពីការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០០៣) ទំ. ៣៥ ។

[91] ស្ត្រីត្រូវចំណាយថវិកាសំរាប់ការហ្វឹកហ្វឺន (២-៣ ខែ) ដែលការចំណាយនោះត្រូវបានគេកាត់ពីប្រាក់ខែប្រចាំខែ របស់ស្ត្រីទាំងនោះ នៅពេលដែលពួកគេបានការងារធ្វើ ។

ពិនិត្យពិច័យ និងតាមដានអោយបានជិតដល់ ។ ថ្មីៗនេះមានកម្មករមួយចំនួនបានត្អូញត្អែរថាក្រុមហ៊ុនខ្លះ មិនបានគោរពកិច្ចសន្យាទេ ដោយកាត់ប្រាក់ខែ ពី ៤០០ដុល្លាមកនៅត្រឹម ១០០ដុល្លា ។ មានលទ្ធភាពតិចតួចណាស់ ដែលស្ត្រីទាំងនេះអាចធ្វើបាននៅពេលទៅដល់ប្រទេសដែលត្រូវទៅធ្វើការនោះជាធម្មតាគេបានដកហូតលិខិតឆ្លងដែនរបស់ពួកកម្មករទាំងនោះរក្សាទុក ។

ការស្រាវជ្រាវក្នុងការងារប្រភេទនេះស្ទើរតែមិនអាចធ្វើទៅកើត ដោយវាជា "ឧស្សាហកម្មលាក់កំបាំង" ដែលកម្មករស្ថិតក្នុងផ្ទះរបស់និយោជក ។ ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDA) បានកត់សំគាល់ថា មានស្ត្រីមួយចំនួនសប្បាយចិត្តនឹងបរិយាកាសការងារថ្មី ព្រមទាំងរីករាយក្នុងការដែលអាចផ្ញើថវិកាមកគ្រួសាររបស់ពួកគេនៅកម្ពុជា[92] ។ ប៉ុន្តែ ស្ត្រីជាច្រើនមិនសប្បាយចិត្ត ហើយមានអ្នកជួយតិចតួចក្នុងការប្តឹង ឬផ្តល់កិច្ចការពារខាងផ្លូវច្បាប់ ។ ថ្ងៃមួយមានស្ត្រីម្នាក់ ដែលកំពុងធ្វើការងារជាអ្នកបំរើនៅកូរ៉េខាងត្បូងបានទូរស័ព្ទមកអង្គការលីកាដូនៅភ្នំពេញ ដើម្បីស្វែងរកជំនួយអន្តរាគមន៍ ។ ករណីនេះ បានបង្ហាញអោយឃើញនូវភាពឯកកោរបស់ស្ត្រីជាអ្នកបំរើក្នុងគេហដ្ឋាននៅបរទេស ដែលពួកគេពុំមានមធ្យោបាយផ្នែកថវិកា ឬបណ្តាញគាំទ្រ ដើម្បីរត់គេចចេញពីការធ្វើបាបឡើយ ។

អង្គការខារ៉ាម និងលីកាដូកំពុងបញ្ចុះបញ្ចូលក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា អោយធ្វើការហ្វឹកហ្វឺនដល់ស្ត្រីអ្នកបំរើក្នុងគេហដ្ឋានអំពីសិទ្ធិការងាររបស់ពួកគេ (ទាំងសិទ្ធិនៅកម្ពុជា និងក្នុងប្រទេសដែលត្រូវទៅធ្វើការ) មុនពេលពួកគេចេញដំណើរ ។ លីកាដូក៏កំពុងផ្តល់អាវយឺតដល់កម្មករ ដែលនៅលើនោះមានការរៀបរាប់ពីសិទ្ធិរបស់ពួកគេ ព្រមទាំងលេខទូរស័ព្ទសំរាប់ទំនាក់ទំនងជាមួយប្រភពជំនួយនានានៅក្នុងប្រទេសដែលពួកគេត្រូវទៅធ្វើការ ។ ជាអកុសលព័ត៌មានទាំងនេះពុំត្រូវបានផ្តល់ ដើម្បីជាមធ្យោបាយសំរាប់រំដោះខ្លួន ពីព្រោះក្រុមហ៊ុនឯកជនដែលធ្វើពាណិជ្ជកម្មនេះមានការស្ទាក់ស្ទើរក្នុងការអោយកម្មកររបស់ខ្លួនដឹងអំពីសិទ្ធិរបស់ខ្លួននេះ ។

# អនុសាសន៍

- ត្រូវធ្វើការខិតខំប្រឹងប្រែង និងវិនិយោគថែមទៀត ដើម្បីបង្កើតគណៈកម្មាធិការត្រួតពិនិត្យ និងការពារនូវសិទ្ធិដែលធានាដោយអនុសញ្ញាស្តីពីការរើសអើងប្រឆាំងនឹងនារីភេទ និងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ដល់ស្ត្រីធ្វើការទាំងអស់ ។
- តំរូវអោយមានការយកចិត្តទុកដាក់ និងការយល់ដឹងអោយបានទូលំទូលាយនៅក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការងារ ។

[92] គំនិតផ្តួចផ្តើមសហគមន៍ ដើម្បីទប់ស្កាត់អំពើជួញដូរស្ត្រី-បទពិសោធន៍កម្ពុជា (ការផ្លាស់ប្តូរសុខភាពផ្លូវភេទ CWDA ឆ្នាំ ២០០៣) ។

- បើកវគ្គហ្វឹកហ្វឺនវិជ្ជាជីវៈដល់ស្ត្រីបន្ថែមទៀត ដើម្បីកុំអោយស្ត្រីទាំងនោះងាយរងគ្រោះ និងពឹងផ្អែកតែទៅលើការងារជាពលករគ្មានជំនាញដែលផ្តល់ដោយនិយោជកឯកជនដែលគិតតែពីការកេងយកចំណេញផ្ទាល់ខ្លួន ។
- គួរធ្វើយ៉ាងណាអោយស្ត្រីនៅជនបទមានលទ្ធភាពទទួលបានផលពីគំរោងការផ្សព្វផ្សាយកសិកម្ម និងមីក្រូឥណទាន ។
- ត្រូវបង្កើតបណ្តាញគាំទ្រសំរាប់ស្ត្រីកម្ពុជា ដែលបំរើការងារជាអ្នកបំរើតាមគេហដ្ឋាននៅបរទេស ។ បទពិសោធន៍អំពីកិច្ចការនេះអាចរៀនសូត្រពីប្រទេសហ្វីលីពីន ដែលមានបទពិសោធន៍យូរអង្វែង ។

# X- ស្ត្រីក្នុងវិស័យអប់រំ

## មាត្រា ១០

> *រដ្ឋភាគីត្រូវចាត់វិធានការសមស្របដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ ដើម្បីធានាអោយពួកគេមានសិទ្ធិស្មើគ្នាជាមួយនឹងបុរសនៅក្នុងវិស័យអប់រំ...*

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីសិទ្ធិស្មើគ្នាសំរាប់ស្ត្រីនៅគ្រប់បែបផែននៃការអប់រំ និងអាជីពទាំងឡាយ ក្នុងមាត្រា ៤៨-៦៣-៦៥-៦៦-៦៧ និង៦៨ ។ រាជរដ្ឋាភិបាលកម្ពុជា ក៏ជាហត្ថលេខីនៃសេចក្តីប្រកាសការអប់រំសំរាប់ទាំងអស់គ្នា ហើយថែមទាំងបានសន្យាថា ជាមួយនឹងគោលដៅសហសវត្សអង្គការសហប្រជាជាតិ ដើម្បីលើកកំពស់បទដ្ឋានអប់រំផងដែរ ។ ប៉ុន្តែ គំលាតរវាងទ្រឹស្តី និងការអនុវត្តន៏ក៏នៅតែឆ្ងាយពីគ្នានៅឡើយ ។ នៅឆ្នាំ ១៩៩០ អត្រាអក្ខរភាពមនុស្សចាស់បុរស គឺ ៧៨% និងស្ត្រី ៤៩%។ អត្រាទាំងនេះបានកើនដល់ ៨០% ចំពោះបុរស និងស្ត្រីដល់ ៥៧% នៅឆ្នាំ ២០០០ ប៉ុន្តែ ទោះជាមានការកើនឡើងយ៉ាងនេះក្តីក៏អត្រាអក្ខរភាពស្ត្រីកម្ពុជានៅតែទាបនៅឡើយ បើប្រៀបធៀបទៅនឹងអត្រានៃប្រទេសអាស៊ីផ្សេងៗទៀត[93] ។ នៅឆ្នាំ ២០០៣ Oxfam GB បានអះអាងថា ស្ត្រីកម្ពុជាតែ២២% ប៉ុណ្ណោះដែលចេះអានកាសែតនឹងចេះសរសេរលិខិតសាមញ្ញ[94] ។ ប្រភពនានាបានបង្ហាញអត្រាអក្ខរភាពសុទ្ធតែមានសុច្ចនៈករខុសៗគ្នាទាំងអស់ ប៉ុន្តែចំណុចស្របគ្នាទូទៅមួយ គឺស្ត្រីខ្វះការយល់ដឹងជាបញ្ហាមួយធ្ងន់ធ្ងរបំផុត ។

## ការអប់រំបឋមសិក្សា

រដ្ឋធម្មនុញ្ញបានចែងថាកុមារ ដែលមានអាយុចន្លោះពី ៦ ទៅ ១៦ឆ្នាំ នឹងត្រូវបានទទួលការអប់រំដោយបង្ខិតបង្ខំរយៈពេល ៩ឆ្នាំ ។ ប៉ុន្តែ កុមារីជាច្រើន ហើយជាពិសេសកុមាររស់នៅជនបទមួយចំនួនមិនដែលបានចូលរៀនសោះ ហើយខ្លះទៀតមិនបានចប់មធ្យមសិក្សាផង ។ មានកត្តាបីយ៉ាង ដែលអាចបំភ្លឺអោយយល់អំពីបញ្ហាចំនួនកុមារីបានរៀនបឋមសិក្សាទាបនេះ ។ កត្តាទី១ ជាបញ្ហាដែលបានចាក់ឬសទៅក្នុងប្រពៃណីមួយបែបរបស់ស្ត្រី ។ នៅជនបទគេគិតថាស្ត្រីជាមនុស្សសំរាប់តែធ្វើការងារផ្ទះតែប៉ុណ្ណោះ ហេតុនេះគេមិនយល់ ហើយថែមទាំងមិនទទួលស្គាល់នូវប្រសិទ្ធិភាពនៃការអប់រំកុមារីទៀតផង ។ នៅក្នុងខណៈខ្លះការអប់រំត្រូវបានគេយល់ឃើញថា ជាឧបសគ្គចំពោះស្ត្រី ដោយបុរសមួយចំនួនមិនចង់រៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីដែលមានការអប់រំ ។ ដូច្នេះនៅក្នុងគ្រួសារក្រីក្រ គេបានអោយអាទិភាពដល់កូនប្រុសទៅ

---

93 UNICEF: ស្ថិតិកម្ពុជាឆ្នាំ ២០០៣ www. unicef.org/cambodia_statistics.html ។ កម្ពុជា

94 កម្ពុជា : គន្លឹះកាត់ដេរសំរាប់ពិភពលោក Oxfam GB ឆ្នាំ ២០០៣ ។

សាលារៀនជាជាងអោយកូនស្រី ហើយទុកកូនស្រីសំរាប់ជួយការងារផ្ទះទៅវិញ ។ កត្តាទី២ គឺបញ្ហាសាលារៀន ។ លោកគ្រូ-អ្នកគ្រូដែលមានប្រាក់បៀវត្សតិចតួច និងខ្វះធនធានបានសុំអោយកុមារបង់ថ្លៃសាលាក្រៅផ្លូវការ ដើម្បីទំនុកបំរុងដល់សាលា និងបុគ្គលិក ។ ក្រៅពីការបង់ថ្លៃនេះ នៅមានការចំណាយផ្សេងៗទៀតដូចជា ប៊ិច សៀវភៅជាដើម ។ ដូច្នេះ តាមការជាក់ស្តែងការសិក្សាអប់រំជាបន្ទុកមួយដ៏ធ្ងន់ចំពោះគ្រួសារក្រីក្រ ដែលពេលខ្លះមិនអាចដោះស្រាយបាន ។ យោងតាមអង្គការ UNICEF បានលើកឡើងថា នៅពេលកុមារចុះឈ្មោះចូលរៀនដំបូងកុមារា និងកុមារីមានចំនួនស្មើៗគ្នា ហើយកត្តាដែលបានលើកឡើងរួចមកហើយ គឺជាកត្តាដែលបណ្តាលអោយកុមារីឈប់រៀនច្រើនបំផុតនៅបឋមសិក្សា[95] ។ សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា (CITA) បានធ្វើការប៉ាន់ប្រមាណថានៅឆ្នាំ២០០៣ មានសិស្សានុសិស្សត្រឹមតែ ៦០%ប៉ុណ្ណោះដែលបានរៀនចប់បឋមសិក្សា ហើយភាគច្រើនជាកុមារា[96] ។

# ការអប់រំនៅមធ្យមសិក្សា និងកំរិតឧត្តមសិក្សា

នៅឆ្នាំ២០០២ ភាគរយជាមធ្យមនៃកុមារីដែលបានរៀននៅសាលាមធ្យមសិក្សា និងកំរិតសិក្សាជាន់ខ្ពស់បានកើនដល់ ៣៦% និង៣១% ដោយនៅតាមជនបទមានអត្រាសិស្សចូលរៀនខ្ពស់ជាងមុន[97] ។ ការសិក្សានៅកំរិតនេះក៏មានឧបសគ្គប្រហែលនឹងកត្តាជាឧបសគ្គដល់ស្ត្រីនៅក្នុងការអប់រំជាទូទៅដែរ ។ ប៉ុន្តែគេបានចាប់ផ្តើមជំហានជាវិជ្ជមានរួចហើយ ដើម្បីដោះស្រាយបញ្ហាអតុល្យភាពនេះ ហើយថែមទាំងបានធ្វើការបញ្ជ្រាបយែនឌ័រនៅក្នុងវិស័យអប់រំនេះទៀតផង ។ នៅឆ្នាំ២០០២ ក្រសួងអប់រំយុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយផ្តល់អាទិភាពមួយ ដើម្បីអោយស្ត្រីបានរៀនដល់កំរិតសិក្សាជាន់ខ្ពស់ដែលលទ្ធផលប្រលងរបស់បេក្ខនារីថ្នាក់ទី ១២ ត្រូវបានផ្តល់អាទិភាពច្រើនជាងសិស្សប្រុស[98] ។ រដ្ឋាភិបាលក៏បានបង្ហាញថា ខ្លួនមានចេតនាក្នុងការបង្កើតអោយមានគោលនយោបាយផ្តល់អាទិភាពនេះនៅក្នុងមន្ត្រីរាជការផងដែរ ជាពិសេសនៅក្នុងក្រសួងអប់រំយុវជន និងកីឡា ដើម្បីបង្កើនចំនួនអ្នកគ្រូ ។ សមាគមគ្រូបង្រៀនឯករាជ្យ CITA បានស្នើសុំអោយរដ្ឋាភិបាលដំឡើងប្រាក់បៀវត្សដល់លោកគ្រូ-អ្នកគ្រូជាច្រើនលើកច្រើនសារព្រមទាំងសុំអោយបង្កើនមូលនិធិ ដើម្បីធានាអោយការសិក្សាត្រូវបានធ្វើឡើងតាមមូលដ្ឋានឥតគិតថ្លៃ ហើយធ្វើដូច្នេះ ទើបអាចកែលំអស្តង់ដា និងវិជ្ជាជីវៈជំនាញទូទៅបាន ។ ប៉ុន្តែសមាគមគ្រូបង្រៀនឯករាជ្យ និង

---

[95] របាយការណ៍ប្រចាំឆ្នាំ២០០៣ (សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា ភ្នំពេញ ខែឧសភា ឆ្នាំ២០០៤) ទំ. ១ ។

[96] របាយការណ៍ព្រាងស្តីពីការអប់រំ : (សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា ភ្នំពេញ ខែឧសភា ឆ្នាំ២០០៤) ។

[97] ការសម្របសម្រួលការអនុវត្តន៍អនុសញ្ញា CEDAW សំដៅសំរេចសិទ្ធិមនុស្សរបស់ស្ត្រីអោយបាននៅតំបន់ អាស៊ីអាគ្នេយ៍ (UNFPA & CIDA 2004) ទំ. ៣២ ។

[98] ក្រោមអនុសញ្ញា CEDAW រដ្ឋភាគីទាំងឡាយត្រូវបានអនុញ្ញាតអោយមានគោលនយោបាយផ្តល់អាទិភាព ។

សហជីពអប់រំបានជួបប្រទះនូវការបំភិតបំភ័យកាន់តែច្រើនឡើង១ នៅពេលដែលពួកគេចង់អោយមានការកែលំអតម្លាភាពប្រាក់បៀវត្ស និងស្ថានភាពប្រសើរជាងមុន[99] ។

## ការហ្វឹកហ្វឺនជំនាញ និងវិជ្ជាជីវៈ

ក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជន និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទទួលស្គាល់សារសំខាន់នៃវគ្គហ្វឹកហ្វឺនវិជ្ជាជីវៈដល់ស្ត្រីកាន់តែខ្លាំងឡើង១[100] ។ វគ្គហ្វឹកហ្វឺននេះ អាចជួយអោយស្ត្រីមានជំនាញច្រើនហើយមានសារៈប្រយោជន៍បំផុតក្នុងការជួយដល់ស្ត្រីក្រីក្រ និងស្ត្រីនៅតំបន់ដាច់ស្រយាលដែលងាយរងគ្រោះដោយសារការកេងប្រវ័ញ្ច ។ សារៈប្រយោជន៍ នៃវគ្គហ្វឹកហ្វឺនវិជ្ជាជីវៈ គឺដោយវាមានរយៈពេលខ្លីជាងការរៀនសូត្រតាមបែបបុរាណ ហើយអាចផ្តល់នូវការអនុវត្តន៍ជាក់ស្តែងដល់ស្ត្រីក្នុងការជួយខ្លួនឯង ។

## អនុសាសន៍

- គួរផ្តល់ថវិកាបន្ថែមដោយមានតម្លាភាពដល់កម្មវិធី P.A.P របស់រដ្ឋាភិបាល[101] ជាទូទៅតំរូវអោយ
  មានការបង្កើនមូលនិធិក្នុងវិស័យអប់រំលុបបំបាត់ការទារថ្លៃក្រៅផ្លូវការពីសិស្សានុសិស្ស ។ ការតំឡើងប្រាក់បៀវត្សដល់លោកគ្រូអ្នកគ្រូក៏ជាជំហានមួយក្នុងការកែលំអគុណភាព និងធ្វើអោយសិស្សានុសិស្សអាចទទួលបានការសិក្សាយ៉ាងច្រើនផងដែរ ។
- ត្រូវមានវិធានការសមស្របនានា ដើម្បីលើកទឹកចិត្តនារីអោយបន្តការសិក្សានៅថ្នាក់មធ្យមសិក្សា និងខ្ពស់ជាងនេះទៅទៀតដូចជាគំរោងផ្តល់អាទិភាព ការផ្តល់រង្វាន់ ការផ្តល់អាហារូបករណ៍ជាតិ និងអន្តរជាតិ និងការផ្តល់អន្តេវាសិកដ្ឋានដល់សិស្សនារីមកពីជនបទ ដើម្បីសិក្សានៅវិទ្យាល័យ និងមហាវិទ្យាល័យ ។
- វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវផ្តោតទៅលើគោលដៅ ជាពិសេសនារីត្រូវតែបង្កើនថែមទៀតនៅទូទាំងប្រទេស ។

---

[99] របាយការណ៍ប្រចាំឆ្នាំសមាគមគ្រូបង្រៀនឯករាជភ្នំពេញ ឆ្នាំ ២០០៣ ។

[100] លើកកំពស់ការហ្វឹកហ្វឺនវិជ្ជាជីវៈ និងជំនាញដល់ស្ត្រីគឺជាគោលដៅអភិវឌ្ឍន៍រួមរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជននៅក្នុងផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ដែលត្រូវបានហៅថា នារីរតនៈ ។

[101] P.A.P. គឺជាកម្មវិធីដែលបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០០២ ។ មានគោលបំណង ដើម្បីចៀសវាងកុំអោយមានការចំណាយថ្លៃសាលាដោយការផ្តល់ការឧបត្ថម្ភដល់មហាវិទ្យាល័យ ។ ប៉ុន្តែវានៅមិនទាន់មានឥទ្ធិពលទៅលើការអនុវត្តន៍ជាក់ស្តែងចំពោះការអនុវត្តន៍ខុសច្បាប់ក្នុងវិស័យអប់រំនៅឡើយទេ ។

# XI- ស្ត្រីក្នុងកិច្ចការនយោបាយ ជីវភាពសាធារណៈ និងកិច្ចការបរទេស

## មាត្រា ៧

> *រដ្ឋភាគីនានាត្រូវចាត់វិធានការសមស្របទាំងអស់ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទនៅក្នុងជីវភាពនយោបាយ និងសាធារណៈនៃប្រទេសជាតិ...*

## មាត្រា ៨

> *រដ្ឋភាគីនានាត្រូវប្រកាន់យកនូវវិធានការសមស្រប ដើម្បីធានាអោយនារីអាចចូលរួមដោយឈរលើមូលដ្ឋានស្មើភាពនឹងបុរស និងដោយគ្មានការរើសអើងអ្វីទាំងអស់ជាតំណាងរដ្ឋាភិបាលរបស់ខ្លួននៅលើឆាកអន្តរជាតិ ហើយនឹងចូលរួមនៅក្នុងអង្គការអន្តរជាតិទាំងមូល ។*

ស្ត្រីតំណាងក្នុងនយោបាយ ជីវភាពសាធារណៈ និងកិច្ចការអន្តរជាតិជាមុខមាត់សាធារណៈមួយរបស់តំណាងយែនឌ័រនៅក្នុងប្រទេសមួយ ។ ហើយវាក៏អាចផ្តល់នូវការបង្ហាញនូវតួនាទីមួយដែលស្ត្រីកាន់តំណែងក្នុងការបង្កើតច្បាប់ និងគោលនយោបាយនានាដែលប៉ះពាល់ដល់ជីវិតរបស់ពលរដ្ឋ ហើយជាពិសេសដល់ស្ត្រី ។ ស្ត្រីជាសមាជិកសភាដំបូងបង្អស់ពីឆ្នាំ ១៩៥៨ ដល់ ១៩៧០ គឺអ្នកស្រី *ពុង ប៉េងចេង (ស៊ីវ អេងតុង)* ធ្លាប់បំរើជារដ្ឋមន្ត្រីសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានរដ្ឋសភាស្តីទី[102] ។ ក្នុងកំឡុងពេលនេះនាងបានលើកទឹកចិត្តស្ត្រីផ្សេងៗជាច្រើនដូចជា អ្នកស្រី *ឌៀប ឌីណា* ដើម្បីអោយឈរឈ្មោះ ។ អ្នកស្រី *ស៊ីវ អេងតុង* បានទាមទារសិទ្ធិរបស់ស្ត្រីឥតឈប់ឈរនៅក្នុងវិស័យសម្ភពស្ត្រីការបញ្ជ្រាបយេនឌ័រទៅក្នុងការងារ និងអប់រំ ព្រមទាំងការពារកុមារ និងនារីបំរើផ្លូវភេទ ។ នៅក្នុងសម័យនោះឃើញថាការបញ្ជ្រាបយេនឌ័រមានការកែលំអបានមួយកំរិតនៅក្នុងវិស័យនយោបាយនិងកិច្ចការសាធារណៈ ប៉ុន្តែស្ត្រីនៅតែពោរពេញទៅដោយភាពសោកសៅដោយគ្មានអ្នកណាម្នាក់ដឹង ។

---

[102] កូនស្រីរបស់អ្នកស្រី ពុង ប៉េងចេង គឺលោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក បានបន្តប្រពៃណីគ្រួសារហើយក៏ជាគំរូជាវិជ្ជមានម្នាក់សំរាប់ស្ត្រីកម្ពុជា។ នាង គឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីមួយចំនួនតូច ដែលចូលរួមដឹកនាំក្នុងការចរចារក្រៅផ្លូវការដែលឈានទៅរកកិច្ចព្រមព្រៀងសន្តិភាពនៅកម្ពុជា ។ នៅឆ្នាំ ១៩៩២ នាងបានបង្កើតអង្គការលីកាដូជាមួយនឹងកូនស្រី ណាលី និងអេវ៉ា ធ្វើការមិនចេះនឿយហត់ដើម្បីការពារនិងលើកស្ទួយសិទ្ធិស្ត្រីនៅកម្ពុជា។ វេជ្ជបណ្ឌិត ពុង ឈីវកេក នៅតែជាប្រធានអង្គការលីកាដូបច្ចុប្បន្ននេះ នាងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកែលំអសេវាសុខភាពនៅកម្ពុជា ។

## ការបោះឆ្នោត និងតំណាងនៅក្នុងរដ្ឋាភិបាល

តាមលក្ខណៈខាងក្រៅកម្ពុជាជាប្រទេសប្រជាធិបតេយ្យសេរីដែលអនុសញ្ញា CEDAW និងមាត្រា ៣៤ នៃរដ្ឋធម្មនុញ្ញជាតិធានាអោយមានការបោះឆ្នោតជាសកល និងការកាន់មុខតំណែងសាធារណៈ ។ នៅក្នុងការអនុវត្តន៍ជាក់ស្តែង ស្ត្រីមានតំណាងតិចតួចបំផុតនៅក្នុងរដ្ឋាភិបាលគ្រប់កំរិតទាំងអស់ ។ នៅក្នុងសម័យបោះឆ្នោតដែលរៀបចំឡើងដោយ អ៊ុនតាក់ កាលពីឆ្នាំ១៩៩៣ មានបេក្ខជនជាស្ត្រីតែ ៥% ប៉ុណ្ណោះ ។ ស្ថានភាពនេះមានការប្រសើរឡើងនៅក្នុងទសវត្សកន្លងទៅនេះ ហើយនៅក្នុងការបោះឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រកាលពីឆ្នាំ១៩៩៨ មានស្ត្រីដែលបានជាប់ជាតំណាងរាស្ត្ររហូតដល់ ១១,៥% ។ ក្រោយការបោះឆ្នោត ១៩៩៨ ក៏នៅមានភាពប្រសើរឡើងបន្តិចទៀតដែរក្នុងតំណាងស្ត្រីនៅថ្នាក់ក្រសួងដោយមានស្ត្រី ២រូប (ក្នុងចំណោម ២៤រូប) ជារដ្ឋមន្ត្រីតំណាងអោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជន ។ រដ្ឋាភិបាលជនបទនៅកម្ពុជាក៏បានឆ្លុះបញ្ចាំងនូវអតុល្យភាពយេនឌ័រផងដែរ ដោយពុំមានស្ត្រីណាម្នាក់ដែល ត្រូវបានគេតែងតាំងជាអភិបាលខេត្ត ឬអភិបាលក្រុងឡើយ ហើយមានតែស្ត្រី ៥នាក់តែប៉ុណ្ណោះ ដែលបានកាន់តំណែងជាពាក់កណ្តាលតំណែងជាន់ខ្ពស់នៃអភិបាលខេត្ត-ក្រុងរង និងអភិបាលស្រុករង ។

នៅឆ្នាំ ២០០០ ប្រទេសកម្ពុជាបានបង្កើតឡើងនូវប្រព័ន្ធទ្វេរសភា ដោយព្រឹទ្ធសភាដើរតួនាទីជា*សភាជាន់ខ្ពស់* ។ រាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងសមាជិកព្រឹទ្ធសភាទាំង ៦១រូប ប៉ុន្តែមានតំណាងស្ត្រីតែ ១៣% ប៉ុណ្ណោះ ។ ដូច្នេះរាជរដ្ឋាភិបាលពុំបានជ្រើសរើសយកការផ្តល់ឱកាសក្នុងការរកដំណោះស្រាយសមភាពសំរាប់ស្ត្រីនៅក្នុងជីវភាពនយោបាយទេ[103] ។

## សេរីភាពនៃការជួបប្រជុំប្រមូលផ្តុំ

អង្គការសិទ្ធិមនុស្សបានកត់សំគាល់ឃើញថា សិទ្ធិសេរីភាពនៃការជួបប្រជុំត្រូវបានហាមឃាត់ចាប់តាំងពីគណបក្សប្រជាជនកម្ពុជាបានឈ្នះឆ្នោតកាលពីឆ្នាំ២០០៣[104] ។ ការបដិបត្តិសេរីភាពក្នុងការជួបប្រជុំមិនត្រូវបានធានាសិទ្ធិនៅឡើយទេនៅក្នុងប្រទេសកម្ពុជា ។ បញ្ហានេះជាពិសេសបានប៉ះទង្គិចដល់ស្ត្រីក្នុង

---

[103] តាមអនុសញ្ញា CEDAW រដ្ឋភាគីនានាត្រូវបានអនុញ្ញាតអោយបង្កើតគោលនយោបាយផ្តល់អាទិភាពដល់ស្ត្រី ប្រសិនបើគោលនយោបាយនោះបង្កើតឡើងក្នុងគោលបំណងជាក់ស្តែង ដើម្បីសមភាពរវាងស្ត្រី និងបុរស ហើយគ្រាន់តែ "ជាវិធានការពិសេសបណ្តោះអាសន្ន" តែប៉ុណ្ណោះ (មាត្រា ៤) ។

[104] គណៈកម្មការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមសិទ្ធិមនុស្សកម្ពុជា ។

វិស័យឧស្សាហកម្មកាត់ដេរ ដោយការធ្វើបាតុកម្មដោយសន្តិវិធី ដើម្បីទាមទារប្រាក់បៀវត្សសមរម្យក៏ត្រូវបានបង្ក្រាបដោយហិង្សាឃោឃៅបំផុតដែរ លើសពីនេះទៅទៀត ពួកគេបានហាមឃាត់រឹតបន្តឹង ។ ក្នុងខែមិនា ឆ្នាំ១៩៩៧ បាតុកម្មដោយសន្តិវិធីមួយរបស់កម្មករកាត់ដេរនៅខាងមុខមន្ទីររដ្ឋសភាពជាតិត្រូវរងដោយការវាយប្រហារដោយគ្រាប់បែក ដែលបណ្តាលអោយស្លាប់ និងរបួសជាច្រើន ។ ស្ត្រីម្នាក់ដែលជាអ្នករកស៊ីចិញ្ចឹមគ្រួសារតែម្នាក់គត់ក្នុងគ្រួសារដែលមានសមាជិក ៨នាក់ បានត្រូវរងរបួសបណ្តាលអោយខ្វិនដើរមិនរួច ហើយត្រូវទទួលការព្យាបាលជាប្រចាំ ។ នៅឆ្នាំ២០០៣ ក្រុមសិទ្ធិមនុស្សបានសង្កេតទៅលើបាតុកម្មជាច្រើនដែលធ្វើឡើងដោយកម្មករស្ត្រីនៅរោងចក្រកាត់ដេរ ដែលត្រូវបានគាបសង្កត់ក៏បណ្តាលអោយមានរងរបួស និងស្លាប់ជាច្រើននាក់ផងដែរ ។ ដូចគ្នានេះដែរ ការជួបជុំគ្នាដើរដង្ហែក្បួនដោយគណៈកម្មាធិការស្ត្រីកម្ពុជា ឃែមបូវ ដើម្បីលើកកំពស់ការយល់ដឹងអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ ក៏ត្រូវបានបដិសេធមិនអនុញ្ញាតច្បាប់ផងដែរ ។ បញ្ហានេះ ជាការប្រាប់អោយដឹងនូវនិន្នាការមួយក្នុងការគាបសង្កត់សិទ្ធិសេរីភាពរបស់ស្ត្រីក្នុងការបញ្ចេញមតិ និងការជួបប្រជុំនៃការទាមទារសិទ្ធិក្នុងទីកន្លែងធ្វើការ ។

## ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០០២

នៅក្នុងការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ២០០២ គណបក្សធំៗទាំងបី (គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ី) មិនបានឯកភាពអោយមានស្ត្រី ៣០% ក្នុងប្រព័ន្ធកូតាត្រូវបានចែងក្នុងច្បាប់ទេ ។ ចំណុចនេះ បានបង្ហាញអោយឃើញថាគណបក្សធំៗនៅតែស្ទាក់ស្ទើរក្នុងការលើកស្ទួយបេក្ខជនឈរឈ្មោះជាស្ត្រីនៅក្នុងជួរមានតែបក្សរបស់ខ្លួន។ រយៈពេល ២ឆ្នាំមុនបោះឆ្នោត អង្គសន្តិភាពបៀវត្សរ៍ស្ត្រី (Women Waging Peace) បានអោយដឹងថា ខ្លួនបានជួយគាំទ្របេក្ខជនស្ត្រីចំនួន ៥.៥២៧ រូប ដោយផ្តល់ការណែនាំដល់ស្ត្រីទាំងនោះពីរបៀបវិធីនិយាយជាសាធារណៈ ការសរសេរសន្ទរកថា ការឆ្លើយសំណួររបស់ម្ចាស់ឆ្នោត និងការទប់ទល់ការប្រកួតប្រជែងដោយសមាជិកបក្សជាបុរស ដែលមិនយោគយល់ដល់ការចូលរួមរបស់ស្ត្រី[105] ។ ក្នុងចំណោមបេក្ខជនចំនួន ៧៥.២៨៧ រូប មានស្ត្រី ១៦% ហើយក្នុងនោះមានតែ ៨.៦៧%ប៉ុណ្ណោះ ដែលបានជាប់ឆ្នោតបំរើក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ដូចបានពិភាក្សានៅក្នុងចំណុច IV រួចមកហើយ គេត្រូវធ្វើការស្រាវជ្រាវបន្តទៀត ដើម្បីរុករកអោយដឹងថា តើស្ត្រីកំពុងប្រឈមមុខ នឹងការរើសអើងទំហំប៉ុនណាពីសំណាក់សហការីបុរសរបស់ខ្លួននៅក្នុងជួរការងារនៃរដ្ឋាភិបាល ។

## ការបោះឆ្នោតជាតិឆ្នាំ ២០០៣

---

105 អភិបាលកិច្ចល្អពីក្រោមឡើងទៅលើៈ តួនាទីរបស់ស្ត្រីក្រោយជំលោះនៅកម្ពុជា (Women Waging Peace គណៈកម្មការគោលនយោបាយ ខែកុម្ភៈ ឆ្នាំ២០០៤ ) ទំ. ៣ ។

ការបោះឆ្នោតជាតិនៅឆ្នាំ២០០៣ ស្ត្រីបានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងកំរិតភាគរយខ្ពស់ ។ ការបោះឆ្នោតនេះត្រូវបានទទួលស្គាល់ដោយអ្នកសង្កេតការណ៍មិនលំអៀង ថាមានលក្ខណៈប្រសើរជាងឆ្នាំ១៩៩៨ ប៉ុន្តែក៏នៅតែប្រព្រឹត្តទៅនៅក្នុងបរិកាសមួយដែលពោរពេញដោយ អំពើហិង្សាការបំភិតបំភ័យទាំងមុន និងទាំងក្រោយពេលបោះឆ្នោត ។ អ្នកសង្កេតការណ៍សិទ្ធិមនុស្សបានកត់សំគាល់ឃើញថា មានការកើនឡើងនូវការសំលាប់ទាំងប្តីប្រពន្ធនៅក្នុងពេលបោះឆ្នោតនោះ ។ អ្នកសង្កេតការណ៍ក្នុងស្រុកបានបង្ហាញនូវការជាប់ពាក់ព័ន្ធរវាងការនិយមគណបក្សនយោបាយ និងការសំលាប់ទាំងប្តីប្រពន្ធនេះ ប៉ុន្តែគេបានដឹងការពិតតិចតួចណាស់ជុំវិញករណីទាំងនោះ[106] ។ ករណីនេះក៏អាចជាករណីអំពើហិង្សាក្នុងគ្រួសារ ដែលកើតចេញពីអំពើហិង្សានយោបាយផងដែរ ។

លទ្ធផលការបោះឆ្នោត ត្រូវបានគណបក្សហ៊្វុនស៊ិនប៉ិច និងសម រង្ស៊ី បដិសេធ ។ ជាមួយនឹងប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាពខ្សោយនៅក្នុងរវាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិរបស់រដ្ឋាភិបាលការជាប់គាំងផ្នែកនយោបាយបានបន្តរហូតដល់ខែកក្កដាឆ្នាំ២០០៤នេះ ។ ការពន្យាពេលក្នុងការបង្កើតរដ្ឋាភិបាលអស់រយៈពេល ១១ ខែនេះ បានបណ្តាលអោយមានរឿងរ៉ាវជាបន្តបន្ទាប់ចំពោះស្ត្រីកម្ពុជា ។ រដ្ឋសភាក៏មិនទាន់បានអនុម័តច្បាប់មួយចំនួនធំ ដែលអាចជួយការពារស្ត្រីអោយបានប្រសើរជាងមុន ។ លើសពីនេះទៅទៀតត្រូវធ្វើការកែទំរង់តុលាការក្នុងទ្រង់ទ្រាយធំ ដើម្បីកាត់បន្ថយនិទ្ទណ្ឌភាព និងអំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តាធិការដែលមិនទាន់បានគិតគូរនៅឡើយ ។

# ស្ត្រីក្នុងប្រព័ន្ធតុលាការ

ដូចបានរៀបរាប់ក្នុងផ្នែកនីតិបញ្ញត្តិ និងនីតិប្រតិបត្តិនៃរដ្ឋាភិបាលដែរ ផ្នែកតុលាការសមាជិកស្ត្រីក៏មានតំណាងតិចតួចដែរ ។ នៅឆ្នាំ២០០៣ មានស្ត្រី ១៤នាក់ជាចៅក្រម (១២%) នៃចៅក្រមសរុបទាំងអស់មាន ១១៩រូប ស្ត្រី ១រូបជាព្រះរាជអាជ្ញា (១,៥%) ក្នុងចំណោមព្រះរាជអាជ្ញាទាំង ៦៣រូប ហើយមាន ១២៩រូបជាក្រឡាបញ្ជី (១៩,២៥%) ក្នុងចំណោមក្រឡាបញ្ជីសរុបទាំងអស់ ៦៦៨[107] ។ តំណាងសមាជិកស្ត្រីក្នុងចំណោមមេធាវីក៏នៅមានចំនួនទាបដែរក្នុងទូទាំងប្រទេសកម្ពុជា ។

អាស្រ័យដោយមានការជាប់គាំងផ្នែកនយោបាយ ដែលកើតឡើងដោយសារការបោះឆ្នោត នៅឆ្នាំ ២០០៣ នោះ គេសង្កេតឃើញថាមានដំណើរការជឿនលឿនតិចតួចណាស់ក្នុងការកែទំរង់វិស័យតុលាការ ។

---

[106] អ្នកសង្កេតការណ៍រួមមាន និចហ្វិច និងលីកាដូ ។

[107] របាយការណ៍ ទី២ និងទី ៣ ស្តីពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើង ប្រឆាំងនឹងស្ត្រីភេទនៅកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ខែតុលា ឆ្នាំ២០០៣) ទំ. ៤១-៤២ ។

បច្ចុប្បន្ននេះមានស្ត្រីម្នាក់បានក្លាយជាអ្នកដឹកនាំសាលាភូមិន្ទចៅក្រម ដែលជាសញ្ញាដ៏ល្អមួយសំរាប់ស្ត្រីក្នុងវិស័យតុលាការ ។ ចំណុចវិជ្ជមានមួយចំនួនទៀត គឺការខិតខំប្រឹងប្រែងក្នុងការគាំទ្រមូលនិធិ ដើម្បីលើកទឹកចិត្តស្ត្រីអោយចូលរួមក្នុងការរៀនសូត្រច្បាប់តាមរយៈការគាំទ្រផ្នែកអាហាររូបករណ៍និងការសិក្សា[108] ។

## ស្ត្រីក្នុងវិស័យកិច្ចការអន្តរជាតិ

កន្លងមកនេះ ពុំមានស្ត្រីជាឯកអគ្គរាជទូតតំណាងកម្ពុជានៅបរទេសទេ ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់កំហុសទៅលើវប្បធម៌ និងតំលៃសង្គមហួសហេតុ ដែលធ្វើអោយស្ត្រីពិបាកក្នុងការចាកចេញពីស្រុក ដើម្បីទទួលមុខតំណែងនៅក្រៅប្រទេសនោះ ។

ស្ត្រីហាក់ដូចជាមានតំណាងច្រើនគួរសមនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ។ មុខងារទាំងនេះ ជាចំណុចចាប់ផ្តើមមួយសំរាប់ស្ត្រីបន្តការងារនៅក្នុងឆាកអន្តរជាតិ ដូចជា ចូលរួមក្នុងសន្និសីទ និងជាប្រតិភូជាដើម ។

## អនុសាសន៍

- គួរតែមានប្រព័ន្ធកូតា ឬគោលនយោបាយផ្តល់អាទិភាពសំរាប់បេក្ខនារី នៅក្នុងគណបក្សនយោបាយនានា និងការឈរឈ្មោះបោះឆ្នោតសំរាប់ស្ត្រី ។
- បន្តការគាំទ្រ លើកទឹកចិត្ត និងគួរផ្តល់ការហ្វឹកហ្វឺនដល់ស្ត្រី ដើម្បីអោយពួកគេមានទំនុកចិត្តក្នុងការកាន់តំណែងសាធារណៈ ។
- គួរលើកទឹកចិត្តស្ត្រី និងផ្តល់សិទ្ធិអនុវត្តនានា ដើម្បីអោយស្ត្រីបង្កើតសហជីពនៅក្នុងរោងចក្រ និងសហគ្រាសនានា ។ ការធ្វើបែបនេះនឹងអាចជួយធានាអោយមានកិច្ចការពារសិទ្ធិស្ត្រីនៅកន្លែងធ្វើការតាមរយៈយុទ្ធសាស្ត្រតវ៉ាជាមួយនឹងក្រុមហ៊ុនដោយសន្តិវិធី ។
- ការអនុម័តសេចក្តីព្រាងច្បាប់នានាដែលសំខាន់បំផុតក្នុងកិច្ចការពារស្ត្រី ហើយត្រូវបន្តធ្វើការកែទំរង់ប្រព័ន្ធតុលាការអោយបានឆាប់ជាទីបំផុត ។
- គួរលើកទឹកចិត្តនឹងជំរុញស្ត្រីយ៉ាងសកម្មក្នុងបេសកកម្មការទូត និងការចូលរួមក្នុងប្រតិភូអន្តរជាតិ ។

[108] រដ្ឋាភិបាលអាល្លឺម៉ង់ (តាមរយៈ GTZ ) បានផ្តល់មូលនិធិ និងគាំទ្រនូវគំនិតផ្តួចផ្តើមនេះយ៉ាងសកម្ម ។

# XII. សេចក្ដីសន្និដ្ឋាន

## ការផ្ដល់អំណាចដល់ស្ត្រីកម្ពុជាពេលអនាគត

របាយការណ៍នេះបានបង្ហាញថាមានឧបសគ្គយ៉ាងច្រើននៅតាមនិន្នាការ ដើម្បីឈានដល់ការផ្ដល់អំណាចចំពោះស្ត្រីនៅកម្ពុជា ។ ជាច្រើនលើកច្រើនសារ ការសិក្សាបានខិតខំគូសបញ្ជាក់នូវបញ្ហាដែលគួរអោយស្អប់ ដូចជារឿងរបស់នារី *"ទូច"* ជាដើម ។ នៅពេលខ្លះទៀតការសិក្សាបានលាតត្រដាងអោយឃើញនូវការព្រងើយកន្ដើយដដែលៗ ដោយក្រុមជនមួយចំនួនបានបង្ហាញអោយឃើញនូវបញ្ហានេះនៅក្នុងសង្គមបានបដិសេធនូវសិទ្ធិជាមូលដ្ឋានរបស់ស្ត្រីដែលមានចែងនៅក្នុងច្បាប់ ។ ដោយមើលឃើញសុទ្ធតែបញ្ហាដ៏ធំធេងជាច្រើន និងជាការងាយណាស់ក្នុងការមើលរំលងនូវជំហានជាវិជ្ជមានដែលកំពុងអនុវត្ត ដើម្បីកែលំអឱកាស និងជីវភាពរស់នៅរបស់ស្ត្រីកម្ពុជា ។ ថ្វីត្បិតតែមានបុព្វហេតុយ៉ាងច្រើន ដែលត្រូវខ្វាយខ្វល់នឹងផ្លាស់ប្ដូរក៏ដោយ តែនៅមានចន្លោះប្រហោងស្ដីពីគំនិតឆ្លុះបញ្ចាំងទៅលើការកែលំអបន្ថែម ដែលបានសំរេចក្នុងទសវត្សមុន ។

## សេរីភាព និងការទុកចិត្តផ្ទាល់ខ្លួន

ការពង្រឹងអំណាចត្រូវបានបញ្ជាក់ដោយសេរីភាព ។ ការផ្ដល់អំណាចសកម្ម រួមមានសេរីភាពក្នុងការទៅសាលារៀន សេរីភាពក្នុងការទទួលបាននូវសេវាសុខភាព ដែលមានគុណភាពខ្ពស់សេរីភាពក្នុងការជ្រើសរើសការងារ និងសេរីភាពក្នុងការជ្រើសរើសគូរស្រករជាដើម ។ ចំណែកឯការផ្ដល់អំណាចអកម្មវិញរួមមានការរស់នៅដោយគ្មានការភ័យខ្លាចពីអំពើហិង្សាមកលើរាងកាយ និងផ្លូវភេទ ព្រមទាំងសេរីភាពជៀសផុតពីការរើសអើង និងជាអ្នកជំនួយរបស់បុរស ។ សេរីភាពទាំងនេះមានចែងនៅក្នុងច្បាប់កម្ពុជា និងក្នុងអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ហើយត្រូវបានលើកស្ទួយនឹងការពារដោយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការផ្សេងៗទៀត ។ តាមរយៈការខិតខំប្រឹងប្រែងរបស់អង្គការទាំងនោះ ស្ត្រីកម្ពុជាបានរៀនសូត្រអំពីសិទ្ធិរបស់ខ្លួនក្នុងនាមជាស្ត្រី និងជាមនុស្សបន្តិចម្ដងៗ ។ នេះ គឺជាជំហានសំខាន់ដំបូងបំផុតឆ្ពោះទៅរកស្ត្រីនៅក្នុងសង្គមទាំងមូលទូទៅមានទំនុកទុកចិត្តក្នុងការបង្កើតសមាគម និងក្រុមសហករណ៍ ដើម្បីការពារ និងអភិវឌ្ឍន៍សេរីភាពទាំងនេះ ។

## ស្ថាប័នរដ្ឋនានា និងរដ្ឋាភិបាល : ផ្លូវឆ្ពោះទៅរកការផ្ដល់អំណាចស្ត្រី

ជាងមួយទសវត្សទើបកន្លងផុតទៅ ប្រទេសកម្ពុជាស្ថិតនៅក្នុងសភាពអោនថយក្រោយពិតៗ ។ ដោយសារការខិតខំប្រឹងប្រែងរបស់អ្នកស្រី *ពុង ប៉េងចេង (ស៊ីវ អេងតុង)* និងអ្នកស្រី *ពុង ឈីវកេក*

ការចរចារ ក៏បានឈានដល់កិច្ចព្រមព្រៀងសន្តិភាព ។ រឿងរ៉ាវខ្លីៗនេះអាចជ្រើសរើសចេញពីប្រភពផ្សេងៗជាច្រើន ដែលបង្ហាញថាស្ត្រីពីធម្មជាតិ គឺជាអ្នកកសាងសន្តិភាព និងឈ្លាសវៃក្នុងសិល្បៈវិធីដោះស្រាយជំលោះតាមមធ្យោបាយអហិង្សា ។ ស្ត្រីមានតួនាទីយ៉ាងធំធេងនៅក្នុងសង្គមស៊ីវិល និងក្នុងជួររដ្ឋាភិបាលដោយជួយអោយកម្ពុជាមានការអភិវឌ្ឍន៏នឹងក្លាយទៅជាប្រទេសមួយ ដែលត្រូវបានគេកត់សំគាល់ថាជាប្រទេសដែលមានអភិបាលកិច្ចល្អ និងការគោរពសិទ្ធិមនុស្ស ។

ស្ត្រីជាច្រើនកំពុងផ្លាស់ប្តូរទិដ្ឋភាពនយោបាយ និងសង្គមតាមរយៈការងាររបស់ពួកគេនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងនៅក្នុងរដ្ឋាភិបាល ។ យុទ្ធនាការលើកកំពស់ស្ត្រីធ្វើឡើងយ៉ាងស្វិតស្វាញនៅក្នុងអង្គការទាំងអស់ខាងលើឱ្យច្រើនលើសពីនេះទៅទៀត លើបញ្ហាប្រឈមចំពោះស្ត្រី ដែលបានបញ្ជាក់នៅក្នុងរបាយការណ៏នេះ ។ ក្នុងនាមជានាយិការកមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គមអ្នកស្រី *ជា វណ្ណាត* បានប្រយុទ្ធជាមួយនឹងបញ្ហាមួយយ៉ាងធំបំផុតនៅក្នុង ប្រទេសកម្ពុជាបច្ចុប្បន្ននេះ ***គឺប្រឆាំងនឹងអំពើពុករលួយ*** ។ អ្នកស្រី បានលើកកំពស់ការយល់ដឹងអំពីជំងឺមហារីកសង្គមនេះ ដែលបានរាលដាលពាសពេញគ្រប់ស្រទាប់រដ្ឋាភិបាល និងរដ្ឋបាលកម្ពុជាទាំងមូល ព្រមទាំងបានបង្ហាញនូវគំលាតរវាងប្រជាធិបតេយ្យដែលមានដំណើរការ និងប្រជាធិតេយ្យអសកម្ម ។

នៅក្នុងរាជរដ្ឋាភិបាលលោកជំទាវ *មួរ សុខហួរ* បានវាយទំលុះទៅក្នុងបណ្តាញអភិបាលកិច្ចរបស់បុរសដើម្បីកាន់ដំណែងជារដ្ឋមន្ត្រី ។ ប្រវត្តិលោកជំទាវនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងការងារសង្គមបានធ្វើអោយលោកជំទាវកសាងទំនាក់ទំនងសហប្រតិបត្តិការរវាងសកម្មនិយមសង្គមស៊ីវិលចំពោះសិទ្ធិស្ត្រី និងរដ្ឋាភិបាល ។ ពេលមានការសាកសួរថា ហេតុអ្វីបានជាចូលទៅក្នុងរដ្ឋាភិបាល លោកជំទាវប្រកាសថា "ខ្ញុំចង់មានអំណាច ដើម្បីផ្លាស់ប្តូរអំណាច ដើម្បីចូលទៅជិតមេប៉ូលីស ហើយនិយាយប្រាប់ថា "ព្រះតេជគុណ-លោកត្រូវតែទទួលខុសត្រូវ" [109] ។

កង្វះភាពទទួលខុសត្រូវ និងការរីឡើងវិញនៃអំពើពុករលួយបណ្តាលអោយមានវប្បធម៌និទ្ទណ្ឌភាពកំពុងបោកបញ្ឆោតបរិយាកាសនៅកម្ពុជា ។ កំហុសតែមួយផ្នែកនេះ បានចោទជាសំណួរថា ហេតុអ្វីបានជាការអនុវត្តន៏សិទ្ធិស្ត្រីនៅកម្ពុជាបច្ចុប្បន្នលំបាកខ្លាំងម្លេះ ។ ដោយឡែកចំនួនស្ត្រីមានការកើនឡើងនៅក្នុងតំណែងធំៗនៃសង្គមស៊ីវិល និងរដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននោះនឹងមានអនាគតដែលស្ត្រីអាចនិយាយថា "លោក-គឺលោកជាអ្នកទទួលខុសត្រូវ ***ពេលនេះអ្វីដែលលោកត្រូវធ្វើនោះ*** " គឺការផ្តល់អំណាចសំរាប់ស្ត្រី ។

---

[109] បញ្ជាក់នៅក្នុង អភិបាលកិច្ចល្អពីមូលដ្ឋានឡើងទៅ : តួនាទីរបស់ស្ត្រីនៅក្រោយសង្គ្រាមកម្ពុជា - (Laura McGrew, Kate Frieson, Sambath Chan; គណៈកម្មការ Women Waging Peace-ខែមិនា ឆ្នាំ២00៤) ទំ. ១៥ ។

# ឯកសារពិគ្រោះ


- ការរំលោភទាក់ទងនឹងដំណើរការសុំកូនចិញ្ចឹមលក្ខណៈអន្តរជាតិនៅកម្ពុជា (របាយការណ៍សង្ខេប) លីកាដូ ខែមករា ឆ្នាំ២០០២) ។
- ការសិក្សាស្រាវជ្រាវអំពីសុខភាពនិងប្រជាសាស្ត្រកម្ពុជា ឆ្នាំ២០០០: របាយការណ៍បឋម (វិទ្យាស្ថានស្ថិតិនៃក្រសួងផែនការ និងក្រសួងសុខាភិបាល ឆ្នាំ២០០០) ។
- របាយការណ៍ទូទៅនៃប្រទេសកម្ពុជា (www.adb.org/documents/HIV_AIDS/mobility/b.pdf)
- របាយការណ៍ទូទៅនៃប្រទេសកម្ពុជា ( IWRAW Asia -Pacific ខែមិនា ឆ្នាំ ២០០២): គន្លឹះកាត់ដេរសំរាប់ពិភពលោក ( Oxfam GB ឆ្នាំ ២០០៣ ) ។
- កម្ពុជា លើទិដ្ឋភាពធំ ( UNICEF កម្ពុជា ឆ្នាំ ២០០៣ ) ។
- សិទ្ធិស្ត្រីកម្ពុជា (វេជ្ជបណ្ឌិត ពុង ឈីវកេក-ការពិភាក្សាទ្វេរភាគីរវាងសកម្មជនសិទ្ធិស្ត្រី និងអង្គការសិទ្ធិមនុស្ស នៅទីក្រុងម៉ានីល ហ្វីលីពីន ឆ្នាំ១៩៩៦) ។
- ឧបសគ្គចំពោះសិទ្ធិស្ត្រីនៅតំបន់អាស៊ី : សិទ្ធិស្ត្រី និងអំណាចនយោបាយនៅកម្ពុជា (សន្ទរកថាថ្លែងដោយវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ ខែឧសភា ឆ្នាំ១៩៩៨) ។
- ពលកម្មកុមារនៅកម្ពុជា (វិទ្យាស្ថានការងារសេរីអាស៊ី អាមេរិក និងលីកាដូ ខែកញ្ញា ឆ្នាំ១៩៩៦) ។
- គំនិតផ្តួចផ្តើមសហគមន៍ ដើម្បីទប់ស្កាត់អំពើជួញដូរស្ត្រី-បទពិសោធន៍នៅកម្ពុជា (ការផ្លាស់ប្តូរសុខភាពផ្លូវភេទ ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា CWDA ឆ្នាំ ២០០៣) ។
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ (ជំពូកអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ សេចក្តីសំរេចលេខ ៣៤/១៨០ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ១៩៧៩) ។
- អំពើពុករលួយ និងកេងប្រវ័ញ្ចផ្លូវភេទ: (សន្ទរកថា ថ្លែងដោយ វេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ នៅមុខវត្តបុទុមវត្តី ខែធ្នូ ឆ្នាំ ២០០១) ។
- ការអនុវត្តន៍ច្បាប់ : ឧបសគ្គ និងរបៀបជំនះឧបសគ្គ ។ សិក្ខាសាលាស្តីពីកិច្ចការពារផ្លូវច្បាប់ និងការអនុវត្តន៍ច្បាប់ក្នុងអំពើជួញដូរស្ត្រី និងកុមារ (សន្ទរកថាថ្លែងដោយ វេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ ២០០០) ។
- ការសម្របសម្រួលការអនុវត្តន៍ CEDAW សំដៅសំរេចអោយបាននូវសិទ្ធិមនុស្សរបស់ស្ត្រីក្នុងតំបន់អាស៊ីអាគ្នេយ៍ ( មូលនិធិអភិវឌ្ឍន៍ស្ត្រីអង្គការសហប្រជាជាតិ UNDFW & CIDA ឆ្នាំ ២០០៤ ) ។
- យេនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ: (ឯកសារផ្នែកអង្គការ និងបញ្ហានានា ស្តីពីការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០០៣ ) ។
- ស្ថិតិយេនឌ័រ ក្រុមធនាគារពិភពលោកប្រចាំកម្ពុជា (http://devdate.worldbank.org /genderstats / cambodia)

- អភិបាលកិច្ចល្អពីថ្នាក់មូលដ្ឋានឡើងទៅ : តួនាទីរបស់ស្ត្រីក្រោយសង្គ្រាមនៅកម្ពុជា (Laura McGrew, Kate Frieson, Sambath Chan; គណៈកម្មការ Women Waging Peace ខែមិនា ឆ្នាំ២០០៤) ទំ. ១៥ ។
- សិទ្ធិមនុស្ស និងពន្ធនាគារកម្ពុជា: របាយការណ៍ ឆ្នាំ២០០១ ស្តីពីសុខភាព (លីកាដូភ្នំពេញ ឆ្នាំ២០០១) ។
- សិទ្ធិមនុស្ស និងពន្ធនាគារកម្ពុជា : របាយការណ៍ ឆ្នាំ២០០១ ស្តីពីស្ថានភាពពន្ធនាគារ (លីកាដូភ្នំពេញ ឆ្នាំ២០០១) ។
- របាយការណ៍ស្ថានភាពសិទ្ធិមនុស្ស: (សមាគមសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ ខែមករា ឆ្នាំ ២០០៤) ។
- របាយការណ៍បឋមទី២ និងទី៣ ស្តីពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ខែ តុលា ឆ្នាំ២០០៣) ។
- ជនគ្មានទោសពៃរ៍ក្នុងពន្ធនាគារ: របាយការណ៍លីកាដូ ស្តីពីសិទ្ធិកុមារធំដឹងក្តីនៅក្នុងពន្ធនាគារ (Hilary Margolis) លីកាដូ ខែមិថុនា ឆ្នាំ២០០២) ។
- យុត្តិធម៌ និងការផ្សះផ្សារជាតិ ។ ករណីសិក្សាអំពីកម្ពុជា (Ming- Try Ea) មជ្ឈមណ្ឌល ដើម្បីសិក្សាការលើកលែងទោស និងការផ្សះផ្សារ ឆ្នាំ២០០១) ។
- មិនសមរស់នៅជាមនុស្ស: អំពើទារុណកម្មនៅកម្ពុជា (Jason Barber) របាយការណ៍កម្មវិធីប្រឆាំងនឹងទារុណកម្ម លីកាដូ ខែមិថុនា ឆ្នាំ២០០០) ។
- រស់នៅក្នុងភពអន្ធការ : ការវាយប្រហារដោយអាស៊ីតនៅកម្ពុជា (កម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម - លីកាដូ ឆ្នាំ២០០៣) ។
- ការវាស់ស្ទង់ចំនួនស្ត្រីដែលរងគ្រោះដោយអំពើជួញដូរស្ត្រី និងកុមារនៅកម្ពុជា) ការសិក្សាដោយការសង្កេតផ្ទាល់នៅមូលដ្ឋាន (Thomas Steinfatt,) សកលវិទ្យាល័យម៉ៃអាមី ឆ្នាំ២០០៣) ។
- នារីរតនៈ : ស្ត្រីគឺជាត្បូងមានតំលៃ ។ ផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ (ក្រសួងកិច្ចការនារី និងអតីតៈយុទ្ធជន ខែកុម្ភៈ ឆ្នាំ១៩៩៩) ។
- វេទិការអង្គការមិនមែនរដ្ឋាភិបាលស្តីពីស្ត្រីនៅប៉េកាំង ឆ្នាំ១៩៩៥ : សិទ្ធិស្ត្រី គឺសិទ្ធិមនុស្ស (លីកាដូ ឆ្នាំ១៩៩៥) ។
- ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងកិច្ចខិតខំប្រឹងប្រែងកម្ពុជា និងក្នុងតំបន់ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស (វេជ្ជបណ្ឌិត ពុង ឈីវកេក លីកាដូ ARIAT, ឯកសារចែកចាយព័ត៌មានសង្ខេប-ក្រុងម៉ានីល ឆ្នាំ២០០០) ។ ដៃគូរ ដើម្បីសមភាពយេនឌ័រ (PGE) (UNDP ឆ្នាំ២០០៣) ។
- វេទិការគោលនយោបាយ ដើម្បីទស្សនៈវិស័យស្ត្រីអនាគត (សន្ទរកថាថ្លែងដោយ វេជ្ជ. ពុង ឈីវកេក លីកាដូ ភ្នំពេញ ខែមេសា ឆ្នាំ១៩៩៩) ។
- សេចក្តីរៀបចំបាយការណ៍អប់រំព្រាង សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា ភ្នំពេញ ខែឧសភា ឆ្នាំ២០០៤ ។

- អំពើរំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ : ឧក្រិដ្ឋកម្មនៅក្នុងសហគមន៏ (Dien O'connel, ) របាយការណ៏ពិសេស លីកាដូ ខែកុម្ភៈ ឆ្នាំ២០០១ ) ។
- អំពើរំលោភ និងបៀតបៀនកេរ្តិ៍ខ្មាស់ : ( របាយការណ៏សង្ខេបលីកាដូ ភ្នំពេញ ខែមិនា ឆ្នាំ២០០៤ ) ។
- របាយការណ៏ស្តីពីការលប់បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅកម្ពុជា ( គណៈកម្មការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ឆ្នាំ ២០០១ ) ។
- របាយការណ៏ស្តីពីយុទ្ធនាការបញ្ចុះបញ្ចូល ដើម្បីអោយមានការពិនិត្យសារឡើងវិញនូវសេចក្តីព្រាងច្បាប់ថ្មីស្តីពីអំពើហិង្សាក្នុងគ្រួសារ ( ឃែមបូវ ភ្នំពេញ ខែកញ្ញា ឆ្នាំ២០០២ )
- របាយការណ៏ស្តីពីយុទ្ធនាការ ១៩៩៨ : យុទ្ធនាការ ១៦ថ្ងៃនៃការប្រឆាំងនឹងអំពើហិង្សាមកលើស្រ្តីនៅខេត្តកំពង់ចាម កំពង់ស្ពឺ និងកណ្តាល ( ក្រសួងកិច្ចការនារី និងគណៈកម្មការអង្គការមិនមែនរដ្ឋាភិបាលស្តីពីសិទ្ធិស្រ្តី ខែធ្នូ ឆ្នាំ១៩៩៨ ) ។
- កាសែតបាងកកប៉ុស្ត៍ ( ២០០៣ ) ។
- តំលៃស្រ្តីក្នុងសង្គមកម្ពុជា ( ទិដ្ឋភាពកម្ពុជា ខែមិនា និងមេសា ឆ្នាំ២០០៤) ។
- កាសែតឌីឃែមបូឌាដេលី ( ឆ្នាំ១៩៩៨-២០០៤ ) ។
- មជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្រ្តីមានវិបត្តិ — ជួយស្រ្តី ដើម្បីអោយស្រ្តីចេះជួយខ្លួនឯង ( របាយការណ៏ប្រចាំឆ្នាំ នៃមជ្ឈមណ្ឌលកម្ពុជា ដើម្បីជួយស្រ្តីមានវិបត្តិ ខែមករា-ធ្នូ ឆ្នាំ២០០២) ។
- ក្រុមធនាគារពិភពលោក : ទិន្នន័យទូទៅកម្ពុជា (http://devdata.worldbank.org/external )
- ការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ( របាយការណ៏សង្ខេប លីកាដូ ខែធ្នូ ឆ្នាំ ២០០៣ ) ។ UNICEF: ស្ថិតិកម្ពុជា (http://www.unicef.org/infobycountry /cambodia_statistics.html) ស្រ្តី និងជំលោះ : ទស្សនះទូទៅនៃការកសាងប្រជាធិបតេយ្យ ការអភិវឌ្ឍន៏ និងសន្តិភាព ( សន្ទរកថា ថ្លែងដោយ វេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ សភាតំណាងរាស្រ្តអង់គ្លេស ខែឧសភា ឆ្នាំ១៩៩៩ ) ។
- ស្ថានភាពស្រ្តី: ការអប់រំ សុខភាព និងអំណាចនយោបាយនៅកម្ពុជា ( សន្ទរកថា ថ្លែងដោយ វេជ្ជបណ្ឌិត ពុង ឈីវកេក-យ៉ាម៉ាកាតា ជប៉ុន ឆ្នាំ១៩៩៨ ) ។
- ស្រ្តីធ្វើការនៅកម្ពុជា : (Astrid Asfjes & Bama Atheya ) លីកាដូ និងវិទ្យាស្ថានការងារសេរីអាស៊ី- អាមេរិក) ។